# ឯកត្តឹសភូមិកថា




រៀបរៀងដោយ ដាំ កុយ

# ឯកត្តីសត្ថមិកថា

- រៀបរៀង = ឧបាសិកា **ដាំ~កុយ** ។

- ពិនិត្យ ផ្ទៀងផ្ទាត់ សម្រួលពាក្យពេចន៍ = ឯកឧត្តម បណ្ឌិត **កុល~ផេង** ទេសរដ្ឋមន្ត្រី អនុប្រធានឧត្តមក្រុមប្រឹក្សាជាតិអប់រំ និងជាប្រធានក្រុមប្រឹក្សាភិបាល នៃពុទ្ធិកបណ្ឌិតសភា សាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា ។

- វាយអត្ថបទ ឧបាសក = **អៀម~ពោរដ្ឋា** ។

- វាយអត្ថបទបង្ហើយ និងកែអក្ខរាវិរុទ្ធ = ឧបាសក **ស៊ុន~សុផាន** ។

- ផ្សាយចេញពីពុទ្ធិកបណ្ឌិតសភា នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា ។

## អារម្ភកថា

បុព្វហេតុ ដែលនាំឲ្យកើតជាសៀវភៅដ៏ស្ដើងនេះឡើង ដោយខ្ញុំព្រះករុណា ខ្ញុំបាទយល់ឃើញថា ៖

- មនុស្សដែលកើតមកក្នុងលោកសន្និវាសនេះ រមែងមានចរិយា ( ការប្រព្រឹត្ត ) ដោយសង្ខេប មាន ២ បែប ដែលផ្ទុយពីគ្នា គឺពួកមនុស្សស្រប្បុរស ឬបណ្ឌិត លោកមានសប្បុរសធម៌ និងបណ្ឌិតធម៌ បំពេញប្រយោជន៍ទាំង ២ មានសទ្ធា សីល ចាគៈ សុតៈ បញ្ញា មានហិរិ ឱត្តប្បៈ បដិបត្តិនូវធម៌ដ៏សមគួរដល់ធម៌ ជាសុក្កាធម្មា ( ធម៌ស ) ។ ល ។ ឯបុគ្គលមួយពួកទៀត ហៅថា អសប្បុរស ឬពាល ពួកនេះ គ្មានគុណធម៌ ប្រព្រឹត្តអាក្រក់ដោយកាយ វាចា ចិត្ត មិនស្គាល់គុណ ទោស ខុស ត្រូវ មិនខ្មាសបាប មិនខ្លាចបាប ជាអ្នកកាត់បង់នូវប្រយោជន៍ទាំង ២ មិនមានសទ្ធាជ្រះថ្លាក្នុងព្រះត្រៃរតន៍ ជាមិច្ឆាទិដ្ឋិ មិនបានសន្សំបុញ្ញកម្មផ្សេងៗ ដើម្បីសេចក្ដីសុខសម្រាប់ខ្លួន សូម្បីតិចតួច

ឡើយ មិនតែប៉ុណ្ណោះ ថែមទាំងពោលពាក្យតិះដៀល ប្រទូស្តចំពោះអ្នកមានសីលបរិសុទ្ធទៀតផង ។

- ផលវិបាក និងគតិរបស់បុគ្គល ២ ពួកនេះ ផ្សេងឆ្ងាយពីគ្នា ផ្ទុយពីគ្នា ខុសគ្នាឆ្ងាយយ៉ាងក្រៃលែង ដូចព្រះគាថា ព្រះសម្មាសម្ពុទ្ធ បរមគ្រូជាម្ចាស់ ត្រាស់ចំពោះព្រះ-អានន្ទ ដោយទ្រង់ប្រារព្ធទៅលើ ព្រះពោធិសត្វអរិយ-មេត្តេយ្យ ( ព្រះបាទសង្ខ: ) ថា ៖

**ទុទ្ទសំ ទទមានំ ទុក្ករំ កម្មកុព្វតំ**

**អសន្តោ នានុកុព្វន្តិ សតំ ធម្មោ ទុរន្នយោតិ ។**

សប្បុរស ( បណ្ឌិត ) បានឲ្យនូវទាន ដែលគេគប្បីឲ្យបានដោយកម្រ ធ្វើនូវអំពើ ដែលគេធ្វើបានដោយកម្រ ។ អសប្បុរស ( ពាល ) មិនធ្វើតាមសប្បុរសទេ ធម៌របស់សប្បុរសទាំងឡាយ អសប្បុរស មិនអាចឲ្យប្រព្រឹត្ត

**តស្មា សតញ្ច អសតញ្ច នានាហោតិ គតោ ឥតិ**

**អសន្តោ និរយំ យន្តិ សន្តោ សគ្គបរាយនាតិ ។**

ព្រោះហេតុដូច្នោះ សប្បុរស និងអសប្បុរស រមែងទៅកាន់ផ្លូវផ្សេងគ្នា អសប្បុរសរមែងទៅកាន់នរក ឯសប្បុរសមានស្ថានសួគ៌ ជាទីប្រព្រឹត្តទៅ ក្នុងខាងមុខ ។

- ការសម្តែងអំពីទីកើតនៃសត្វ ៣១ ភូមិ ប្រៀបដូចជាប្រទីបដ៏តូចមួយ សម្រាប់ជាគ្រឿងបំភ្លឺ ឬការពិចារណាដល់ជាតិកំណើតនៃយើងទាំងអស់គ្នា **ជាតឹ បច្ចវេក្ខិតព្វា** ដែល បានកើតជាមនុស្សដោយសារបុណ្យ **បុព្វេ ច កត~បុញ្ញតា** ដែលបានសន្សំរាប់កប្បមកហើយ ព្រោះថាយើងជាបុថុជ្ជន ឋិតនៅក្បែរ អែបជិតរណ្តៅអបាយភូមិ ( គួរឲ្យភ័យ យ៉ាងក្រៃលែង ) ប្រសិនបើយើងមិនបានសន្សំបុញ្ញកម្ម ឲ្យរឿយៗ ចិត្តសៅហ្មងនៅពេលមរណាសន្នជវនមកដល់ ចុតិភ្លាម ប្រាកដជាធ្លាក់ទៅកាន់អបាយភូមិ មិនខាន **ចិត្តេ សង្កិលិដ្ឋេ ទុគ្គតិ បដិកង្ខា** កាលបើចិត្តសៅហ្មង ( ពេលដាច់ខ្យល់ ) ទុគ្គតិនឹងប្រាកដ ។ កាលដែលធ្លាក់ខ្លួនទៅកើតក្នុងអបាយភូមិហើយ ធ្វើម្តេចឡើយនឹងឲ្យទាន ឬ

រក្សាសីល សូម្បីមួយពេលបាន បើគ្មានសីលជាស្ពាន ជាគ្រឿងទ្រហើយ តើសុគតិមានមកពីណា ?

**តស្មា ករេយ្យ កល្យាណំ និចយំ សម្បរាយិកំ**

**បុញ្ញានិ បរលោកស្មឹ បតិដ្ឋា ហោន្តិ បាណិនំ ។**

ព្រោះហេតុដូច្នោះ សាធុជន ( យើងទាំងអស់គ្នា ) អ្នកមានបំណងចង់បានសេចក្តីសុខដល់ខ្លួន ត្រូវតែប្រញាប់-ប្រញាល់ ធ្វើនូវអំពើបុណ្យដែលជាគុណ គឺលោកអ្នកប្រាជ្ញតែងរាប់អាន ឲ្យបានជាកិច្ច គឺខ្លួនគប្បីកសាងសន្សំ គ្រាន់នឹងបានជាទីពឹងពាក់ពំនាក់អាស្រ័យ ព្រោះថា បុណ្យទាំង-ឡាយ រមែងជាទីពឹងរបស់សត្វទាំងឡាយ ក្នុងបរលោក ។

ម្យ៉ាងទៀត យើងទាំងអស់គ្នា ដែលបានធ្វើដំណើរក្នុងសង្សារវដ្តដ៏អង្វែងនេះ ឥតមានធនធាន ទ្រព្យសម្បត្តិ ដែលស្វះស្វែងរកគ្រប់ៗ ជាតិនេះ ដ៏តិចតួចឡើយ សូម្បីវត្ថុជាទីស្រឡាញ់ពេញចិត្ត ដូចកូន ប្រពន្ធ ប្តីសីជាដើម ក៏ពុំបានយកទៅជាមួយដែរ ។

ការពិតមានតែ**កុសលាកុសល**ប៉ុណ្ណោះ ដែលយើងសន្សំក្នុងសន្ដាន អាចនាំទៅជាប់ខ្លួនបាន ។

សាធុសប្បុរសទាំងឡាយ ! ជីវិតរបស់យើង មានប្រមាណតិចណាស់ យើងមិនគួរប្រហែសឡើយ គួរតែព្យាយាមបំពេញកុសល ឲ្យបានរឿយៗ យ៉ាងហោចណាស់ក៏គួររក្សាបញ្ចសីល ( សីល ៥ ) ឲ្យបានជាប់លាប់បរិសុទ្ធ កុំឲ្យសៅហ្មងព្រោះ ៖

**យោ ច វស្សសតំ ជីវេ ទុស្សីលោ អសមាហិតោ**

**ឯកាហំ ជីវិតំ សេយ្យោ សីលវន្តស្ស ឈាយិនោ ។**

បុគ្គលណា ទ្រុស្តសីល ( គ្មានសីល ) មិនមានចិត្តតម្កល់មាំ ទោះបីរស់នៅអស់រយៈឆ្នាំ ក៏មិនប្រសើរ ( ឥតប្រយោជន៍ ) , ឯបុគ្គលអ្នកមានសីល មានឈាន ( ការសម្ងំ ) សូម្បីមានជីវិតរស់នៅតែមួយថ្ងៃ ក៏ឈ្មោះប្រសើរ ( មានប្រយោជន៍ ) ជាទីពឹងសម្រាប់ខ្លួន និងសម្រាប់បុគ្គលដទៃ យ៉ាងក្រៃលែង ។

**អជ្ជេវ កិច្ចមាតប្បំ កោ ជញ្ញា មរណំ សុវេ**

**ន ហិ នោ សង្គរន្តេន មហាសេនេន មច្ចុនោ ៕**

*ការព្យាយាម ជាគ្រឿងដុតកិលេស បុគ្គលគួរតែធ្វើក្នុងថ្ងៃនេះឯង អ្នកណានឹងដឹងថា សេចក្តីស្លាប់នឹងមាន ក្នុងថ្ងៃស្អែកបាន ព្រោះការតទល់របស់យើង នឹងមច្ចុរាជដែលមានសេនាដ៏ច្រើននោះ មិនមានឡើយ ។*

*សូមឧទ្ទិស មហាកុសលនៃធម្មទាននេះ ថ្វាយ ប្រគេនជូនចំពោះលោកដ៏មានគុណទាំងឡាយ មានសម្តេចព្រះ-សង្ឃរាជ* **ជួន-ណាត** *, សម្តេចព្រះធម្មលិខិត* **លី្វ-ឯម** *, សម្តេចព្រះសង្ឃរាជ* **ហួត-តាត** *, ព្រះគ្រូ***បុរត្ថិមវាសី** **អ៊ុំ-ចេវ** *, ព្រះសង្ឃគ្រប់ព្រះអង្គ ពុទ្ធសាសនិកខ្មែរទាំងអស់ ព្រមទាំងញាតិសាលោហិតក្នុងសង្សារវដ្ត មួយអន្លើដោយសព្វសត្វទាំងឡាយ ទាំងពួង ។ សូមទ្រង់ព្រះមេត្តាទទួល និងទទួលអនុមោទនាត្រេកអរ ហើយសូមបានទូវសេចក្តីសុខ រួចផុតចាក*

ទុក្ខ គ្រប់ៗ ព្រះអង្គ គ្រប់ៗ គ្នា កុំបីឃ្លៀងឃ្លាត ក្លាយជាប្រការដទៃឡើយ ។

សូមអភ័យទោស ចំពោះកំហុសដោយអចេតនា និងសូមមេត្តាជួយកែសម្រួល តម្រូវ ដោយកុសលចិត្ត ។

**សូមអរព្រះគុណ~សូមអរគុណ**

ឧបាសក **ជាំ~គុយ**

# ឯកសារដើម

- **ព្រះវិនយបិដក** *ភាគ ១* **មហាវគ្គ** *បរាជិកកណ្ឌ*
- **ព្រះសុត្តន្តបិដក** *ភាគ ៣២* **សំយុត្តនិកាយ** *និទានវគ្គ*
- **ព្រះសុត្តន្តបិដក** *ភាគ ៥៦* **ខុទ្ទកនិកាយ** *បេតវត្ថុ*
- **និរយកថា** *ស្នាព្រហស្តព្រះមហា* **ខិម~ណារុត្រី**
- **លោកគ្រត** *ស្នាដៃព្រះបាឡាត់ សម្តេចព្រះធម្មលិខិត* **លឹ្វ~ឯម ( សុខ~ស៊ីច )**
- **សគ្គកថា** *ស្នាព្រហស្តព្រះមហា* **ខិម~ណារុត្រី**
- **អភិធម្មត្ថសង្គហៈ** *ស្នាព្រះហស្តព្រះភិក្ខុ អគ្គធីរោ* **គង់~សាមិត**
- **បរមត្ថជោតិកៈ** *ស្នាព្រះហស្ត ព្រះភិក្ខុកោសលមុនី* **មៀវ~ថាន**
- **ធម្មបទដ្ឋកថា** *យមកវណ្ណនា ស្នាព្រះហស្ត ព្រះភិក្ខុ* **លឹម~ធន់**
- **ខ្សែអាត់សំឡេង** *ព្រះធម្មទេសនា លេខ ១៥៨៧ សម្តែងដោយ លោកគ្រូ អគ្គបណ្ឌិត* **ប៊ុត~សាវង្ស**
- **វចនានុក្រមខ្មែរ** *ស្នាព្រះហស្ត សម្តេចព្រះមហាសុមេធាធិបតី* **ជួន~ណាត** *ជោតញ្ញាណោ ព្រះសង្ឃរាជ ថ្នាក់ទី ១ ។*

**ចិរំ តិដ្ឋតុ ពុទ្ធសាសនំ** *សូមព្រះពុទ្ធសាសនា ឋិតថេរគង់វង្សយូរអង្វែង ជាអមតៈ ។*

**ព.ស.**២៥៦១

**គ.ស.**២០១៨

# នមត្ថុ រតនត្តយស្ស

# ឯកត្តឹសភូមិកថា

## ការសម្ដែងអំពី ទីកើតនៃសត្វ ៣១ ឋាន ( សង្ខេប )

*ពាក្យថា* **ភូមិ** *បានសេចក្ដីថា ផែនដី , ទីដី , តំបន់ , ផ្ទៃ , ទី , ជាន់ , ថ្នាក់ ។*

## ភូមិ៤

*អបាយភូមិ ១ , កាមសុគតិភូមិ ១ , រូបាវចរភូមិ ១ , អរូបាវចរភូមិ ១ ។*

## អបាយភូមិ ៤

*នរក ១ , ប្រេត ១ , អសុរកាយ ១ , តិរច្ឆាន ១ ។*

## កាមសុគតិភូមិ ៧

*មនុស្សភូមិ ១ , ចាតុម្មហារាជិកាភូមិ ១ , តាវត្តឹស-ភូមិ ១ , យាមាភូមិ ១ , តុសិតាភូមិ ១ , និម្មានរតីភូមិ ១ , បរនិម្មិតវសវត្តីភូមិ ១ ។*

អបាយភូមិ ៤ និងកាមសុគតិ ៧ ( ១១ ជាន់នេះ **ហៅថា** កាមាវចរភូមិ ) ។

**តទៅនេះ ជាសេចក្តីពន្យល់ដោយសង្ខេប ៖**

ពាក្យថា **អបាយភូមិ** បានសេចក្តីថា ឋាន , ជាន់ ឬទីអបាយ , កំណើតសត្វដែលប្រាសចាកសេចក្តីចម្រើន មាន ៤ គឺ នរក , ប្រេត , អសុរកាយ និងតិរច្ឆាន ។

# ១.នរក

**នរក ឬនិរយៈ នរក** ប្រែថា រណ្តៅ ឬអន្លង់ **និរយៈ** ប្រែថា ភូមិ ឬជាន់មិនមានសេចក្តីចម្រើន គឺទីអបាយ ឬអធោលោក មានរណ្តៅ ឬអន្លង់ ជាលំនៅឋានរបស់ពួកសត្វមានបាប រងទុក្ខវេទនាតាមកម្លាំងកម្ម ដែលខ្លួនបានធ្វើ បានសេចក្តីថា សត្វនរកតែងទទួលទុក្ខទោស ទារុណកម្មគ្រប់ឥរិយាបថ ឥតពេលស្រាកស្រាន្ត ឯសេចក្តីសុខសប្បាយតិចតួចក៏ពុំមានឡើយ ។

## ការប្រៀបធៀប ៖

- សេចក្ដីសុខរបស់មនុស្ស ប្រសើរជាងសត្វតិរច្ឆាន
- សេចក្ដីសុខរបស់សត្វតិរច្ឆាន ប្រសើរជាងអសុរកាយ
- សេចក្ដីសុខរបស់អសុរកាយ ប្រសើរជាងប្រេត
- សេចក្ដីសុខរបស់ប្រេត ប្រសើរជាងនរក

សេចក្ដីប្រៀបធៀបនេះ ជាសក្ខីភាពបញ្ជាក់ថា ពួកសត្វក្នុងឋាននរក មានតែសេចក្ដីទុក្ខជានិរន្តរកាល ។

**ព្រះសម្មាសម្ពុទ្ធ ទ្រង់ត្រាស់សំដែងនៅក្នុងទេវទូតសូត្រ**

## នរក មាន ៧ រណ្ដៅ ៖

**ក-លោកកុម្ភីនរក** = នរកខ្ទះទង់ដែង

នរកនេះ មានខ្ទះទង់ដែង ទំហំធំជម្រៅ ៦០ យោជន៍ ក្ដៅពុះខ្ជោល ៗ ជានិច្ចកាល តាំងនៅអស់កប្ប ។ នាយនិរយបាល ចាប់ជើងសត្វនរកឡើងលើ ក្បាលសំយុងចុះក្រោម បោះទៅក្នុងខ្ទះទង់ដែង ដែលកំពុងពុះគគ្រាក់នោះ សត្វនរកត្រូវលិចចុះដល់បាតខ្ទះ អស់រយៈពេល ៣០,០០០

ឆ្នាំ ត្រូវអណ្តែតមកដល់មាត់ខ្ទះវិញ រយៈពេល ៣០,០០០ ឆ្នាំដូចគ្នា សត្វនរកត្រូវសោយទុក្ខរបៀបនេះ រហូតដល់អស់បាបកម្ម ។

**ខ~អវិចីនរក** = នរកមិនទំនេរ , មិនចន្លោះ

នរកនេះ មិនទំនេរដោយអណ្តាតភ្លើង ១ , មិនចន្លោះពាកសត្វនរក ១ , មិនចន្លោះចាកសេចក្តីទុក្ខ ១ ។

បាបកម្ម ដែលនាំឲ្យធ្លាក់អវិចីនរក បណ្តាលមកអំពីអាចិណ្ណកម្ម ដែលបានសន្សំ មានអកុសលកម្មបថ ១០ មិច្ឆាជីវៈ ទម្លាយលោកអ្នកមានសីលខ្លះ អ្នកមានបញ្ញាខ្លះ ទម្លាយព្រះអរិយបុគ្គលខ្លះ និងធ្វើអនន្តរិយកម្មខ្លះ ។

លុះរួចចាកពីនរកនេះ នៅសេសសល់ផលកម្ម មកកើតក្នុងនរកជាបរិវារ ប្រេត អសុរកាយ តិរច្ឆាន ត្រូវអត់ឃ្លាន ត្រដាបត្រដួស គេវាយវាត់ ទាត់ធាក់ ទឹម ជិះ កាប់សម្លាប់ ក្រៀវ វះ ពន្លះ ពន្លាត់ ពង្រាត់បង្រាសឲ្យរត់ឲ្យលូន សូន្យចាកសេចក្តីសុខ មានតែទុក្ខជារៀងរហូត ។

**គ~គូថនរក** = នរកដុំលាមក

នរកនេះ មានទទឹង និងបណ្ដោយ ១០០ យោជន៍ ពេញដោយមូត្រ និងលាមក ស្អុយគគ្រុក ឆ្អេះឆ្អាប អសោចិ៍ យ៉ាងក្រៃលែង មានដង្កូវប៉ុនដីរសារខ្លះ ប៉ុនទូកកម្រោលខ្លះ មានមាត់តូចស្រួចឆ្មីមដូចម្ជុល ពេលនិរយបាល ចាប់សត្វនរកបោះទៅក្នុងរណ្ដៅ ជុំលាមកអណ្ដែតឡើងលាយឡំនឹងទឹកមូត្រក្ដៅ ពួកដង្កូវនាំគ្នាទៅចាក់បុករុក ស្បែកសាច់ឲ្យរលុះរលួយ ធ្លាយដល់ពោះវៀន ដោយសេចក្ដីស្រេកឃ្លានខ្លាំងពេក ក៏រើសដុំលាមកដែលក្ដៅដូច រងើកភ្លើងនោះមកស៊ី ( លេប ) ពេលចូលដល់ក្នុងពោះកាលណា ក៏ក្ដៅស្វោកពោះវៀន ស្លាប់កើត ៗ ប្រវេប្រវាឡើងមកលើ ក៏ត្រូវពួកនិរយបាល ដែលកំពុងឈរចាំចាក់ទម្លាក់ទៅវិញ ។

បាបកម្មទាំងនេះ ព្រោះលោកមច្ឆរិយៈ គឺសេចក្ដីកំណាញ់ លាភសក្ការៈ បន្ទំលាភសង្ឃ ចិញ្ចឹមជីវិតដោយមិច្ឆាជីវៈ ដាក់ទោសទណ្ឌដល់អ្នកគ្មានកំហុស ប្រទូស្តចំពោះអ្នកមានឧបការៈលើខ្លួន ។ ល ។

**ឃ~គូថនរក** = នរកផេះក្ដៅ

នរកនេះ មានទទឹង និងបណ្តោយ ១០០ យោជន៍ ពេញដោយផេះ និងរងើកភ្លើងធំៗ ប៉ុនប្រាសាទ ក្តៅក្រហម ប្រាលរន្ទាល ជានិរន្តរ៍ ។ ពួកនិរយបាលចាក់ដោយលំពែង ឬដែកស្រួច ឬស្នូ សត្វនរក បានឃើញកុក្កុលនរកនោះ ស្មានថា វាលខ្សាច់ ឬផ្ទូវខ្សាច់ សម្រាប់កម្សាន្តសប្បាយ មានចិត្តត្រេកអរ នាំគ្នារត់តម្រង់សំដៅទៅ ពេលធ្លាក់ដល់ ទើបដឹងថា ផេះក្តៅ ក៏នាំគ្នាបម្រះកន្ត្រាងលោតចុះឡើង ៗ មិនរួច ធ្លាក់ចុះក្នុងរណ្តៅវិញត្រឹមចង្កេះ ត្រូវផេះក្តៅឆេះ រលេះរលួយស្លាប់កើត ៗ រហូតដល់អស់បាបកម្ម ។

ទោសនៃការកើតក្នុងនរកនេះ បានដល់ការចាប់សត្វ ទាំងរស់ បោះទៅក្នុងរងើកភ្លើងខ្លះ ជាសមណៈទ្រុស្តសីលខ្លះ ដែលបរិភោគបច្ច័យ ៤ របស់អ្នកស្រុក ដោយមិនបាន ពិចារណាខ្លះ កំណាញ់ធម៌មិនប្រាប់ដល់អ្នកដទៃ ខ្លាចក្រែង គេចេះដឹង និងកើតលាភសក្ការៈច្រើនលើសខ្លួនខ្លះ ។

**ខ-សិម្ពលីនរក** = នរកដើមរកា

ដើមរកាទាំងនោះ ធំ ៗ មានកម្ពស់ ១ យោជន៍ មានបន្ទាដែកស្រួចប្រវែង ១៦ អង្គុលី ។ នាយនិរយបាលដេញសត្វនរក ឲ្យឡើងដើមរកា ដោយសត្ថបករណ៍ទាំងឡាយ មានលំពែងជាដើម ពេលនោះ បន្ទាក្នុកចុះមកក្រោមមុតជុះ រលុះរលួយឈាមស្រោចពេញខ្លួន កាលឡើងមិនរួចក៏ត្រឡប់ចុះមកវិញ ឯបន្ទាក៏កោងក្នុកឡើងលើ លុះចុះមកដល់ដី ត្រូវពួកឆ្កែធំ ៗ មាឌប៉ុនដំរីសារ ដេញត្របាក់ខាំពួកនិរយបាល ក៏នាំគ្នាចាក់ដោយលំពែងឲ្យឡើងទៅលើទៀត លុះដល់ចុងរកាមានក្អែក ត្មាត ធំ ៗ ចឹកក្បាលដោយចំពុះដែក ។ សត្វនរក ត្រូវនិរយបាលដេញឲ្យឡើងចុះ ៗ ឥតមានស្រាកស្រាន្តឡើយ ។

បាបកម្មទាំងនេះ ព្រោះកាលនៅជាមនុស្ស ប្រព្រឹត្តកាមេសុមិច្ឆាចារ និងជាស្ត្រីកាឡកណ្ណី ផិតក្បត់ស្វាមី ។ ល ។

**ច~អសិបត្តនរក** = នរកស្លឹកដាវ

នរកនេះ ពោរពេញដោយដើមឈើធំ ៗ មានមែកត្រសុំត្រសាយ ដូចសួនច្បារ មើលទៅគួរជាទីមនោរម្យ

សត្វនរក ដែលរត់រួច ក្រឡេកឃើញហើយ ក៏នាំគ្នារត់ប្រញាប់ប្រញាល់ ចូលទៅអង្គុយក្រោមដើមឈើទាំងនោះ ដោយគិតថា បានក្សាន្តសប្បាយ បន្ទាប់មក ស្រាប់តែមានខ្យល់បក់បោកយ៉ាងខ្លាំង បណ្តាលឲ្យស្លឹកឈើទាំងនោះធ្លាក់ចុះមក ក្លាយជាអាវុធ មានដាវ លំពែងជាដើម ដែលមានមុខមុតស្រួច ប៉ះដាច់ក្បាល ត្រចៀក ច្រមុះ និងអវយវៈផ្សេង ៗ ទៀត ។ល។

បាបកម្មទាំងនេះ បានដល់បុគ្គលដែលតាំងខ្លួនជាអ្នកលេង កាប់ចាក់ សម្លាប់គ្នា ដោយអាវុធយុទ្ធភណ្ឌ ។

**៦~ខារោទកនរក** = នរកទឹកស្ទឹងទន់ដែង

នរកនេះ ជាស្ទឹងទឹកទន់ដែង ឆេះជាអណ្តាតភ្លើងសម្រាប់ប្រកមាត់សត្វនរក ហៅថា ( វេតរណីនរក ) ក៏បាន ព្រោះនរកនេះ សម្បូរដោយដើមផ្តៅ មានបន្លាដែកស្រួចដូចលំពែង ឆេះដោយអណ្តាតភ្លើង មុតដូចកាំបិតកោរ កាត់សត្វនរកដាច់ជាកំណាត់ ៗ សត្វនរកពេលរួចចាកពីបន្លាផ្តៅចុះទៅក្រោម ក៏ត្រូវចម្រូងដែកគៀបត្បៀត ហើយឆេះឡើង

លុះរួចពីចម្រូងដែក ក៏ត្រូវស្ទឹកឈូកដែកមុតឆេះ ជាអណ្ដាតភ្លើង លុះផុតពីស្ទឹកឈូក ត្រូវធ្លាក់ក្នុងទឹកបន្សា ៗ ឆេះស្រោបខ្លួន ក៏នាំគ្នាវត់មុជចុះទៅខាង ដោយស្មានថា បានសុខស្រួល តែបែរជាត្រូវទឹកក្រុតកាត់ដាច់រាងកាយ ជាកំណាត់តូចធំ យំរងំ ហែលទៅមក ក៏ត្រូវនាយនិរយបាលនៅមាត់ច្រាំង ចាក់ដោយលំពែង ដែកស្រួច ស្ទូ រួចយកសន្ទូចដែកដ៏ធំ ថ្កក់ទាញ អូសមកផ្តេកលើផ្ទាំងដែក ដែលកំពុងឆេះក្រហមឆ្អៅ ក្តៅមហិមា រួចឲ្យសត្វនរកហាមាត់យកដុំដែក និងទឹកទង់ដែង មកបញ្ចូកចូលក្នុងមាត់ ។ ល ។

បាបកម្មទាំងនេះ ព្រោះកាលមានអត្តភាពជាមនុស្សរកស៊ី ធបោក សម្លាប់សត្វ ( អណ្តើក ហ៊ីង ខ្ចៅ ខ្ចង ) ដោយបោះទៅក្នុងទឹកក្តៅទាំងរស់ ផឹកសុរា សេពគ្រឿងញៀន បៀតបៀនអ្នកមានកម្លាំងខ្សោយ ។ ល ។

## នរក ១៥ វេណ្ដៅ ( ក្នុងនេមិរាជជាតក )

**ក~ទេតរណីនរក** *( ដូចខាពេទកនរក )*

**ខ~សុនខនរក** = នរកសុនខ

នរកនេះ សម្បូរដោយឆ្កែមាឌធំ ៗ ប៉ុន ៗ ដ៏រសារ សម្បុរក្រហមខ្លះ ពពាលខ្លះ និងហ្វូងត្មាត ត្រដក់ ធំ ៗ ប៉ុន ៗ រទេះ ចំពុះសុទ្ធតែដែក គួរខ្លាចយ៉ាងក្រៃលែង ។ ពួកឆ្កែដេញខាំសត្វនរក ឲ្យដួលលើដែកក្រហម ហើយយក ជើងមុខទាំងពីរ ជាន់ពីលើដើមទ្រូងសត្វនរក ស៊ីជាច់អស់ នៅសល់តែឆ្អឹង រួចសត្វត្មាត ត្រដក់មកចឹកស៊ីថែមទៀត ។

បាបកម្មទាំងនេះ ព្រោះកាលកើតជាមនុស្សកំណាញ់ ហើយ ហាមឃាត់អ្នកដទៃមិនឲ្យធ្វើទាន ជេរស្តី បៀតបៀន គំរោះគំរាម សមណព្រាហ្មណ៍ អ្នកមានសីល ។ ល ។

**គ~អយបថវីនរក** = នរកផែនដីដែកក្រហម

នរកនេះ មានផែនដីដែកក្រហម ទំហំ ៩ យោជន៍ នាយនិរយបាល ដេញវាយសំពងសត្វនរក ដោយអន្ទង់ ដែកក្រហមប៉ុន ៗ ដើមត្នោត ឲ្យដួលចុះស្រប៉ាប រួចយក ញញួរដែក ដំកម្ទេចឲ្យល្អិតម៉ដ្ឋឈឹង ។

បាបកម្មទាំងនេះ គឺជនអ្នកមានចិត្តអាក្រក់ បៀតបៀនជេរស្តីបន្ទោស ជនអ្នកគ្មានកំហុស ។ ល ។

**ឃ~អង្គារកាសុនរក** = នរករងើកភ្លើង

សត្វនរកនេះ ត្រូវនាយនិរយបាល ដេញវាយដោយញញួរដែកក្រហមក្តៅ ឲ្យចុះក្នុងរណ្តៅរងើកភ្លើងត្រឹមចង្កេះរួចហើយយកកន្ទ្រងដែកធំៗ ដួសរងើកភ្លើង ចាក់ស្រោចគរលើក្បាលថែមទៀត ។

បាបកម្មទាំងនេះ បានដល់ឃោសកជន ដែលមានគំនិតអាក្រក់ ក្លែងបោកប្រាស់ ដើររៃអង្គាសបច្ច័យទាយកយកមកបរិភោគផ្ទាល់ខ្លួន ហើយឃោសនាថា យកមកកសាងវត្ថុ ឬបូជាព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃជាដើម ។

**ង~លោហកុម្ភីនរក** = នរកខ្ទះទង់ដែង (សំដែងហើយ)

**ច~អយោធននរក** = នរកទឹកដែកក្រហម

ពួកនិរយបាល យកខ្សែដែក ដែលឆេះជាអណ្តាតភ្លើងក្រហម មកចងកសត្វនរក ហើយមួលឲ្យដាច់ បោះទៅក្នុងទឹកក្តៅ សត្វនរកនោះ ក៏កើតឡើងទៀត នាយនិរយបាល

ក៏យកខ្សែដែកដូចមុន មកចងកហើយមួលឲ្យដាច់ទៀត ។ ដាច់ហើយកើត ៗ រហូតដល់អស់បាបកម្ម ។

បាបកម្មទាំងនេះ ព្រោះកាលមានអត្តភាពជាមនុស្ស មាន ចិត្តអាក្រក់បៀតបៀន និងសម្លាប់សត្វស្លាបទាំងឡាយ ដោយមួលក ។ ល ។

**ឆ~ថុសនរក** = នរកអង្កាម

នរកនេះ ជាស្ទឹង មានទឹកថ្លាពេញព្រៀប ពេលសត្វនរកក្តៅក្រហល់ក្រហាយ ព្រោះរស់នៅលើផែនដែកក្រហម ក៏ស្ទុះលោតចុះ ទៅដោយគិតស្មានថា ផឹកងូតឲ្យសប្បាយ លុះផឹកចូលទៅក្នុងពោះហើយ ក៏ក្លាយជាអង្កាមក្តៅ ឆេះដាច់ពោះវៀន ជាកំណាត់ ៗ ។ ល ។

បាបកម្ម ដែលនាំឲ្យធ្លាក់នរកនេះ ព្រោះយកស្រូវស្កក ឬអង្កាមប្រកបារ៍ ការុង ក្លែងធ្វើជាស្រូវល្អ លក់ដូរ ។ ល ។

**ជ~អយសូលនរក** = នរកចម្រូងដែក

នាយនិរយបាល ចាក់ធ្លុងជំនីរទាំងសងខាង របស់សត្វនរក ដោយអាវុធផ្សេង ៗ មានចម្រូងដែកជាដើម ។

បាបកម្មនាំឲ្យធ្លាក់នរកនេះ បានដល់មនុស្ស ដែលប្រព្រឹត្តអំពើអាក្រក់ ក្នុងជីវលោកនេះ មានការចិញ្ចឹមជីវិតដោយលួចស្រូវ អង្ករ គោ ក្របី មាស ប្រាក់ របស់អ្នកដទៃជាដើម ។

**ឈ~សញ្ជោវតិនរក** = នរកអាវុធដែកក្រហម

ពួកនិរយបាល ចាប់សត្វនរកចងក ដោយខ្សែដែកយ៉ាងធំ ដែលឆេះដោយអណ្តាតភ្លើងសន្ធោសន្ធៅ លុះសត្វនរកដួលស្របាបហើយ ក៏វាយដោយអាវុធផ្សេង ៗ ទៀត ។ល។

បាបកម្មទាំងនេះ ព្រោះកាលកើតជាមនុស្ស សម្លាប់គោ ក្របី ចៀម ពពែ ជ្រូក យកសាច់លក់ចិញ្ចឹមជីវិត ។ល។

**ញ~គូថនរក** ( សំដែងហើយខាងលើ )

**ដ~លោហិតបុព្វនរក** = នរកឈាម និងខ្ទុះ

នរកនេះ ពោរពេញដោយឈាម និងខ្ទុះ ស្អោកគ្រោក រកអ្វីប្រៀបមិនបាន សត្វនរកនេះ ស៊ីតែឈាម និងខ្ទុះដោយសេចក្ដីស្រេកឃ្លានយ៉ាងក្រៃលែង ។

បាបកម្ម បានដល់មនុស្ស អ្នកធ្លាប់សម្លាប់មាតាបិតា ព្រះអរហន្ត និងព្រះសង្ឃសាវ័ក ។

**៥~គូដគារីនរក** = នរកមនុស្សកោង

ពួកនិរយបាល យកសន្ទូចដែកធំ ៗ ប៉ុនដើមត្នោតការវថ្កក់សត្វនរកនេះ សន្ទឹងទុកលើផ្ទាំងដែកក្រហម ដូចគេបោះ ទាញសន្ទឹងស្បែក លើផែនដី ។

បាបកម្មទាំងនេះ ព្រោះកាលកើតជាមនុស្ស រកស៊ីលក់ដូរ ដំឡើងថ្លៃទំនិញហួសហេតុ ព្រោះចង់បានចំណេញច្រើន ដោយប្រើពាក្យសំដីពីរោះ ផ្អែមល្ហែម ដើម្បីលាក់លៀមអំពើកោងរបស់ខ្លួន ដូចព្រានប្រមាញ់ពួនលាក់ខ្លួន ពួនស្ទាក់ចាំបាញ់សត្វព្រៃ ។

**៦~អយបព្វតនរក** = នរកភ្នំដែក

មានព្រះគាថាសំដែងបញ្ជាក់ថា ស្ត្រីពួកនេះ មានរាងកាយធាត់ធំ ប៉ុន ៗ ភ្នំ ពេលនាយនិរយបាលដេញឲ្យចុះក្នុងផែនដែកក្រហម ត្រឹមចង្កេះ រើខ្លួនពុំរួច ដូចគេឃុំឃាំងគោក្នុងក្រោលសម្រាប់សម្លាប់ ពេលនោះ មានភ្នំដែកឆេះជាអណ្តាតភ្លើង រមៀលចេញមកពីទិសទាំង ៤ កិនសង្កត់ស្រីទាំងនោះ ឲ្យម៉ដ្ឋផង់ដូចម្សៅ ។

បាបកម្មទាំងនេះ បានដល់ស្ត្រី ដែលមានការស្រើបស្រាល ត្រេកត្រអាលក្នុងកាម ប្រាថ្នាសប្បាយហើយប្រព្រឹត្តកន្លងចិត្តស្វាមីរបស់ខ្លួន ។

**៣៤~ជលិតអង្គារនរក** = នរករណ្តៅរងើកភ្លើង

នរកនេះ មានរណ្តៅរងើកភ្លើងធំ ៗ នាយនិរយបាលដេញសត្វនរកទាំងហ្វូង ៗ ដូចគោ ក្របី ចាប់យួរជើងឡើងលើ ក្បាលចុះក្រោម ហើយបោះចូលក្នុងរណ្តៅរងើកភ្លើងនោះ ។

បាបកម្ម ដែលនាំឲ្យសត្វកើតក្នុងនរកនេះ ព្រោះការប្រព្រឹត្តមិច្ឆាចារៈ កន្លងប្រពៃណីនឹងកិរិយាអ្នកដទៃ ។

**ឍ-មិច្ឆាទិដ្ឋិកនរក** = នរកអ្នកមិច្ឆាទិដ្ឋិ

សត្វនរកពួកនេះ  សុទ្ធតែជាអ្នកមានគំនិតយល់ខុស ដោយខ្លួនឯងផង  និងដឹកនាំអ្នកដទៃឲ្យយល់ខុសផងថា " ការឲ្យទាន មិនមានផល, ការបូជាធំ តូច ការធ្វើល្អ អាក្រក់ មិនមានផល , មាតាបិតា មិនមានគុណ , សត្វជាឧបបាតិកកំណើត មិនមាន , លោកនេះ លោកខាងមុខ មិនមាន ។

បាបកម្មទាំងនេះ មកអំពីបុគ្គលក្នុងលោកនេះ មានគំនិតយល់ខុសដោយខ្លួនឯងខ្លះ ដឹកនាំអ្នកដទៃឲ្យយល់ខុសខ្លះ លុះស្លាប់ទៅកើតក្នុងនរកនេះ មានទុក្ខទោសវេទនាយ៉ាងខ្លាំង ក្តៅក្រហល់ក្រហាយ ខ្លោចផ្សា ជាអនេកអនន្តក្រៃលែង ។

## នរក ៨ រណ្តៅ ( ក្នុងសង្កិច្ចជាតក )

**ក-សញ្ជីវនរក** = នរករស់ឯង

ពួកនិរយបាល កាប់ចិញ្ច្រាំសត្វនរកទាំងនោះ ជាកំណាត់តូច ៗ ដោយសស្ត្រាផ្សេង ៗ ជាវិការៈនៃអណ្តាតភ្លើង ពេលស្លាប់ហើយ មានខ្យល់ត្រជាក់ផាត់បក់មកត្រូវក៏រស់ឡើងវិញរឿយ ៗ ពេលខ្លះត្រូវកាប់ចាក់សម្លាប់គ្នាឯង ដោយដៃ ដែលបាបកម្មផ្តល់ឲ្យក្លាយជាដាវ លំពែងកាំបិត ពូថៅ បណ្តាលឲ្យស្លាប់កើត ៗ រងទុក្ខវេទនា ដរាបដល់អស់បាបកម្ម ឬអស់អាយុដែលកំណត់ ៥០០ ឆ្នាំនរកស្មើនឹងអាយុទេវតា ឋានចាតុម្មហារាជិកា ។

**ខ~កាឡសុត្តនរក** = នរកខ្សែបន្ទាត់ដែក

នាយនិរយបាល ដេញប៉ះផាប់ចាប់ពកឹង សត្វនរកទៅមក ៗ លើផែនដីដែកក្រហម ឥតពេលស្រាក លុះដេញទាន់ហើយ ប្រហារឲ្យដួលស្រប៉ាប់លើដែកក្រហម រួចយកខ្សែបន្ទាត់ដែក ផ្ទាត់ចុះតាមរាងកាយ ពីមុខធ្លាយទៅក្រោយ ពីក្រោយធ្លាយមកមុខ ពីស្តាំធ្លាយទៅឆ្វេង ពីឆ្វេងធ្លាយមកស្តាំ ។

ពេលសត្វនរកនោះ ស្លាប់ហើយរស់វិញ ដឹងខ្លួនភ័យខ្លាច ក៏រត់ទៅតាមផែនដែកក្រហម ភ្លើងក៏ឆេះគ្រប់ជំហាន អស់កម្លាំងដួលស្រូស ត្រូវភ្លើងឆេះ និងត្រូវពួកនិរយបាលធ្វើទណ្ឌកម្ម រហូតដល់អស់បាបកម្ម ។ នរកនេះមានកំណត់អាយុ ១,០០០ ឆ្នាំ ស្មើនឹងអាយុទេវតាឋានតាវត្តឹសា ។

**គ-សង្ឃាតនរក** = នរកសង្កត់ ឬកម្ទេច ឬទង្គិច

នរកនេះ មានភ្នំដែកធំ ៗ អណ្តាតភ្លើងឆេះជានិរន្តន៍ នាយនិរយបាល ចាប់សត្វនរកបោះទៅក្នុងផែនដែក ដែលកំពុងឆេះសន្ធោសន្ធៅ កម្រាស់ ៩ យោជន៍ ដល់ត្រឹមចង្កេះ ភ្នំដែកទាំងនោះ ក៏រមៀលពីទិសខាងកើតទៅខាងលិច ពីខាងលិចមកខាងកើត ជួនកាលភ្នំទាំងពីរនោះ ទង្គិចគ្នាកិនកម្ទេចសត្វនរក ឲ្យរងទុក្ខវេទនាយ៉ាងក្រៃលែង ។ នរកនេះមានកំណត់អាយុ ២,០០០ ឆ្នាំ ស្មើនឹងអាយុទេវតាឋានយាមា ។

**ឃ~ធូមរោរុវៈ ឬរោរុវៈ ឬចូឡរោរុវនរក** = នរកយំដោយផ្សែងភ្លើង

នរកនេះ មានផ្សែងភ្លើងហុយទ្រលោម ស្រោបខ្លួនសត្វនរកជានិច្ច ហើយស្រូបចូលតាមទ្វារទាំង ៩ ផ្សែងនោះក្តៅផ្សាជាអតិបរមា សត្វនរកយំយែក ស្រែកទ្រួញ សោយសោក យ៉ាងខ្លាំង ។ នរកនេះ មានកំណត់អាយុ ៤,០០០ ឆ្នាំ ស្មើនឹងទេវតាឋានតុសិតា ។

**ង~ជាលរោរុវៈ ឬមហារោរុវនរក** = នរកយំដោយអណ្តាតភ្លើង

នរកនេះ មានអណ្តាតភ្លើង ស្រូបចូលតាមទ្វារទាំង ៩ នៃសត្វនរក ហើយដុតកម្តៅរាងកាយ ឲ្យក្តៅក្រហល់ក្រហាយយ៉ាងក្រៃលែង សត្វនរក នាំគ្នាយំរងំរងួយ គ្រប់វិនាទី ។ នរកនេះ មានកំណត់អាយុ ៨,០០០ ឆ្នាំ ស្មើនឹងអាយុទេវតាឋាននិម្មានរតី ។

**ច~តាបនៈ ឬចូឡតាបននរក** = នរកធ្វើឲ្យក្តៅ

ពួកនាយនិរយបាល យកតង្កៀបប៉ុនដើមត្នោត ដែលជាអណ្ដាតភ្លើង មកថ្កៀបសត្វនរកទាំងនោះ មិនឲ្យរាកខ្លួនរួច ឯផ្នែកខាងក្រោម ក៏ជាផែនដីមានអណ្ដាតភ្លើង ឆេះពួកសត្វនរកទាំងនោះ ឥតឈប់ដែរ ។ នរកនេះ មានកំណត់អាយុ ៨,០០០ ឆ្នាំ ស្មើនឹងអាយុទេវតា ឋានបរនិម្មិតវសវត្តី ។

**ឆ-បតាបនៈ ឬមហាតាបននរក** = នរកធ្វើឲ្យក្ដៅទូទៅ

ពួកនាយនិរយបាល ដេញវាយប្រហារសត្វនរកដោយអាវុធដែលឆេះជាអណ្ដាតភ្លើង ឲ្យឡើងលើភ្នំភ្លើងដល់ហើយ មានខ្យល់ព្យុះជំផាត់ឲ្យធ្លាក់ចុះមក ត្រូវចុងដែកស្រួចខាងក្រោម មុតខាងក្រោមទៀត ។ នរកនេះមានកំណត់អាយុ កន្លះអន្តរកប្ប ស្មើនឹងអាយុព្រហ្មជាន់បរិសជ្ជា។

**ជ-មហាអវិចីនរក** = នរកធំមិនមានចន្លោះ មិនទំនេរ

នរកនេះ មានអណ្ដាតភ្លើងឆ្វាយចេញពីទិសទាំង ៤ ផ្សាយទៅ ១០០ យោជន៍ ជានិរន្តរ៍គ្មានលស់ពេលវេលា ឯខាងក្នុង មានទំហំរាប់យោជន៍ គ្មានទំនេរដោយសត្វនរក ៗ

នៅប្រជ្រៀតគ្នា កុះករ កកកុញ ស្អេកស្កះ ដូចដង្កូវក្នុងបង្គន់ ។ មហាអវិចីនរកនេះ វាស់កណ្តាលបាត ៣១៨ យោជន៍ ។ នរកនេះ មានកំណត់អាយុ ១ អន្តរកប្ប [១] ។ ( ច្បាប់ខ្លះ សម្តែងថា មានអាយុ ១ បទុម គឺមានលេខមួយ ហើយថែមសូន្យ ១១៩ ទៀត ) ។

**បាបកម្មដែលនាំឱ្យធ្លាក់នរកធំទាំង ៨ ក្តី ធ្លាក់នរកជាបរិវារនៃនរកធំទាំង ៨ នេះក្តី មានសម្តែងលាយឡំគ្នា ដូចតទៅ ៖**

- ជាបុគ្គលប្រទូសរ៉ាយព្រះឥសី មានសីលបរិសុទ្ធ ត្រូវធ្លាក់នរកធំ អស់កាលយូរឆ្នាំរាប់ពុំបាន ។
- ព្រះរាជា ឬមេដឹកនាំប្រទេស ដែលខ្វះយុត្តិធម៌ ធ្វើឲ្យប្រជាជន កើតចលាចលក្តៅក្រហាយ ត្រូវធ្លាក់ទៅសោយទុក្ខវេទនាក្នុង**តាបននរក** មានភ្លើងឆេះចេញពីសព៌ាង្គកាយគ្មានពេលស្រាក ។

---

**១ អនុដីកាវិភង្គ ។**

- អ្នកសម្លាប់បិតា ត្រូវធ្លាក់ទៅក្នុង**សុត្តនរកខ្លះ លោហ-កុម្ភីនរកខ្លះ** ។ ពួកនាយនិរយបាល ចាក់បុករុករាងកាយដោយលំពែង ចាក់ឲ្យខ្វាក់ភ្នែកខ្លះ , ឲ្យផឹកស៊ីមូត្រលាមកខ្លះ , ឲ្យស៊ីដុំដែកភ្លើងក្រហមខ្លះ , ពួកសុនខ ក្អែក ត្មាតហែកស៊ីខ្លះ , បោះចូលទៅក្នុងទឹកផ្សាក្តៅខ្លាំងខ្លះ ។ ល ។

- អ្នកសម្លាប់មាតា ត្រូវធ្លាក់ទៅសោយទុក្ខក្នុងនរកទាំងពីរ ( ដូចអ្នកសម្លាប់បិតាដែរ ) ។ ពួកនិរយបាល ក្ឈូរដោយផាលដែកក្រហមខ្លះ , ត្រាំក្នុងទឹកមូត្រ លាមកខ្លះ , ដង្កូវធំមានមាត់ជាដែកចោះរាងកាយខ្លះ , ធ្លាក់ចុះក្នុងទឹកឈាមនិងខ្ទុះ ជម្រៅរាប់រយយោជន៍ខ្លះ ។ ល ។

- ស្ត្រីទម្លាក់គភ៌ ( ពន្លូតកូន ) ទៅកើតក្នុង**វេតរណីនរក** ដែលពោរពេញដោយបន្លាក្តៅដ៏មុត ។

- បុរសប្រព្រឹត្តក្នុងកាមេក្តី , ស្ត្រីដែលផិតក្បត់ស្វាមីក្តី លុះស្លាប់ទៅកើតក្នុង**សិម្ពលីនរក** ដែលពេញដោយដើមរកា

ដែក ។ល។ លុះរួចពី**សិម្ពលីនរក** ក៏ធ្លាក់ទៅ**លោហកុម្ភីនរក** ដែលពេញព្រៀប ដោយទឹកទង់ដែងទៀត ។

## ឧស្សទនរក មាន ៥ រណ្តៅ

**គូថនរក** ១ **កុក្កុឡនរក** ១ **សិម្ពលីនរក** ១ **អសិបត្តនរក** និង**វេតរណីនរក** ១ ។

មហានរកទាំង ៨ នេះ មហានរកនីមួយ ៗ មាន **ឧស្សទនរក** ១៦ ជាបរិវារ រាប់តាមទិស ៤ ៗ x ៤ = ១៦ , ១៦ x ៨ = ១២៨ រណ្តៅតូច ៗ ហៅថា **ចូឡនរក**ក៏បាន បើរាប់តាមទិស ៨ មហានរកមួយ ៗ មាន**ឧស្សទនរក** ៣២ , ៣២ x ៨ = ២៥៦ រណ្តៅតូច ។ **ឧស្សទនរក** ៥ នេះ **អសិបត្តនរក** និង**វេតរណីនរក** រាប់បញ្ចូលគ្នាតែ ១ ដូច្នេះ **ឧស្សទនរក** រាប់បានតែ ៤ រណ្តៅ ប៉ុណ្ណោះ ។ **ឧស្សទនរក** **ប្រែថា** មានច្រើន គឺសេចក្តីទុក្ខលំបាកផ្សេង ៗ មានច្រើន ក្នុងនិរយភូមិនេះ ។ មហានរក ៨ រណ្តៅ តាំងនៅខាង

ក្រោម ជាប់នឹងមនុស្សលោក ផុយគ្នាពីជម្ពូទ្វីប មានកម្រាស់ ២៤០,០០០ យោជន៍ នៅជាន់លើពាក់កណ្ដាលផែនដី ធម្មតាហៅថា " **បំសុបឋវី** " មានកម្រាស់ ១២០,០០០ យោជន៍ នៅខាងក្រោមពាក់កណ្ដាល ជាថ្មហៅ " **សិលាបឋវី** " មានកម្រាស់ ១២០,០០០ យោជន៍ដែរ ។

មហានរកនេះ តាំងនៅក្នុងដីធម្មតា រណ្ដៅនីមួយ ៗ ចាប់ពីជម្ពូទ្វីបទៅ ឃ្លាតឆ្ងាយឃ្លាតពីគ្នា ១៥,០០០ យោជន៍ដូចៗ គ្នា ៖

ពី**ជម្ពូទ្វីប** ទៅ**សញ្ជីវនរក**

ពី**សញ្ជីវនរក** ទៅ**កាឡសុត្តនរក**

ពី**កាឡសុត្តនរក** ទៅ**សង្ឃាតនរក**

ពី**សង្ឃាតនរក** ទៅ**រោរុវនរក**

ពី**រោរុវនរក** ទៅ**មហារោរុវនរក**

ពី**មហារោរុវនរក** ទៅ**តាបននរក**

*ពី* **តាបននរក** *ទៅ* **មហាតាបននរក**

*ពី* **មហាតាបននរក** *ទៅ* **អវិចីនរក**

*មហានរកនេះ ជាឧមង្គទៅក្រោមដី ។ ផែនដីមាន កម្រាស់ ២៤០,០០០ យោជន៍នេះ តាំងនៅលើជុំទឹកកក ៤៨០,០០០ យោជន៍ , ជុំទឹកកកដ៏រឹង តាំងនៅលើខ្យល់ កម្រាស់ ៩៦០,០០០ យោជន៍ ។*

*( ១ យោជន៍ ស្មើនឹង ១៣ ម៉ៃល៍ ឬ ២០ គីឡូម៉ែត្រ )*

*បន្ទាប់ពីខ្យល់នេះទៅ ជាអាកាសទទេ ហៅថា* **ហេដ្ឋិម-អជ្ជាកាស** *( អាកាសជាន់ក្រោម ) ឯអាកាសដែលតាំង នៅខាងលើ ចាប់តាំងពីនេវសញ្ញានាសញ្ញាយតនព្រហ្ម ឡើងទៅ ហៅថា* **ឧបរិអជ្ជាកាស** *( អាកាសខាងលើ ) ។*

**<u>កថាពោលពីនរក ចប់ ដោយសង្ខេបប៉ុណ្ណោះ ។</u>**

# ២. ប្រេត

ពាក្យថា **ប្រេត** ជាភាសាសំស្ក្រឹត អានថា **បេតៈ ប្រែថា** ប្រេត មានច្រើនពួកណាស់ ប្រេតខ្លះមានឫទ្ធិអំណាចបណ្ដាលឲ្យឃើញវត្ថុជាឥដ្ឋារម្មណ៍ ឬអនិដ្ឋារម្មណ៍ខ្លះ ពេលយប់ជាទេវតា សោយសុខសម្បត្តិក្នុងវិមាន ពេលថ្ងៃសោយទុក្ខវេទនាយ៉ាងខ្លោចផ្សា ។ល។

តែនៅទីនេះ ខ្ញុំព្រះករុណាសូមលើកយកតែប្រេត ១២ ពួក , ប្រេត ២១ ពួក , និងប្រេត ៤ ពួក មកសម្ដែងដូចតទៅនេះ ៖

## ប្រេត ១២ ពួក សម្ដែងក្នុងលក្ខណសូត្រ ៖

**ក~វន្តាសប្រេត** = ប្រេតស៊ីទឹកមាត់ស្ដោះ កម្អួត

ប្រេតនេះ មានមុខក្រញូវ ភ្នែកគ្រលួង សក់រួញរីងក្រញង់ មាត់វៀច ស្មងកោងកំពូរ ពោះកំប៉ោង ដៃជើងក្រញាង ធ្មេញដុះខុសជួរ សរសៃវាមដូចពួរព័ទ្ធកាយស្គមខ្ពស់ជង្គ្រោង ជាំពេញខ្លួន ក្លិនខ្មោះខ្មូរ ស៊ីតែកំហាក

ស្ទេស្ទ កម្អួត ស្លាប់កើតៗ រាប់លានឆ្នាំ ។ ច្រើនរស់នៅក្បែរផ្ទះក្បៀនកោះ ដើរឈ្លោករកកន្ទោរ ស្តាប់មនុស្សខាកស្តោះ ព្រោះសេចក្តីស្រេកឃ្លានខ្លាំង ។

បាបកម្មទាំងនេះ ព្រោះកាលកើតជាមនុស្ស មិនមានសទ្ធាជ្រះថ្លា ឲ្យទានដោយខ្នះខ្នាយ ស្មោកគ្រោក ប្រគេនចង្ហាន់ព្រះសង្ឃមិនបានផ្ចិតផ្ចង់ ធ្វើដោយអំណាចចិត្តប្រ-ណែន ពង្រាយសំរាមក្នុងបូជនីយដ្ឋាន ។

**ខ~កុណបខាទប្រេត** = ប្រេតស៊ីសាកសពមនុស្ស សត្វ

ប្រេតនេះ ពោះយារស្តោក មុខខ្ទីកំប៉ុក ភ្នែកជំប៉ុនគងចង្កាយារ ធ្មេញប៉ុនចបកាប់ សក់វែងអូសដី ប្រមុះខើចកត្តូចដូចកដប ក្បាលធំទើងមើង ក្លិនស្អុយអសោចិ៍ ស៊ីសពខ្មោច និងខ្ទុះឈាម រាប់កោដិឆ្នាំ ។

បាបកម្មទាំងនេះ ព្រោះកាលកើតជាមនុស្ស ខិលខូចប្រព្រឹត្តអបាយមុខ មិនគោរពត្រកូលរៀមច្បង កុហកបញ្ឆោតអ្នកបួស ឲ្យបរិភោគសាច់ដែលខុសព្រះវិន័យ ។

**គ~គូថខាទកប្រេត** = ប្រេតស៊ីលាមក

ប្រេតនេះ ភ្នែកវិលទទឹង ដុះរោមជិត មាត់ស្មេញប្រមុះត្រង់ភ្លឹង កន្ទីដូចហ៊ីង ក្បាលធំគ្រមាំង កណ្ដាលរលីងខាង ៗ ដុះរ៉ូយ ៗ ពោះកំប៉ោង ត្រចៀកកំប៉ិត ស្គមកំព្រឹងសាច់ស្បែក សោះកក្រោះ ដៃជើងធំស្មូក ក្លិនស្អុយខ្មោះដើរស្វែងរកគំនរលាមក បង្គន់ ឬផ្ទះអ្នកស្រុក ហើយស៊ីដោយការស្រេកឃ្លានខ្លាំង សោយទុក្ខវេទនា រស់នៅដោយកម្លាំងកម្មពៀរ វេទនារាប់កោដិឆ្នាំ ។

បាបកម្មទាំងនេះ ព្រោះពីជាតិមុន ជាជនពាលមិនទំនុកបម្រុងមាតាបិតា ជីដូនជីតា បង្ខិតបង្ខំអ្នកបួសដោយអំណាច ឲ្យស៊ីលាមកឈ្លូស គោ ក្របីជាដើម ។ លុះស្លាប់ទៅកើតក្នុងនរកខ្ទះដែក សល់ផលកម្មទើបមកកើតជាគូថខាទកប្រេតនោះឯង ។

**ឃ-អគ្គិជាលមុខប្រេត** = ប្រេតមានអណ្ដាតភ្លើងឆេះមាត់

ប្រេតនេះ មានភ្នែកហើមលៀនទុល ស្បែករលាត់ពុរពង ភ្លើងឆេះក្នុងខ្លួន មានអណ្ដាតភ្លើងចេញតាមមាត់

ទាំងយប់ទាំងថ្ងៃ រស់នៅតាមដងព្រៃជ្រៅ ញកភ្នំ មាត់សមុទ្រ លើដុំថ្ម ឬកោះ ។

បាបកម្មទាំងនេះ ព្រោះកាលមានអត្តភាពជាមនុស្ស ៗ ប៉ៅឡែ លួកលលេងនឹងអ្នកមានសីល ដើម្បីសើចសប្បាយ មានបញ្ឆោតព្រះសង្ឃ ឲ្យចាប់ដែកក្ដៅជាដើម ។

**ខ~សុចិមុខប្រេត** = ប្រេតមានមាត់ប៉ុនក្ដិតម្ជុល

ប្រេតនេះ មានមាត់ស្រួចតូចដូចក្ដិតម្ជុល មានមាឌធំខ្ពស់ ដៃជើងធំ ៗ មើលឃើញដូចភ្នំ ក្រចកដៃដុះវែងក្រាស់ខុប ស្រែងស៊ីសុះ សាច់ពកដុំ ៗ ប៉ុនថ្មដា សក់ក្បាលពុកមាត់ ពុកចង្កា ដុះទ្រុបទ្រុលដូចមែកឈើ ។ ច្រើនរស់នៅតាមញកភ្នំ ព្រៃជ្រៅឆ្ងាយដាច់ស្រយាល ស្រេកឃ្លានខ្លាំងណាស់ ញាត់បាយ ចាក់ទឹកមិនចូល ។

បាបកម្មទាំងនេះ ព្រោះកាលកើតជាមនុស្សកំណាញ់ស្វិត លោភលន់ មិនធ្វើបុណ្យទានតិចតួច សូម្បីមាតាបិតាក៏ឥតបានចិញ្ចឹមដែរ ។ ល ។

**ច~តណ្ហិ ឬតណ្ហជ្ជិតប្រេត** = ប្រេតត្រូវតណ្ហាបៀត-បៀន ( ស្រេកឃ្លានជានិច្ច )

ប្រេតនេះ មានរូបរាងធំខ្ពស់ ដៃជើងធំ ៗ ប្រវែង ប្រវាងដូចយក្ស កវែង ក្បាលក្រៀង ភ្នែកស្រលៀងធំ ទុលម្វាង ប្រមុះខ្វី ដុះរោមសព្វខ្លួនដូចស្មៅ បបូរមាត់ស្តែះ ពោះប៉ោង សាច់ស្បែក ស្ពោតសាញដុះស្ដែ ។ ស្រេកឃ្លាន ខ្លាំងណាស់ ពេលឃើញទឹក ឬចំណី លុះដើរទៅជិតក្លាយ ជាដុំថ្ម ក្រួស សុទ្ធតែជាទីកើតនៃភ្លើង ។

បាបកម្មនេះ ព្រោះពីជាតិមុន ជាមនុស្សទុរជន មិន ស្គាល់បុណ្យបាប ដឹកគោ ក្របី ជ្រូក បញ្ចូលក្នុងវត្ត ឲ្យ ស៊ីដំណាំ ដុះនោមដាក់ស្រះទឹក ពេលព្រះសង្ឃហាមឃាត់ តមាត់ហើយចងគំនុំផង ។

**ឆ~និជ្ឈា ឬសុនិជ្ឈាមកប្រេត** = ប្រេតមានដងខ្លួនខ្មៅ ដូចដង្គត់ឈើ ភ្លើងឆេះជានិច្ច ។

ប្រេតនេះ មានរូបរាងអាក្រក់ក្រៃលែង ខ្មៅក្រិត កន្ទុយ ដុះចេញពីមាត់ ពោះប៉ោងស្មុល ផ្ចិតលៀន ប្រមុះកញ្ចួត

មុខដុះរោម ម្រាមដៃជើងដុះជាប់គ្នាគ្មានចន្លោះ បបូរមាត់វាង ជ្រុងសំយុងធ្លាក់មកគ្របចង្កា ត្រចៀកយារបាក់ដល់ស្មា សក់វែងមានក្លិនស្អុយ ច្រើនរស់នៅក្នុងព្រៃជ្រៅ ឆ្ងាយដាច់ស្រយាល ឬលើកោះ ។

បាបកម្មនេះ ព្រោះពីជាតិមុនឃើញសមណព្រាហ្មណ៍ អ្នកមានសីល ស្មូមយាចក ជនពិការ ជេរស្តី ទ្រគោះ បោះ-បោក ញុះញង់ ពោលពាក្យបញ្ឆោត បញ្ឈឺចិត្ត ឡកឡាយ បន្ថោកកិត្តិយស បង្អាប់មុខមាត់ ។ ល ។

**៥-សព្វចង្កា ឬសត្វង្គប្រេត** = ប្រេតមានក្រចកដៃជើង ដូចកាំបិត

ប្រេតនេះ មានរូបរាងទុយមុយ ដំបៅពេញខ្លួន សាច់ស្បែកហើមពុរ សុទ្ធតែពងរុយ ខ្ទុះហូរជានិច្ច ភ្នែកលៀនធំ ច្រមុះធំវែង ក្លិនស្អុយគគ្រុក ស្រែកយ្ហានខ្លាំង ក៏យកក្រចកវែងស្រួចមុត ខ្វាចខ្វេះសាច់របស់ខ្លួនស៊ី មានការឈឺចាប់ខ្លោចផ្សាបំផុត ។ ប្រេតនេះ ច្រើនរស់នៅក្នុងព្រៃភ្នំជ្រៅ ឬលើកោះ ។

បាបកម្មនេះ ព្រោះពីជាតិមុន ជាមនុស្សអកតញ្ញូ កាចឫស្យា ជាល់តប់ម៉ែ ឪ ជីដូន ជីតា គ្រូអាចារ្យ ធ្វើឫក្សក្រពើ ឥតធ្វើបុណ្យទាន ។

**ឈ~បព្វតខ្លប្រេត** = ប្រេតមានរាងកាយធំខ្ពស់ ដូចភ្នំ

ប្រេតនេះ មានរាង ( ធំកន្ទ្រល ) វែងខ្ពស់ដូចភ្នំ ដៃជើង និងកខ្វី សក់រឹងគម្រិងគម្រាំង ភ្លើងឆេះព័ទ្ធរុំជុំកាយទាំងយប់ទាំងថ្ងៃ ។ រស់នៅដោយស្រេកឃ្លានអាហារ រាប់កោដិឆ្នាំ មិនចេះស្លាប់ព្រោះកម្មវិបាក ។ មាននៅច្រើនជាអនេកក្នុងជងព្រៃហិមពាន្ត ភ្នំគិជ្ឈកូដ ។

បាបកម្មទាំងនេះ ព្រោះកាលបានអត្តភាពជាមនុស្សជាទុរជន មានចិត្តរឹងរូស កោងកាច មានះ ចងគំនុំ ពូកែឈ្លោះ ឥតខ្លាចរអែង ដុតផ្ទះសំបែងអ្នកដទៃ ធ្លាក់ទៅកើតក្នុងអវិចីនរក សេសសល់ផលកម្ម មកកើតជា **បព្វតខ្ល~ប្រេត**នេះ ។

**ញ~អជគរខ្លប្រេត** = ប្រេតមានកាយ ដូចពស់ថ្លាន់

ប្រេតនេះ មានក្បាលច្រើនបែប គឺក្បាលជាខ្លា ឆ្មា គោ ក្របី ស្វា ដំរី ប្រើស មៀម មាន់ជាដើម ឯខ្លួនជាពស់ថ្លាន់ មានមាឌធំវែងខ្ពស់ដូចភ្នំ ភ្លើងព័ទ្ធខ្លួន ទាំងយប់ទាំងថ្ងៃ ស្រែកឃ្លានជាអនេក ស្រែកទួញត្អូញថ្ងូរ រងទុក្ខទារុណមិនចេះស្លាប់ ច្រើនរស់នៅក្នុងជងព្រៃជ្រៅ ញកភ្នំ មាត់សមុទ្រ កោះ ។

បាបកម្មទាំងនេះ ព្រោះពីជាតិមុនជាមនុស្សប៉ៅខ្មៀ មិនដែលធ្វើបុណ្យ មិនខ្វាចម៉ែឪ ដូនតា ត្រកូលរៀមច្បង តិះដៀល ជេរប្រទេចអ្នកមានសីល ។

**៨~វេមានិកប្រេត** = ប្រេតមានវិមាន

ប្រេតនេះ មានមាឌធំ ធ្វើឫកក្រអឺង រាងក្រអាញ ដុះរោមជិតឈឹង ត្រង់ពោះប៉ោង មើលឃើញគួរឲ្យស្ញើម អស្ចារ្យ សោយទុក្ខ និងសុខស្មើគ្នា ដៃកាន់អាវុធជា អចិន្ត្រៃយ៍ ចិត្តសាហាវខ្លាំងក្លា ។ ប្រេតនេះ ហៅថា យមរាជក៏បាន ។ ពេលថ្ងៃសោយទុក្ខ ចិត្តក្តៅដូចលាជផ្ទុះ ប្រហារសត្វនរក ឈាមប្រឡាក់ពេញខ្លួនតាំងពីព្រឹកទល់

ល្ងាច អត់បាយ អត់ទឹក វាយស្គរចម្រៀងសត្វនរក គ្រប់ឋាន ។ ពេលយប់សោយសុខ ក្លាយជាទេវបុត្រកំលោះ រូបល្អឥតខ្ចោះ ឋិតនៅនាឋានសួគ៌ សោយទិព្វសម្បត្តិ មានទេពអប្សរចោមរោមទាំងគូ សប្បាយរីករាយត្រេកត្រអាលយ៉ាងក្រៃលែង ។

បាបកម្មទាំងនេះ ព្រោះពីជាតិមុនធ្វើទានខ្លះ ៗ តាមទម្លាប់ ស្រវឹងខ្លួប ឥតសីល ប្រមាទ បុណ្យក៏ធ្វើ បាបក៏ធ្វើ ។

**៥-មហិទ្ធិកប្រេត** = ប្រេតមានឫទ្ធិច្រើន

ប្រេតនេះ មានរូបល្អដូចស្ដេចចក្រ មានឫទ្ធិអំណាច មានសម្លៀកបំពាក់ស្អាតស្រស់ ប្រដាប់ដោយមកុដសង្វារយ៉ាងសង្ហា ចិញ្ចាចចិញ្ចៀន ស្រេកឃ្លានខ្លាំងណាស់ ស្ទុះស្វែងរកអាហារសព្វទីកន្លែង ពេលឃើញចំណីស្ទុះទៅចាប់ស្រាប់តែភ្លើងឆេះ ត្រូវទទួលទុក្ខយ៉ាងធ្ងន់ ជួនកាលស្រវាចាប់ដាក់ក្នុងមាត់ ក៏ក្លាយទៅជាដុំដែកក្ដៅក្រហមប្រាល ឆេះមាត់ស្រែកទ្រហោយំយ៉ាងខ្លាំង ពួកខ្លះស៊ីលាមកជាអាហារ មិនចេះឆ្អែត ក្លិនស្អុយឥតគណនា ។

បាបកម្មទាំងនេះ ព្រោះពីជាតិមុន បួសក្នុងសាសនា ប្រមាទ មិនបដិបត្តិធម្មវិន័យ ញាំញីសាសនា ប្រព្រឹត្ត មិច្ឆាចារ ធបោកគ្រហស្ថ ប្រើប្រាស់បច្ច័យ ៤ មិន ពិចារណា ពេលស្លាប់ ទៅកើតក្នុងនរកជ្រៅ សេសសល់ ផលកម្ម មកកើតជា**មហិទ្ធិកប្រេត**នេះ ។

**នគរនៃប្រេតទាំង ១២ ពួកនេះ ឋិតនៅនាបរិវេណព្រៃវិជ្ឈាដវី ភ្នំហិមាល័យ មានមហិទ្ធិកប្រេតជាស្ដេច គ្រប់គ្រងពួកប្រេតទាំងអស់ ។**

## ប្រេត ២១ ពួក

**ក-អដ្ឋិសង្ខលិកប្រេត** = ប្រេតមានគ្រោងឆ្អឹងគ្មានសាច់ស្បែក ។

**ខ-មំសបេសីប្រេត** = ប្រេតមានរាងកាយ ដូចចម្រៀកសាច់ ។

**គ-មំសបិណ្ឌប្រេត** = ប្រេតមានរាងកាយដុំសាច់ ។

**ឃ-និច្ឆវិបុរិសប្រេត** = ប្រេតមានរាងកាយរបកលតស្បែក ។

**ង-អសិលោមប្រេត** = ប្រេតមានដាវជាប់នឹងកាយ ដូចរោម ។

**ច-សត្តិកលោមប្រេត** = ប្រេតមានរាងដូចលំពែងជាប់នឹង កាយ ដូចរោម ។

**ឆ~ខុសលោមប្រេត** = ប្រេតមានព្រួញជាប់នឹងខ្លួន ដូចរោម ។

**ជ~សូចិលោមប្រេត** = ប្រេតមានម្ជុលដោតជាប់នឹងខ្លួន ដូចរោម ។

**ឈ~សូចិលោមប្រេត** = ប្រេតមានដែកស្រួចចាក់ខ្វាស់ រាងកាយប្រូងប្រាង ដូចរោម ។

**ញ~កុម្ភណ្ឌការីប្រេត** = ប្រេតមានអណ្ឌៈជាភារៈ ធំប៉ុនថ្នាំង ។

**ដ~គូថកូបនិមុគ្គប្រេត** = ប្រេតលិចចុះក្នុងរណ្ដៅឧច្ចារៈ ។

**ឋ~គូថខាទកប្រេត** = ប្រេតស៊ីលាមក ។

**ឌ~និច្ឆវិត្ថីប្រេត** = ប្រេតស្រីមានកាយរងាល ឥតស្បែក ។

**ឍ~មង្គុលិត្ថីប្រេត** = ប្រេតស្រី មានកាយអាក្រក់គួរខ្ពើម មានក្លិនស្អុយ ។

**ណ~ឱគិលិនីប្រេត** = ប្រេតស្រី មានរាងកាយឆេះរោលរាលស្រោចដោយរងើកភ្លើង ។

**ត~អសីសកប្រេត** = ប្រេតឥតក្បាល មានតែរាងកាយដូចសាកសពដាច់ក្បាល ( មានមុខមាត់នៅត្រង់ទ្រូង ) ។

**ថ~តិក្ខុប្រេត** = *ប្រេតមានរូបរាងដូចកិក្ខុភ្លើងឆេះសន្ធោសន្ធៅ ។*

**ទ~តិក្ខុនីប្រេត** = *ប្រេតមានរូបរាងដូចកិក្ខុនីភ្លើងឆេះ សន្ធោសន្ធៅ ។*

**ធ~សិក្ខមានាប្រេត** = *ប្រេតមានរូបរាងដូចសិក្ខមានា ភ្លើងឆេះសន្ធោសន្ធៅ ។*

**ន~សាមណេរប្រេត** = *ប្រេតមានរូបរាងដូចសាមណេរ ភ្លើងឆេះសន្ធោសន្ធៅ ។*

**ប~សាមណេរីប្រេត** = *ប្រេតមានរូបរាងដូចសាមណេរី ភ្លើងឆេះសន្ធោសន្ធៅ ។*

## ប្រេត ៤ ពួក

**ក~បរទត្តូបជីវកប្រេត** = *ប្រេតដែលរស់ដោយអ្នកដទៃឲ្យ ។*

**ខ~ខុប្បិបាសិកប្រេត** = *ប្រេតដែលត្រូវបៀតបៀន ដោយការស្រេកឃ្លាន ។*

**គ~និជ្ឈាមតណ្ហិ** = ប្រេតដែលត្រូវភ្លើងឆេះដុតពេល ក្តៅជានិច្ច ។

**ឃ~កាលកញ្ជិកប្រេត** = ប្រេតជាឈ្មោះរបស់អសុរា ។

ប្រេតនេះ មានកម្ពស់ ៣ គាវុត សាច់ឈាមតិច កម្លាំងខ្សោយ មានសម្បុរ និងសណ្ឋានទ្រង់ទ្រាយស្វិតក្រៀមដូចស្លឹកឈើ ភ្នែកលៀនដូចក្តាម មាត់តូចប៉ុនក្តិតម្ជុល ឋិតនៅចំពីលើក្បាល ។

# ៣. អសុរកាយ

ពាក្យថា **អសុរកាយ** *ប្រែថា* ពួកសត្វដែលមិនមានសេចក្តីក្លាហាន ដែលចាញ់គេ ខ្លាចគេ ឬសត្វដែលមិនភ្លឺស្វាងរុងរឿងរស្មី ដោយភាពជាឥស្សរៈ ឬភាពសុខសាន្តរីករាយ ។

មិនភ្លឺស្វាង សំដៅយកជីវិតមិនភ្លឺស្វាងរុងរឿង ក្នុងការរស់នៅ ។ ឧទាហរណ៍ ដូចមនុស្សជាប់ពន្ធនាគារ ត្រូវទទួលទុក្ខទោស ទារុណកម្មផ្សេងៗ រីឯអាហារបរិភោគ ទោះបីមាន

តិចតួចក៏ជាវត្ថុថោកទាប ស្មោកគ្រោក គ្មានអនាម័យសោត ឯសម្លៀកបំពាក់ ទីស្នាក់នៅ ក៏សុទ្ធតែអន់ថយ ។ ឥរិយាបថទាំង ៤ ប្រព្រឹត្តទៅ ឥតមានសេចក្តីសុខសប្បាយរីករាយ ឥតមានឥស្សរភាព និងសិទ្ធិសេរីភាពឡើយ ។ ចំណែកមនុស្សដែលឋិតនៅក្រៅពន្ធនាគារ ប្រកបដោយទ្រព្យសម្បត្តិស្តុកស្តម្ភ ជីវិតរស់នៅផុយអំពីការជាប់ពន្ធនាគារ ពោលដោយសង្ខេប គឺមានសិទ្ធិសេរីភាពគ្រប់គ្រាន់ ។ល។

ពាក្យថា **អសុរ** បានដល់ **កាលកញ្ជិកប្រេត** អសុរាពួកនេះ មិនមានទីស្នាក់នៅអាស្រ័យទេ ដើរសាត់អណ្តែតសែតអញ្ចង់ ស្វះស្វែងតាមទីផ្សេងៗ ក្នុងមនុស្សលោកយើងនេះ មានព្រៃភ្នំ ស្ទឹង ទន្លេ សមុទ្រ កោះ ជ្រោះជ្រលងជងអូរជាដើម ។

*ដែលហៅថា* **អសុរ** *ដោយសេចក្តីថា អសុរា ។* **អសុរា មាន ៣ ពួក គឺ ទេវអសុរា ១ , បេត្តិអសុរា ១ , និរយ~អសុរា** *១ ។*

~ **ទេវអសុរា ចែកជា ៦ ពួក គឺ** *វេបចិត្តអសុរា ១ សុពលិអសុរា ១ , រាហុអសុរា ១ , បហារអសុរា ១ , សម្ពរតីអសុរា ១ , និងវិនិបាតិកអសុរា ១ ។*

~ **បេត្តិអសុរា មាន ៣ ពួក គឺ** *កាលកញ្ចិកប្រេត-អសុរា ១ , វេមានិកប្រេតអសុរា ១ , និងអាវុធិកប្រេត-អសុរា ១ ។*

~ **និរយអសុរា មានតែមួយពួក គឺ** *ពួកប្រេតដែលសោយទុក្ខក្នុងលោកន្តរិយនរក ដែលតាំងនៅនាកណ្តាលចក្រវាលទាំង ៣ មុំ ។*

*ទីនរកនេះ គ្មានព្រះអាទិត្យ គ្មានព្រះចន្ទ ងងឹតឈឹងនៅខាងក្រោមមានទឹកក្រុតមហាត្រជាក់ ពួកសត្វនរកផ្តក់ជាប់នឹងជញ្ជាំងល្អាង ដូចសត្វប្រចៀវ ដោយស្រេកឃ្លាន*

ខ្លាំង ពេលឃើញគ្នា ស្មានថា អាហារ ក៏លោតទៅសង្គ្រប់ខាំគ្នា រួចលែងដៃទាំងពីរហើយ ធ្លាក់ទៅក្នុងទឹកក្រុតខាងក្រោម រលាយខ្លួលបាត់ឈឹង ។

# ៤. តិរច្ឆាន

ពាក្យថា **តិរច្ឆាន** ប្រែថា សត្វទៅដោយទទឹង ឬសត្វដែលមានរាងកាយចម្រើនដោយទទឹង ( ដោយផ្ដេក ដោយទ្រេត មិនបញ្ឈរ ) ។

## តិរច្ឆានចែកជា ៤ ពួក

**១~អបាទតិរច្ឆាន** = សត្វតិរច្ឆានគ្មានជើង មានត្រី ពស់ជាដើម ។

**២~ទ្វិបាទតិរច្ឆាន** = សត្វតិរច្ឆានមានជើងទាំងពីរ មានបក្សាបក្សីជាដើម ។

**៣~ចតុប្បាទតិរច្ឆាន** = សត្វតិរច្ឆានមានជើង ៤ មានគោ ក្របីជាដើម ។

**៤-ពហុប្បានតិរច្ឆាន** = សត្វតិរច្ឆានមានជើងច្រើន មានក្អែប ម្រើមព្រះជាដើម ។

សត្វតិរច្ឆានខ្លះ មានឫទ្ធានុភាពច្រើន ដូចជានាគ គ្រុឌ ដំរី រាជសីហ៍ជាដើម ។

បានឮថា កាឡនាគរាជមានអាយុវែង បានជួបព្រះ-សម្មាសម្ពុទ្ធកក្កុសន្ធៈជាដើម និងបានឃើញព្រះអរិយមេត្រី-សម្មាសម្ពុទ្ធ ដែលនឹងបានត្រាស់នាពេលខាងមុខទៀតផង ។

## អាហាររបស់អបាយសត្វ

សត្វនរក មានកម្មជាអាហារ ប្រេតមានកម្មផង មានផលនៃទានដែលញាតិឧទ្ទិសឲ្យផង ជាអាហារ ឯអាហាររបស់អសុរកាយ ប្រៀបធៀបនឹងមនុស្សជាប់ពន្ធនាគារ ដែលបានរៀបរាប់រួចហើយ ។ ចំណែកសត្វតិរច្ឆាន មាន សាច់ ស្មៅ ស្រូវ ជាអាហារ ។

**<u>កថាពោលពីសត្វតិរច្ឆាន ចប់ ។</u>**

# ៥. មនុស្ស

ពាក្យថា **មនុស្ស ប្រែថា** សត្វវិសេស ឬសត្វមានចិត្តខ្ពស់ បានសេចក្តីថា អ្នកមានចិត្តរុងរឿង មានចិត្តឧក្រិដ្ឋដោយគុណធម៌ ជាសត្វមានសតិសម្បជញ្ញៈ ក្លៀវក្លាដឹងខុសត្រូវ ស្គាល់គុណ ទោស បុណ្យ បាប ប្រយោជន៍និងមិនជាប្រយោជន៍ សមគួរដល់ព្រហ្មចរិយធម៌ ។ **ព្រះសម្មាសម្ពុទ្ធ**ទ្រង់ត្រាស់សម្តែងថា " **កិច្ឆោ មនុស្សប្បដិលាភោ** ការត្រឡប់បានអត្តភាពជាមនុស្ស គឺជាការក្រដ៏ក្រៃលែង " ។

**ព្រះពុទ្ធដីកា**នេះ ប្រសិនបើយើងគ្រាន់តែសិក្សាដោយសើៗ ច្បាលៗ អាចសន្និដ្ឋានថា មិនទាន់ត្រឹមត្រូវពេញលេញទេ ព្រោះកាលៈទេសៈបច្ចុប្បន្ន មនុស្សមានការកើនឡើងជាអតិបរមា គឺមានច្រើនម៉ឺនលាននាក់ណាស់ ប្រទេសជាច្រើន បានដាក់លក្ខខណ្ឌដល់ប្រជាពលរដ្ឋ ឬប្រជាជនរបស់ខ្លួន ឲ្យមានកូនតែមួយ ឬពីរនាក់ ដោយមានវិធានការប្រើប្រាស់ស្រោមអនាម័យ ឬពិធីសាស្ត្រផ្សេងៗ ដើម្បី

ពនព្យាកំណើត ។ ម្យ៉ាងទៀត បញ្ហាទំនាស់ព្រំប្រទល់ រវាងប្រទេសជិតខាងក្តី ព្រំប្រទល់ដីជាប់គ្នាក្តី ការកេងប្រវញ្ចនៃកម្មសិទ្ធជនក្តី រមែងកើតមានជានិរន្តរ៍ ដែលបណ្តាលឲ្យមានភាពស្មុគ្រស្មាញជាទីបំផុត ។ ទិដ្ឋិភាពនេះ អាចបញ្ជាក់បានថា បណ្តាលមកអំពីដីធ្លីមានតិច ឯមនុស្សកើតកាន់តែច្រើន មិនមានតុល្យភាពគ្នា ។ល។

**សំណួរ** ដូច្នេះ តើ**ព្រះពុទ្ធដីកា** ដែលសម្តែងខាងលើអាចកំណត់ថា ត្រឹមត្រូវដែរឬទេ ?

**ចម្លើយ** ពាក្យពិតជាអមតវាចា នេះជា**ព្រះពុទ្ធដីកា**ដែល**ព្រះសម្មាសម្ពុទ្ធ**ទ្រង់ត្រាស់សម្តែង តាំងពីជាង ២៥៦១ ឆ្នាំ រហូតមកដល់បច្ចុប្បន្ន នៅតែគង់វង្ស ឋិតថេរ ឥតប្រែប្រួលឡើយ ។ ឧទាហរណ៍ដូចជា ៖

- សាមញ្ញលក្ខណធម៌ ៣
- អរិយសច្ចធម៌ ៤
- សតិប្បដ្ឋាន ៤
- អដ្ឋង្គិកមគ្គ ( មគ្គប្រកបដោយអង្គ ៨ ) ។ល។

សច្ចធម៌ទាំងនេះ ឥតមានបុគ្គលណាម្នាក់ ក្នុងលោក-សន្និវាសនេះ អាចកែប្រែបានឡើយ ព្រោះផ្តល់អត្ថប្រយោជន៍ សេចក្តីសុខ សេចក្តីចម្រើន ដល់សាវ័ករបស់ព្រះអង្គ ដែលបដិបត្តិនូវធម៌ដ៏សមគួរដល់ធម៌ រហូតបានដល់ទីបំផុតទុក្ខ ដែលទ្រង់ត្រាស់ថា “ **នត្ថិ សន្តិ បរំ សុខំ** សេចក្តីសុខដទៃក្រៅអំពីសេចក្តីស្ងប់ពុំមានឡើយ ” ( ពោលគឺព្រះនិព្វាន ) ។

ពុទ្ធសាសនិក អ្នកមានសទ្ធាប្រកបព្រមដោយបញ្ញា សូមសិក្សាសង្កេតពិនិត្យ ៖

សត្វក្នុងអបាយភូមិ ៣ ( នរក , ប្រេត , អសុរកាយ ) ជា**អទិស្សមានកាយ** ដែលបុថុជ្ជនមិនអាចមើលឃើញ ដោយ**មំសចក្ខុ** បាន គឺមិនដឹងថា មានប៉ុន្មាន ? ក្នុងគម្ពីរព្រះពុទ្ធ-សាសនា សម្តែងថា ប្រសិនបើយើងមើលឃើញវិញនោះ ពិតជាដើរគេចពុំរួចឡើយ ( ច្រើនណាស់ ) ។ សូមមេត្តាក្រឡេកមើលនូវសត្វតិរច្ឆាន ដែលរស់នៅជិតយើងៗ មើលឃើញ ( សត្វជើងពីរ ជើងបួន ជើងច្រើន គ្មានជើង សត្វដើរ លូន វារ ហើរ ហែល បិតនៅក្នុងស្រុក ព្រៃ ទន្លេ ស្ទឹង

បឹងបួ សមុទ្រ វន្ន វុង ។ ល ។ តើសត្វទាំងនេះ មានកូន មានពង មួយឆ្នាំៗ ប៉ុន្មានដង ? កូនម្តងៗ ប៉ុន្មាន ? ពងម្តងៗ កើត ឬញាស់បានកូនប៉ុន្មាន ?

ឯពួកទេវតា ៦ ជាន់ និងព្រហ្ម ២០ ជាន់ ជាសុខុមរូប ឬ**អទិស្សមានកាយ** ដែលយើងមិនអាចមើលឃើញដែរនោះ តើមានប៉ុន្មាន ? ស្ថានទេវតាទាំងអស់នោះ សូម្បីពួកអ្នកវិទ្យាសាស្ត្រមានឧបករណ៍ទំនើប ដែលហៅថា **អតិសុខុម-ទស្សន៍** ក៏មិនអាចចុះបញ្ចាំង មើលស្ថានទេវតាឃើញដែរ ។

" **សត្តនិកាយោ អនន្តោ** ពួកសត្វច្រើនរាប់មិនអស់ "

**ព្រះសម្មាសម្ពុទ្ធបរមគ្រូ** ជាអម្ចាស់ទ្រង់ត្រាស់សម្តែងបែងចែកតាមការរស់នៅ និងការប្រព្រឹត្តរបស់មនុស្ស ជា ៥ ពួកគឺ ៖

**១-មនុស្សនេរយិកោ** = មនុស្សដែលមានការរស់នៅ និងការចិញ្ចឹមជីវិត ដូចសត្វនរក ។

**២-មនុស្សបេតោ** = មនុស្សដែលមានការស់នៅ និងការចិញ្ចឹមជីវិតដូចសត្វប្រេត ។

**៣-មនុស្សតិរច្ឆានោ** = មនុស្សដែលមានការស់នៅ និងការចិញ្ចឹមជីវិតដូចតិរច្ឆាន ។

**៤-មនុស្សមនុស្សោ** = មនុស្សដែលមានការស់នៅ និងការចិញ្ចឹមជីវិតដូចមនុស្ស ។

**៥-មនុស្សទេវោ** = មនុស្សទេព្តា ។

**មនុស្សនរក** និង**មនុស្សប្រេត** សូមមិនធ្វើអត្ថាធិប្បាយ ព្រោះជា**អទិស្សមានកាយ** យើងយល់ដឹងខ្លះៗ តាមគម្ពីរដីកាព្រះពុទ្ធសាសនា ។ ដូច្នេះ សូមមេត្តាពិនិត្យមើល នូវការប្រព្រឹត្ត និងការចិញ្ចឹមជីវិត របស់មនុស្សតិរច្ឆាន ដែលយើងបានមើលឃើញ ដឹងឮយ៉ាងប្រចក្ស ដូចតទៅ ៖

**សត្វតិរច្ឆាន** មានជាតិកំណើត ជាអហេតុកអកុសល-វិបាកបដិសន្ធិ មានតែសញ្ញា ៣ គឺអាហារសញ្ញា ១ , កាមសញ្ញា ១ , និងភយសញ្ញា ១ , ឥតមានធម្មសញ្ញាទេ

( វៀរសន្ដានព្រះបរមពោធិសត្វ ) ។ ដ្បិតនិយាមសភាវគតិរបស់សត្វតិរច្ឆាន ជាសត្វមិនដឹងខុសត្រូវ មិនស្គាល់បាបបុណ្យ គុណទោស អាក្រក់ ល្អ ស ខ្មៅ ឡើយ ម្ល៉ោះហើយការប្រព្រឹត្ត និងការចិញ្ចឹមជីវិត ប្រកបតែអំពើទុច្ចរិតកម្មផ្សេងៗ អបាយមុខ ពាលា អាវ៉ាសែ សាហាវ ឃោរឃៅប្រទូសរ៉ាយ ក្ដៅក្រហាយ វាយដំ បាញ់ ចាក់កាប់សម្លាប់មនុស្សសត្វ បំបាត់ជីវិត លួចប្លន់ ឆក់ ដណ្ដើម ប្រព្រឹត្តអនាចារ គ្មានសីលធម៌ តាមសភាវគតិរបស់សត្វតិរច្ឆានដ៏អាក្រក់អាក្រី ថោកទាប គួរឲ្យអៀនខ្មាស គួរស្អប់ខ្ពើមត្រូវតែតិះដៀល និងគួរតែដាក់ទណ្ឌកម្ម ឧទាហរណ៍ ការសេពមេថុន ស្ត្រីតែម្នាក់ បុរសច្រើននាក់ តាមទី សាធារណៈឪពុករំលោភកូន កូននឹងម្ដាយ ជីតារំលោភចៅ ប្ដីពីរប្រពន្ធមួយ ។ ល ។ ការពោលពាក្យកុហក ភូតភរ ឆបោកអសុរោះ ញុះញង់ កេងប្រវញ្ច ក្លែងក្លាយ បោកប្រាស់ដោយក្អែកជញ្ជីង ឬលក់ ដូរសម្ភារៈកាឡៃ ឃោសនា

បំផ្លើស ( គូថកាណី ) ។ សេពសុរាមេរ័យ គ្រឿងញៀន ។ល ។ និង ។ល ។

អាកប្បកិរិយាទាំងអស់ របស់**មនុស្សតិរច្ឆាន**នេះ គឺដូចសត្វតិរច្ឆានបេះបិទ ។

សូមអញ្ជើញអស់លោក តាមដានស្តាប់ធម្មទេសនាតាមស្ថានីយ៍វិទ្យុជាច្រើន និងស្តាប់នាទីសន្តិសុខសង្គម អានទស្សនាវដ្តី អានសារពត៌មាន ស្តាប់នាទីទស្សនសារ-ព័ត៌មាន ដោយផ្ទាល់បន្ថែមទៀត ឲ្យបានជ្រាបច្បាស់នូវអំពើក្បត់ សីលធម៌សង្គមជាតិ និងសង្គមសាសនា យ៉ាងច្រើនជាអនេកប្បការ ។ មិនតែប៉ុណ្ណោះ មនុស្សតិរច្ឆានទាំងនោះ ថែមទាំងមិនបានបំពេញសេចក្តីល្អតិចតួច ឬសន្សំបុញ្ញកម្មតូចតាច ដើម្បីសេចក្តីសុខចម្រើន សម្រាប់ជីវិតបច្ចុប្បន្ន ឬអនាគតរបស់ខ្លួនឡើយ ។

៦ **មនុស្សមនុស្សោ** ជាមនុស្សមានលក្ខណៈជាមនុស្សការប្រព្រឹត្ត និងការចិញ្ចឹមជីវិត ជាមនុស្ស គឺជាបុគ្គលមានសទ្ធាជឿការត្រាស់ដឹងរបស់ព្រះតថាគត ជឿកម្មផល ជឿ

ផលវិបាករបស់កម្ម ជាអ្នកមានសីល ៥ ប្រចាំជីវិត ចម្រើនមេត្តាភាវនា ផ្តល់អភ័យចំពោះសព្វសត្វ លះបង់ទុច្ចរិត ៣ សេពគប់បណ្ឌិតសប្បុរស បំពេញសេចក្តីល្អជាប្រក្រតី ។ម្យ៉ាងទៀត ការបានអត្តភាពជាមនុស្ស មានសរីរាវយវៈគ្រប់លក្ខណៈ មិនពិកលពិការ គឺបានដោយអាស្រ័យកុសលវិបាកបដិសន្ធិ ( ទុហេតុក , តិហេតុក ) ពោលគឺបុញ្ញកម្មដែលបានសន្សំ បានបំពេញរាប់ជាតិជាអនេកពិសេសបានកើតជាមនុស្សខ្មែរ មានសញ្ជាតិខ្មែរ ឋិតក្នុងប្រទេសខ្មែរ ជាប្រទេសមានបណ្ឌិតសប្បុរស ប្រព្រឹត្តសប្បុរសធម៌ ជាប្រទេសកាន់ព្រះពុទ្ធសាសនា ដែលជាសាសនាប្រកបដោយហេតុផល ជាសាសនាវិទ្យាសាស្ត្រជាសាសនាសកល ជាសាសនាមិនទទួលការសូម ការបួង-សួង ការបន់ស្រន់អង្វរករ ឬស៊ីសំណូក សូកប៉ាន់ឡើយរួមសេចក្តីយ៉ាងខ្លីមក ព្រះពុទ្ធសាសនា ជានិយ្យានិក-សាសនា ដឹកនាំសព្វសត្វអ្នកបដិបត្តិ ឲ្យបានទទួលផលដ៏

ប្រសើរ ឧត្តុង្គឧត្តម រហូតបានចាក់ធ្លុះនូវមគ្គ ផល ព្រះ-និព្វាន ។

ពិសេសម្យ៉ាងទៀត ការបានកើតជាមនុស្ស គប្បីដឹងដោយខ្លួនឯងថា ជាបុគ្គលមានសមត្ថភាព និងមានដើមទុនយ៉ាងច្រើន ព្រោះមានភ្នែកជា ( **ឧស្សនានុត្តរិយៈ** ) អាចមើល ( អាន ) ព្រះពុទ្ធវចនៈ ( ព្រះត្រៃបិដក ) ព្រះអដ្ឋកថា ដីកា និងមើលបូជនីយវត្ថុ បូជនីយដ្ឋានក្នុងប្រទេស ដូចជាព្រះសក្យមុនីចេតិយ តម្កល់ព្រះបរមសារីរិកធាតុ លើកំពូលភ្នំព្រះរាជទ្រព្យ ( វិហារអដ្ឋរស្ស ) ។ ព្រះពុទ្ធប្បដិមាធំតូច រាប់ពាន់ព្រះអង្គ និងព្រះពោធិព្រឹក្សយ៉ាងច្រើនដើម ដែលប្រតិស្ឋាននៅអាស្រមព្រះគន្ធកុដិ ខេត្តបាត់ដំបងនៅពុទ្ធមណ្ឌលកម្ពុជា ឋិតនៅឃុំដីឥដ្ឋ ស្រុកកៀនស្វាយ ខេត្តកណ្ដាល ។ ល ។ សម្លឹងមើលព្រះសង្ឃសាវ័ក ប្រកបដោយឥន្ទ្រិយសំវរៈ នៅពេលនិមន្តបិណ្ឌបាត ឬប្រគេនចង្ហាន់ ។ ល ។ ជា**សវនានុត្តរិយៈ** គឺមានត្រចៀក អាចស្ដាប់ព្រះធម៌ ជាធម៌នាំសត្វឲ្យបានរួចចាកសង្សារទុក្ខ ដែលព្រះ-

យោគាវចរស្វាធ្យាយ ធម្មកថិកសម្ដែង ឬធម្មសាកច្ឆា តាមវិទ្យុ ជាច្រើនស្ថានីយ៍ ចាប់ពីម៉ោង ៤ និង ៣០ នាទី រហូតដល់ម៉ោង ១១ យប់ ( ២៤ ម៉ោង ) ប្រហែល ២០ ពេល ។ល។

ជាលាភដ៏ប្រសើរ ដែលយើងមានលទ្ធភាព អាចសិក្សាព្រះធម្មវិន័យ ជា**ព្រះបរមពុទ្ធោវាទ** ប្រកបដោយការសច្ចៈដ៏ត្រឹមត្រូវ ល្អប្រពៃ វិសេសក្រៃលែង គ្មានពាហិរសាសនា ឬលិទ្ធិណា ប្រៀបផ្ទឹមស្មើបានឡើយ ។ ដែលរាប់ចូលបានថា ជា**លាភានុត្តរិយៈ** និង**សិក្ខានុត្តរិយៈ**ផង ។ល។ មានមាត់ មានអណ្ដាតអាចគ្រលាស់ ទន្ទេញ បរិកម្ម និងពោលនូវវចីសុចរិតបាន ព្រមទាំងអាចបំពេញគុណធម៌ជាច្រើនទៀត ដូចជា ការឲ្យទាន សមាទានសីល ចម្រើនភាវនា អប់រំសតិប្បដ្ឋាន ប្រតិបត្តិតាមអរិយមគ្គប្រកប ដោយអង្គ ៨ ដែលជាផ្លូវមួយតែមួយគត់ ក្នុងបដិបទាដើម្បីឈមមុខទៅកាន់ត្រើយព្រះនិព្វាន ។

ភ័ព្វសំណាង ដ៏ឧត្តុង្គឧត្តមមួយផ្នែកទៀត ដែលពុទ្ធ-បរិស័ទជាធម្មមិត្តយ៉ាងច្រើន បានចូលរួមដំណើរធម្មយាត្រាស្វែងបុណ្យ ទៅនមស្ការគោរពបូជាបូជនីយដ្ឋាននានា នៅជាតិភូមិ នៃព្រះសម្មាសម្ពុទ្ធជាម្ចាស់ ( ដែលដឹកនាំដោយលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ជាដើម ) ។ ចំណែកយើងខ្ញុំ ដែលមិនបានចូលរួម ក៏បានទទួលអនុមោទនា ( ជាបត្តិទានមយបុណ្យ ) ដោយសោមនស្ស នឹងជាមហា-កុសលដ៏ប្រសើរថ្លៃថ្លាផងដែរ ។ មិនតែប៉ុណ្ណោះ បណ្តាកំណើតទាំង ៣១ ភូមិ មានតែកំណើតជាមនុស្សមួយគត់ ដែលមានពុទ្ធានុញ្ញាត អាចសាងនេក្ខម្មៈ គឺបព្វជ្ជា ឬ ឧប-សម្បទា បំពេញបារមីធម៌ ឬពុទ្ធការកធម៌ ដើម្បីឲ្យបានសម្រេចជាព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ ឬជាអគ្គសាវកពុទ្ធបាន ។ ឯសត្វក្នុងភូមិ ៣០ ទៀត មិនអាចបព្វជ្ជា ឬឧប-សម្បទាបានឡើយ ។

តែប្រសិនបើបានកើតជាមនុស្សហើយ មិនបានជួបនឹងព្រះពុទ្ធសាសនា បែរជាជួបនឹងសាសនា ដែលជាសាសនា

ទិញដូរ ដួលដោយប្រាក់កាស ឬសម្ភារៈល្បួងលួងលោម បោកបញ្ឆោតថា ព្រះទទួលបាបជំនួស ឬព្រះអាចជួយព្យាបាលរោគ ឲ្យជាសះស្បើយ ពុំនោះសោត ជាសាសនា ដែលប្រតិបត្តិ វត្តគោ វត្តពស់ វត្តជ្រូក វត្តឆ្កែ មុជទឹកលាងបាប រដូវក្តៅដេកហាលថ្ងៃ រដូវត្រជាក់ចុះត្រាំទឹក ដេកលើបន្លា ក្តាប់ដៃអត់អាហារ បរិភោគស្លឹកឈើ ស៊ោលាមកសត្វ លាមកមនុស្ស ( ជម្ពុកាជីវក ) ប្រព្រឹត្តអាក្រាតកាយ ។ ល ។

**សួរថា** តើការបដិបត្តិ បែបពាហិរសាសនានេះ អាចបន្ទោបង់ កម្ចាត់បង់ ដើម្បីរំលត់កិលេសក្នុងចិត្តបានដែរឬ ?

មុននឹងបញ្ចប់នូវភូមិទី ៥ ( មនុស្សភូមិ ) នេះ ខ្ញុំសូមអញ្ជើញបងប្អូន ញាតិញោមសាធុជនរួមសាសនា ព្យាយាមញុំាងសទ្ធាឲ្យកាន់តែប្រាកដច្បាស់បន្ថែមទៀតថា ការត្រាច់រង្គាត់ក្នុងវដ្តសង្សារ ដែលគ្មានទីបំផុតខាងដើម និងខាងចុងនេះ យើងទាំងអស់គ្នា អ្នកណាម្នាក់ក៏សុទ្ធតែធ្លាប់បានកើតជាព្រះព្រហ្ម ព្រះឥន្ទ ទេព្តា អសុរ យម យក្ស គ្រុឌ នាគ

គោ ក្របី ដំរី សេះ ខ្លា ក្រពើ ជ្រូក មាន់ ទាផ្ទៃ ។ល។ ធ្លាប់បានសោយទិព្វសម្បត្តិ សម្រេចលោកិយឈាន មានសមាបត្តិ មានអាយុរាប់កោដិកប្ប និងត្រូវគេធ្វើទារុណកម្ម បន្ទំឲ្យអួស ឲ្យទាញ វាយវាត់ ចាក់កាប់សម្លាប់បង្ហូរឈាម ប្រៀបនឹងទឹកមហាសមុទ្រ ។ ឯឆ្អឹងគរលើផែនដីនេះ ស្មើនឹងភ្នំសិនេរុ ទីឋានត្រង់ណាក៏ធ្លាប់បានកប់បានដុតសាកសពរបស់យើងដែរ ហើយម្នាក់ៗ ក៏ធ្លាប់ជាម៉ែឪ បង ប្អូន ប្រពន្ធ ប្តី ( ត្រឡប់ត្រឡិន វិលវល់ ) រាប់កប្បជាតិគ្មានទីបំផុត ។ ធ្លាប់កើតជាប្រេត ជាសត្វនរក ជាឧបបាតិកកំណើត រងទុក្ខសោក វិយោគ ស្រែក ទួញថ្ងូចថ្ងូរថា “ កាលណា បានកើតជាមនុស្ស ខ្ញុំនឹងជាមនុស្សល្អ ដឹងខុសត្រូវ ស្គាល់គុណទោស បម្រើមាតាបិតា គោរពត្រកូលរៀមច្បង មានសទ្ធាជ្រះថ្លា ក្នុងព្រះពុទ្ធសាសនា ជាអ្នកឲ្យទាន សមាទានសីល ប្រព្រឹត្តសុចរិត រាងចាលឈប់ធ្វើអំពើបាបទៀតហើយ ” ។ តែផ្ទុយទៅវិញ សត្វទាំងនេះ លុះពេលបានកើតជាមនុស្ស ដោយឥទ្ធិពលនៃសេចក្តីសុខ ជា

អំណោយបន្ថិចបន្តួចរបស់បញ្ចក្ខន្ធ ក៏ភ្លេចពាក្យសន្យារបស់ខ្លួន កាលទៅជានរក ប្រេតអស់ហើយ បែរជាប្រព្រឹត្តទុច្ចរិតកម្ម ដោយសេពសោយ ត្រេកត្រអាលសប្បាយរីករាយក្នុងបញ្ចកាមគុណដ៏ក្រៃលែង ជាហេតុប្បច្ច័យនាំឲ្យសត្វនោះៗ ស្លាប់ទៅកើតក្នុងអបាយភូមិតទៅទៀត មានសត្វតិចណាស់ ដែលរួចចាកពីសំណាញ់អបាយភូមិ ៤ ,

**អន្ធភូតោ អយំ លោកោ តនុ កេត្ថ វិបស្សតិ**

**សកុណោ ជាលមុត្តោវ អប្បោ សគ្គាយ គច្ឆតិ**

សត្វលោកនេះ ( ល្ងង់ ) ដូចមនុស្សខ្វាក់ នៅក្នុងលោកនេះ សត្វតិចណាស់ដែលបាន ឃើញច្បាស់នូវព្រះ-សទ្ធម្ម សត្វតិចណាស់ដែលបានទៅកាន់ស្ថានសួគ៌ ដូចបក្សីដែលជាប់សំណាញ់របស់ព្រាន មិនអាចរួចខ្លួនចាកសំណាញ់បានឡើយ ។

សូមលើកយក **រឿងនាងខ្ញី** ស្រង់ចាកខ្សែអាត់សំឡេងព្រះធម៌ លេខ ១៥៨៧ ដែលសម្តែងដោយលោកគ្រូអគ្គបណ្ឌិត **ប៊ុត-សាវង្ស** មានសេចក្តីដូចតទៅ ៖

កាលព្រះសម្មាសម្ពុទ្ធ គង់ប្រថាប់ក្នុងវត្តវេឡុវ័ន ទ្រង់ស្តេចយាងបិណ្ឌបាត ក្នុងក្រុងរាជគ្រឹះ ទ្រង់ទតឃើញមេជ្រូកមួយ ទ្រង់ព្រះញញឹម ព្រះអានន្ទបានឃើញពន្លឺដែលចែងចាំង ចេញពីព្រះទាឋនៃព្រះឱស្ឋទិព្វថ្ងៃ ក៏ទូលសួរ , ព្រះអង្គមានព្រះបន្ទូលថា នែ ! អានន្ទ អ្នកឃើញមេជ្រូកនុ៎ះ ឬទេ ? បពិត្រព្រះអង្គ ! ខ្ញុំព្រះអង្គឃើញ ។ ម្នាលអានន្ទ ក្នុងសាសនាព្រះសម្មាសម្ពុទ្ធកកុសន្ធៈ មេជ្រូកនេះ កើតជាមេមាន់ នៅជិតរោងបាយ មេមាន់នោះបានស្តាប់ព្រះយោគាវចរមួយអង្គ ស្វាធ្យាយព្រះធម៌ គឺវិបស្សនាកម្មដ្ឋាន ថា សង្ខារធម៌ទាំងឡាយមិនទៀងជាដើម ។ ដោយអំណាចអានិសង្ស ដែលបានបង្អោនចិត្តស្តាប់ព្រះធម៌ដ៏ប្រពៃ ( សូម្បីមានអត្តភាពជាមេមាន់ ) ។

នៅពេលព្រះនាង បានសម្រេចជាព្រះអរហន្តី រលឹកជាតិបាន ទើបសម្តែងបន្ថែមថា មេមាន់បានស្លាប់ដោយការចាប់នៃសត្វខ្លែង ( យកទៅធី ) ។ ស្លាប់ពីមេមាន់ បានកើតជារាជធីតា ឈ្មោះនាងឧព្វរី ពេលចូលទៅបន្ទោបង់ក្នុងបង្គន់ ( មិនមែនបង្គន់អនាម័យ ដូចយើងសព្វថ្ងៃទេ ) ដោយឧបនិស្ស័យដែលធ្លាប់សន្សំមក មើលឃើញដង្កូវក្នុងបង្គន់[១] យោនិសោមនសិការកើតឡើង ពិចារណាបដិកូលសញ្ញា បានសម្រេចបឋមជ្ឈានភូមិ បានទៅកើតក្នុងព្រហ្មលោក ។ ចុតិពីព្រហ្ម ( ព្រះដ៏មានបុណ្យ ទ្រង់សម្តែងថា " វិលវល់ៗ ក្នុងភព " ) ពេលព្រះនាង រលឹកឃើញជាតិខ្លួនឯងថា ជាតិមុនជាសេដ្ឋីធីតា ចុតិមកកើតជាមេជ្រូកហ្នឹងឯង ។ ព្រះអានន្ទ លោកស្តាប់រឿងនេះ កើតសេចក្តីសង្វេគ ហើយសម្តែងប្រាប់ដល់ភិក្ខុទាំងឡាយៗ ក៏សង្វេគ ( ចំពោះជីវិត ) ដូចនាងនេះ ជាតិមុនជាមេមាន់ បន្ទាប់មកកើតជាមនុស្ស គឺឧព្វរីរាជធីតា ហើយទៅកើតក្នុង

---

**១.ការមើលដង្កូវជាអនិដ្ឋារម្មណ៍ ( អកុសលវិបាក ) ។**

ព្រហ្មលោក បន្ទាប់មកកើតជាកូនសេដ្ឋី ឥឡូវមកកើតជាមេជ្រូក ព្រោះហេតុនោះ ទើបព្រះបរមសាស្តា ទ្រង់ត្រាស់សម្តែងនៅក្នុងអដ្ឋកថាគាថាធម្មបទយ៉ាងច្រើន អំពីទោសនៃតណ្ហា ដែលមិនទាន់បានជីករំលើងឫសគល់ រមែងញ៉ាំងសត្វឲ្យមានទុក្ខទោសដ៏ក្រៃលែង ក្នុងវដ្តសង្សារ មិនអស់មិនហើយ យ៉ាងនេះឯង ។

ភិក្ខុទាំងឡាយ ស្តាប់ព្រះគាថា របស់ព្រះលោកនាថហើយ បានសម្រេចគុណធម៌ មានសោតាបត្តិផលជាដើម ។

ក្នុងធម្មបទដ្ឋកថា ដែលសម្តែងប្រវត្តិច្បាស់លាស់ ជាទីបញ្ចប់នៅសិរីលង្កាថា នាងនោះ ស្លាប់អំពីមេជ្រូក ទៅកើតជាមនុស្សនៅក្នុងសុវណ្ណភូមិ ស្លាប់ពីមនុស្សនៅក្នុងសុវណ្ណភូមិ ទៅកើតជាមនុស្សនៅក្នុងនគរពារាណសី ស្លាប់ពីមនុស្សនៅក្នុងនគរពារាណសី ទៅកើតជាកូនឈ្មួញរទេះនៅក្បែរកំពង់សុប្បារកៈ តមកកើតជាកូនអ្នកអុំទូក នៅឯកំពង់គាវិរៈ តមកទៀតទៅកើតជាមនុស្ស នៅក្នុងអនុរាធបុរី ( ប្រទេសសិរីលង្កា ) បានធ្វើបុណ្យសុន្ទរីទាន

សមរម្យ សព្វគ្រប់ តមកទៀតជាជាតិចុងក្រោយ បានទៅកើតជាកូនកុដុម្ពីឈ្មោះសុមនៈ នាទិសទក្សិណនៃអនុរាធបុរី ក្នុងស្រុក កេក្កន្ទគ្រាម នៅពេលស្រុកកើតសង្គ្រាម ព្រះបាទទុដ្ឋគាមិនីអភ័យ [២] ច្បាំងជាមួយពួកទមិឡ ក៏រត់ភៀសខ្លួនជាមួយនឹងមាតាបិតា ទៅស្នាក់នៅភូមិមួយ ឈ្មោះទីឃវាបិ ពេលនោះ អាមាត្យធំម្នាក់របស់ស្តេច ឈ្មោះលកុណ្តក-អតិម្ពរៈ បានឃើញនាងសុមនា ក៏ស្រឡាញ់ រួចរៀបមង្គលការ យ៉ាងអ៊ឹកធឹក ។ ក្រោយមកមានព្រះថេរៈ ១ អង្គ ព្រះនាមមហាអតុលៈ នាំភិក្ខុទាំងឡាយ ត្រាច់បិណ្ឌបាត បានជួបនឹងនាងសុមនា មហាថេរបានសម្តែងប្រាប់ភិក្ខុទាំងឡាយ អំពីការអន្ទោលជាតិកំណើតរបស់នាង ព្រោះលោកបានជ្រាបប្រវត្តិតាំងពី ព្រះអានន្ទបានឃើញព្រះដ៏មានព្រះ-ភាគ ទ្រង់ព្រះញញឹម ដោយសព្វគ្រប់ នាងបានទៅស្តាប់

---

**២. ស្តេចទុដ្ឋគាមិនីអភ័យ ជាអ្នកជ្រះថ្លាក្នុងព្រះពុទ្ធសាសនា បានសាងបូជ-នីយដ្ឋានជាច្រើន មានសុវណ្ណមាលិកចេតិយ និងលោហប្រាសាទជាដើម ស្តេចអង្គនេះ ត្រូវបានជាអគ្គសាវ័កស្តាំ របស់ព្រះអរិយមេត្រី ។**

ក្នុងទីនោះដែរ ស្រាប់តែរលឹកឃើញជាតិបាន សង្វេគនឹងខ្លួនឯងក្នុងវដ្តសង្សារ ដែលរកអ្វីឲ្យប្រាកដថា ជារបស់ខ្លួនគ្មាន ( កើតជាមាន់ , ជារាជធីតា , ជាព្រហ្ម , ជាកូនសេដ្ឋី , ជាជ្រូក , ជាមនុស្ស នៅក្នុងសុវណ្ណភូមិ , ជាមនុស្ស នៅក្នុងពារាណសី , ជាកូនឈ្នួញរទេះ , ជាកូនអ្នកអុំទូក , ជាកូនកុដុម្ពី រត់ចោលស្រុកភូមិ ហើយបានជាភរិយារបស់អាមាត្យ ) ។ ដោយសេចក្តីសង្វេគខ្លាំង ក៏សុំប្តីបួសនៅក្នុងសម្នាក់ភិក្ខុនី ដែលបរិបូណ៌ដោយឥន្ទ្រិយ និងពលៈ ស្តាប់ភិក្ខុនីស្វាធ្យាយ **មហាសតិប្បដ្ឋានសូត្រ** បានសម្រេចសោតាបត្តិផល រួចធ្វើដំណើរទៅកាន់មហាវិហារ ជាទីគង់អាស្រ័យនៅនៃអតុលមហាថេរៈ បានស្តាប់ **អសីវិសូបម~សូត្រ** ( ធាតុ ៤ ដូចជាអសិរពិស ) បាន សម្រេចជាព្រះអរហន្តី ។ ពេលមួយ បានសម្តែងជីវប្រវត្តិ របស់ខ្លួនហើយក៏បរិនិព្វានក្នុងកណ្តាលជំនុំសង្ឃនោះឯង ។

ការលើកយកបុគ្គលាធិដ្ឋានមកនេះ ជាសក្ខីភាពបញ្ជាក់ឲ្យកាន់តែច្បាស់នូវមហាសមុទ្រទុក្ខ ក្នុងវដ្តៈដែល

យើងទាំងអស់គ្នាកំពុងហែលចូលកាត់ ពុំអាចកំណត់ថា នឹងរួចផុតនៅពេលណាឡើយ ហើយក៏ជាគ្រឿងដាស់សតិសម្បជញ្ញៈរបស់យើងគ្រប់គ្នា កុំឲ្យលង់លក់ក្នុងសេចក្ដីប្រមាទ ព្រោះបមាទធម៌ ជាកំពូលនៃអកុសលទាំងអស់ អកុសលទាំងឡាយទាំងពួង ប្រជុំចុះក្នុងបមាទធម៌ៗ ជាផ្លូវនៃសេចក្ដីស្លាប់ ( ស្លាប់ទាំងរស់ ) **បមាទោ មច្ចុនោ បទំ** ។

ការពោលបរិយាយរាប់រៀបអំពីពាក្យថា **មនុស្ស** ហាក់មានភាពវែងអន្លាយ ថែមទាំងឃ្លាតចាកចំណងជើងផង តែទោះជាយ៉ាងណា សូមលោកអ្នកអាន មេត្តាសន្ដោសអភ័យទោសដល់ខ្ញុំបាទ ដោយអនុគ្រោះ ។

រីឯ **មនុស្សទេវោ** = មនុស្សទេព្តា គឺជាមនុស្សមានទេវធម៌ ជាបណ្ឌិតសប្បុរស មានសទ្ធា សីល សុតៈ ចាគៈ បញ្ញា បរិបូណ៌ដោយ ហិរិ ឱត្តប្បៈ មានចិត្តតម្កល់មាំក្នុងធម៌ស មានសន្ដានចិត្តស្ងប់ ដែលព្រះសម្មាសម្ពុទ្ធបរមគ្រូជាម្ចាស់ ទ្រង់ត្រាស់ហៅថា ( មនុស្ស ) មានទេវធម៌ក្នុងលោក ។

# ៦. ឋានសួគ៌

**ស្ថានសួគ៌** គឺជាទីសម្រាប់អាស្រ័យនៅ នៃពួកទេវតាទាំងឡាយ ។

ពាក្យថា **ស្ថានសួគ៌ ប្រែថា ល្អ ស្អាត ឆាយ** គឺល្អលើស ស្អាតលើស ឆាយលើស ។ **បានសេចក្តីថា** រូប សំឡេង ក្លិន រស សម្ផស្ស ទ្រព្យ លាភ យស សរសើរ សុខ អាយុ វណ្ណៈជាដើម សុទ្ធសឹងតែល្អលើស ស្អាតលើស ឆាយលើស ប្រសើរលើស ជាងមនុស្សលោកយើងនេះ រាប់រយពាន់ដង ។

ពួកទេវតាក្នុងស្ថានសួគ៌ មានសេចក្តីសម្រាន្តក្សាន្តសប្បាយរីករាយលើសលុប ជាលំដាប់តាមឋាន អ្វីៗ សុទ្ធតែល្អប្រណីត ស្អាតស្រស់ត្រចះត្រចង់ ហើយជាទីភ្លើតភ្លើនចម្រើនចិត្តឥតខ្វះខាត គឺមានរូបស្អាតល្អល្អះ ស្រស់ប្រិម-ប្រិយផូរផង់ មានរស្មីពណ្ណរាយ គួរពេចពិលរមិលមើល និងជាទីមនោរម្យជល់ដួងចិត្ត ។ ឯសំឡេងពីរោះផ្អែមល្ហែម

ក្លិនក្រអូបឈ្ងុយឈ្ងប់ អាហារទិព្វប្រកបដោយឱជារស ឈ្ងុយឆ្ងាញ់ជាប់វិញ្ញាណសោត ឯសម្ផស្សល្អិតល្អន់ ទន់ល្មៃ រលើបរលង់គួរចង់ប៉ះពាល់ដល់កាយ គ្មានណាយចិត្ត ។ល។

យើងទាំងអស់គ្នា ជាពុទ្ធសាសនិកជន សូមជ្រាបតាម **មង្គលសូត្រ** ដែល **ព្រះសម្មាសម្ពុទ្ធ** ទ្រង់ត្រាស់សម្ដែង ជាអាទិ៍ថា " លំដាប់នោះឯង ទេវតាអង្គ ១ កាលដែលវេលា រាត្រីបឋមយាមកន្លងទៅហើយ មានរស្មីដ៏ល្អ ញ៉ាំងវត្តជេតពនជុំវិញទាំងអស់ឲ្យភ្លឺស្វាង គឺពន្លឺទាំងនោះ ភ្លឺដោយរស្មីនៃទេវតា ១ អង្គនោះឯង " ។

ម្យ៉ាងទៀត គួរយើងធ្វើការសន្និដ្ឋានរឿងព្រះនន្ទ ដែលកំពុងរៀបមង្គលការ **ព្រះមានព្រះភាគ** ទ្រង់ប្រគល់បាត្រ ឲ្យព្រះនន្ទកាន់ដើរតាមក្រោយ ពេលនោះ ស្រីបម្រើបាននាំដំណឹងទៅប្រាប់នាង ជនបទកល្យាណីថា " ព្រះពុទ្ធ ( ជាម្ចាស់បង ) នាំព្រះនន្ទទៅតាមហើយ " នាងជនបទ-កល្យាណី ស្រែកដង្ហោយហៅព្រះនន្ទថា " បពិត្រព្រះ-

អយ្យបុត្រ សូមត្រឡប់មកវិញឆាប់ៗ ” សំឡេងនេះ ប្រៀប បាននឹងទឹកអម្រឹត ឬទឹកទិព្វដ៏មហាត្រជាក់ ស្រោចស្រព បេះដូងព្រះនន្ទ ហើយតាំងនៅក្នុងត្រចៀកជានិរន្តរ៍ ឥតបាត់ មួយនាទី ដោយនឹកជានិច្ចថា ព្រះអង្គទ្រង់នឹងយកបាត្រវិញ នៅត្រង់ក្បាលជណ្ដើរ ឬនឹងយកវិញនៅត្រង់ជើងជណ្ដើរ ព្រះលានលួង សូម្បីដល់ទីនោះៗ ក៏ព្រះដ៏មានបុណ្យទ្រង់ មិនទទួល ទោះបីខ្លាចមិនហ៊ានតឿន ឬថ្វាយបាត្រទៅ ព្រះសាស្ដាក៏ពិតមែន តែក្នុងចិត្តព្រះនន្ទ នៅមានសង្ឃឹម ជានិច្ចថា ព្រះអង្គនឹងទទួលបាត្រវិញ ទៅទីនេះ នៅទីនោះ មិនខាន បន្តិចមកសេចក្ដីសង្ឃឹមនោះ ក៏រលាយបាត់អស់ ព្រះនន្ទចង់ត្រឡប់វិញណាស់ តែដោយសេចក្ដីខ្លាច និង គោរពព្រះសាស្ដា ក៏ស៊ូទ្រាំកាន់បាត្រតទៅ ។ ព្រះបរមគ្រូ ទ្រង់នាំព្រះនន្ទទៅកាន់មហាវិហារ ហើយសួរថា នែនន្ទ ! អ្នកបួសឬ ? ព្រះនន្ទមិនហ៊ានប្រកែក ឆ្លើយថា ខ្ញុំព្រះអង្គ នឹងបួស ព្រះសាស្ដា ទ្រង់ឲ្យភិក្ខុទាំងឡាយបំបួស មិនយូរ ប៉ុន្មាន ព្រះនន្ទអផ្សុកចង់ចាកសិក្ខាបទ ក៏ប្រាប់ដល់ភិក្ខុ

ទាំងឡាយ ។ **ព្រះសម្ពុទ្ធ**ទ្រង់ជ្រាប ហើយទើបត្រាស់ហៅព្រះនន្ទមកសួរ ព្រះនន្ទក្រាបទូលដោយត្រង់ថា ពេលចេញពីដំណាក់ នាងជនបទកល្យាណីស្រែកផ្តាំថា សូមព្រះអយ្យបុត្ត មកវិញឆាប់ៗ ណា៎ ។

ព្រះសាស្តាទ្រង់ចាប់ដើមដៃព្រះនន្ទ ហើយនាំទៅកាន់ឋានតាវត្តិង្សទេវលោក នៅក្នុងចន្លោះផ្លូវព្រះអង្គទ្រង់និម្មិតឲ្យព្រះនន្ទឃើញមេស្វាមួយ របោចរោម មានត្រចៀកប្រមុះដាច់ កំបុតកន្ទុយ អង្គុយលើជន្លត់ឈើមួយដែលភ្លើងឆេះ ។ ទើបព្រះអង្គទ្រង់សំដែង ឲ្យឃើញទេពអប្សរ ៥០០ ដែលមានជើងដូចជើងព្រាប ត្រឡប់មកពីបម្រើព្រះឥន្រ្ទទើបត្រាស់សួរ ថានៃនន្ទ ! អ្នកសម្គាល់ទិដ្ឋភាពនេះ ដូចម្តេច ? តើនាងជនបទកល្យាណី នឹងស្រីទេពអប្សរ ៥០០ អ្នកណារូបរាងល្អស្អាត គួរមៀងមើល គួរជ្រះថ្លាជាង ? ព្រះនន្ទក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន នាងជនបទកល្យាណីប្រៀបធៀបមិនបានមួយចំណិត ឬមួយចំណែកនៃស្រី

ទេពអប្សរទាំង ៥០០ នោះឡើយ គឺប្រៀបដូចមេស្វា ដែលខ្ញុំព្រះអង្គទើបបានឃើញមុនហ្នឹងឯង ។

រឿងព្រះនន្ទ ខ្ញុំបាទសូមស្ទះទុកតែប៉ុណ្ណេះចុះ សូមអញ្ជើញ អ្នកអានជួយពិភាក្សា វាយតម្លៃដូចតទៅ ៖

**ជនបទកល្យាណី** ជាពាក្យបាលី **បើប្រែជាខ្មែរថា** ស្រីអ្នកមានលំអក្នុងជនបទ **បានសេចក្ដីថា** នៅក្នុងជនបទជាស្ត្រីល្អជាងគេ ល្អជាច់គេ ល្អលើសគេ គឺគ្មានស្ត្រីណាម្នាក់ស្អាតស្មើ ភាសាយើងសព្វថ្ងៃអាចពោលថា " បវរកញ្ញាឯក " មិនដឹងថា ល្អយ៉ាងទេហ្ន៎ ?

ព្រះនន្ទជាយុវក្សត្រ នៅពេលដែលឮពាក្យពោលផ្ដាំរបស់នាងជនបទកល្យាណី តើរាគចិត្តពុះកញ្ជ្រោលយ៉ាង-ណា តើបាត្រព្រះបរមសាស្ដា ចំពោះព្រះនន្ទកាន់ មានទម្ងន់ប៉ុនណាទៅ ? តើព្រះនន្ទចង្អៀតចង្អល់យ៉ាងណា ? ពេលដែលព្រះសាស្ដា ទ្រង់មិនទទួលយកបាត្រវិញនោះ ។ ព្រះ-នន្ទកើតទុក្ខលំបាកចិត្តថែមទៀត ព្រោះការបួសដោយគ្មានសទ្ធា គឺបួសដោយមិនហ៊ានប្រកែកនឹងព្រះអង្គ ។ លុះបាន

បួសហើយចង់សឹកវិញ ព្រះអង្គទ្រង់នាំទៅទេវលោក បាន ឃើញមេស្វា ឃើញពួកទេវកញ្ញា ស្រាប់តែដកចិត្ត ហើយ ប្រៀបនាងជនបទកល្យាណីថា ដូចមេស្វា ហើយញ៉ាំងចិត្ត ឲ្យជាប់ស្អិតស្អិទ្ធស្នេហ៍ចំពោះពួកទេពអប្សរ ថែមទាំងសន្យា ថា ប្រសិនណាបើព្រះអង្គជានាឲ្យបានស្រីទេពធីតា ខ្ញុំព្រះ-អង្គនឹងខំប្រព្រឹត្តព្រហ្មចរិយធម៌ ។

សូមអស់លោកអ្នកអាន ជួយផ្តល់តម្លៃមកមើលថា តើបវរកញ្ញានៅនាស្រុកមនុស្ស ( នាងជនបទកល្យាណី ) នឹងពួកកញ្ញាជម្ពូតា ( ទេវកញ្ញា ) ក្នុងស្ថានទេវលោក ល្អស្អាតខុសគ្នាប៉ុនណា ? បានជាព្រះនន្ទ ភ្លេចអស់នូវ អនុស្សាវរីយ៍ ដែលបានសាងជាមួយនាងជនបទកល្យាណី ? ។

ការលើកហេតុផលមកប៉ុណ្ណេះ **ដើម្បីបញ្ជាក់ថា** ការ សេពនូវឥដ្ឋារម្មណ៍ ក្នុងស្ថានសួគ៌ទេវលោក នាំសត្វឲ្យ ត្រេកត្រអាល សប្បាយរីករាយ ភ្លើតភ្លើន ដោយកាមគុណ ដ៏ខ្លាំងក្លាជាអតិបរមា ខុសពីឋានមនុស្សឆ្ងាយណាស់ ។ ល ។

# ស្ថានសួគ៌ ២៦ ជាន់

## ក~ចាតុម្មហារាជិកា

*ដែលហៅថា* **ចាតុម្មហារាជិកា** *គឺភពជាទីនៅនៃមហារាជទាំង ៤ ព្រះអង្គ ៖*

**-ស្តេចធតរដ្ឋៈ** = *គ្រប់គ្រងពួកគន្ធព្វ នៅទិសខាងកើតភ្នំសិនេរុ*

**-ស្តេចវិរុឡ្ហកៈ** = *គ្រប់គ្រងពួកកុម្ភណ្ឌ នៅទិសខាងត្បូងភ្នំសិនេរុ*

**-ស្តេចវិរូបក្ខៈ** = *គ្រប់គ្រងពួកនាគ នៅទិសខាងលិចភ្នំសិនេរុ*

**-ស្តេចកុវេរៈ ឬវេស្សវ័ណ** = *គ្រប់គ្រងពួកយក្ស នៅទិសខាងជើងភ្នំសិនេរុ ។*

*ទេវភូមិចាតុម្មហារាជិកានេះ តាំងនៅពាក់កណ្តាលភ្នំសិនេរុ លើកំពូលភ្នំសត្តបរិភណ្ឌ ( ភ្នំ ៧ ជួរ ព័ទ្ធជុំវិញ*

ភ្នំសិនេរុ ) គឺភ្នំ យុគន្ធរៈ ឥសិន្ធរៈករវិកៈ សុទស្សនៈ នេមិន្ធរៈ វិនតកៈ និងភ្នំអស្សកណ្ណៈ ។ នៅចន្លោះភ្នំទាំង ៧ នេះ មានមហាសមុទ្រ ឈ្មោះសីតន្តរៈ ដែលមានទឹកថ្លាល្អិត ថ្លាក្រៃលែងណាស់ មានទំហំ និងជម្រៅខាងក្នុងធំ ហើយជ្រៅ ឯខាងក្រៅតូចរាក់ តាមលំដាប់ ។ ក្រោមផុតពីភ្នំ ៧ នេះ មានមហាសមុទ្រទឹកប្រៃ មានកោះធំៗ ៤ ស្ថិតនៅជុំវិញភ្នំសិនេរុ កោះនោះឯង ហៅថា មហាទ្វីប ៤ ។

*ទេវតាដែលនៅក្រោមការគ្រប់គ្រង របស់ស្តេចចាតុម្មហារាជិកា មានច្រើនពួក ដូចជា :*

-**បព្វតដ្ឋទេវតា** = ទេវតាដែលអាស្រ័យនៅតាមភ្នំ

-**អាកាសដ្ឋទេវតា** = ទេវតាដែលអាស្រ័យនៅលើអាកាស

-**ខិឌ្ឌាបទោសិកទេវតា** = ទេវតាច្យុត ព្រោះភ្លើតភ្លើនក្នុងការលេងកីឡា ( កាមគុណ ) ភ្លេចបរិភោគអាហារ

-**មនោបទោសិកទេវតា** = ទេវតាដែលច្យុត ព្រោះសេចក្តីក្រោធ

~**សីតវលាហកទេវតា** = ទេវតាដែលធ្វើអាកាសធាតុឲ្យត្រជាក់

~**ឧណ្ហវលាហកទេវតា** = ទេវតាដែលធ្វើអាកាសធាតុឲ្យក្ដៅ

~**ចន្ទិមទេវបុត្រ** = ទេវបុត្រដែលនៅក្នុងព្រះចន្ទ

~**សុរិយទេវបុត្រ** = ទេវបុត្រដែលនៅក្នុងព្រះអាទិត្យ ។

**មានទេវតាដែលកាចសាហាវ ៤ ពួក ទៀត ៖**

- **យក្ខោ យក្ខិនី** = យក្សប្រុស យក្សស្រី
- **គន្ធព្វោ គន្ធព្វី** = គន្ធព្វប្រុស គន្ធព្វស្រី
- **កុម្ភណ្ឌោ កុម្ភណ្ឌី** = កុម្ភណ្ឌប្រុស កុម្ភណ្ឌស្រី
- **នាគោ នាគី** = នាគឈ្មោល នាគញី ។

សូមបញ្ជាក់ថា មហារាជទាំង ៤ សុទ្ធតែមានឫទ្ធានុភាពច្រើន អំណាចខ្លាំងក្លា មានបរិវារច្រើន មានឱរសមួយអង្គមួយពាន់ មានមាមថា ឥន្ទៈ ដូចគ្នាទាំងអស់ ។

អាយុរបស់ទេវតា ក្នុងឋានចាតុម្មហារាជិកា ៥០០ ឆ្នាំទិព្វ **គិតជាឆ្នាំមនុស្សគឺ**

- មួយថ្ងៃទិព្វ ស្មើនឹង ៥០ ឆ្នាំមនុស្ស
- មួយខែទិព្វ ស្មើនឹង ១,៥០០ ឆ្នាំមនុស្ស
- មួយឆ្នាំទិព្វ ស្មើនឹង ១៨,០០០ ឆ្នាំមនុស្ស
- ប្រាំរយឆ្នាំទិព្វ ស្មើនឹង ៩ លានឆ្នាំមនុស្ស

## ខ~តាវត្តិង្ស

តាវត្តិង្ស ជាទេវស្ថានជាន់ទី ២ ជាទីកើតនៃគណៈសហបុញ្ញការី ( ក្រុម ឬពួកបុរសអ្នកធ្វើបុណ្យរួមគ្នា ) ៣៣ នាក់ ដែលមានមឃមាណពជាប្រធាន នាំគ្នាធ្វើបុណ្យសុទ្ធទាន មានជម្រះសម្អាតផ្លូវ សម្រាប់ធ្វើចរាចរ ធ្វើរោងស្នាក់ តម្កល់ពាងទឹក ក្នុងផ្លូវកន្តារៈ និងសាងសាលា ១ ខ្នង នៅលើផ្លូវបែកជា ៤ សម្រាប់អ្នកដំណើរសម្រាក ។ល។

បុរសទាំង ៣៣ នាក់ លុះក្ស័យជីវិត ទៅកើតក្នុងឋានតាវត្តិង្ស មានទំហំផ្ទៃក្រឡា ១ ម៉ឺនយោជន៍ តាំងនៅលើ

កំពូលភ្នំសិនេរុ កម្ពស់ ៨៤,០០០ យោជន៍ ក្នុងឋានទេះ ក៏មានកុម្ភទេវតា និងអាកាសទេវតា ឯពួកអសុរ មានស្តេច វេបចិត្តជាដើម ដែលស្ថិតនៅក្រោមភ្នំសិនេរុ ក៏រាប់បញ្ចូល ក្នុងកុម្ភទេវតាដែរ ទេវតា ២ ពួកនេះ មានវិមានតៗ គ្នា រហូតដល់ភ្នំចក្រវាល ។ នគរនេះ មានកំពែង ៤ ទិស ក្នុង ទិសនីមួយ ៗ មានទ្វារ ២៥០ មានរមណីយដ្ឋានជា ច្រើន ដូចជាសួនបុណ្ឌរិកៈ សួនមហាវ័ន ស្រះបោក្ខរណី ដែលឋិត នៅចំកណ្តាលទីក្រុង មានប្រាសាទមាសឈ្មោះ ពេជយ័ន្ត កម្ពស់ ១,០០០ យោជន៍ ប្រកបដោយរតនៈ ៧ ប្រការ កម្ពស់ ៣០០ យោជន៍ ជាទីប្រថាប់នៃសក្កទេវរាជ មានដើម បារិច្ឆត្តព្រឹក្ស កម្ពស់ ១០០ យោជន៍ មែកបែកចេញទៅ ៥០ យោជន៍ ជាបរិមណ្ឌលជុំវិញ ៣០០ យោជន៍ មានផ្កា ក្លិន ផ្សាយទៅ ១,០០០ យោជន៍ ។ នៅខាងក្រោមដើម បារិច្ឆត្តព្រឹក្ស មានព្រះទែនបណ្ឌុកម្ពលសិលាសនៈ សម្បុរ ដូចផ្កាជយព្រឹក្ស ពណ៌លក្ខ និងពណ៌ផ្កាឈូក រុះរោយ ទទឹង និងបណ្តោយ ៥០ យោជន៍ កម្ពស់ ១៥ យោជន៍

ជាទីប្រជាប់នៃសក្កទេវរាជ ។ មានសាលាជាទីប្រជុំស្តាប់ព្រះធម៌ ។ មានចូឡាមណីចេតិយ ជាវិការៈនៃកែវមរកត កម្ពស់ ១០០ យោជន៍ ជាទីបញ្ចុះនៃព្រះទាឋធាតុខាងស្តាំ និងព្រះកេសធាតុ ដែលព្រះអង្គទ្រង់កាត់ នាថ្ងៃចេញបួស ។ ដំរីឰរាវ័ណទេវបុត្រ ទំហំ ១៥០ យោជន៍ មានក្បាល ៣៣ ក្បាលមួយៗ មានភ្លុក ៧ ។ ៣៣ គុណនឹង ៧ ស្មើនឹង ២៣១ ។ ភ្លុកមួយៗ ប្រវែង ៥០ យោជន៍ មានស្រះបោក្ខរណី ៧ ។ ២៣១ គុណនឹង ៧ ស្មើ នឹង ១,៦១៧ ។ ស្រះបោក្ខរណីមួយៗ មានឈូក ៧ គុម្ព ។ ១,៦១៧ គុណនឹង ៧ ស្មើនឹង ១១,៣១៩ ។ គុម្ពនីមួយៗ មាន ផ្កាឈូក ៧ ។ ១១,៣១៩ គុណនឹង ៧ ស្មើនឹង ៧៩,២៣៣ ។ ផ្កាមួយៗ មានត្របក ៧ ។ ៧៩,២៣៣ គុណនឹង ៧ ស្មើនឹង ៥៥៤,៦៣១ ។ ក្នុងស្រទាប់ត្របកមួយៗ មានទេពធីតា ៧ អង្គ ។ ៥៥៤,៦៣១ គុណនឹង ៧ ស្មើនឹង ៣,៨៨២,៤១៧ ។ ទេវកញ្ញាទាំងនេះ ជានាដកា រាំច្រៀងថ្វាយព្រះឥន្ទ្រាធិរាជ ឬព្រះឥន្ទ្រាធិរាជ ទ្រង់ទត តាមភ្លុកដំរី ទាំង ២៣១ នោះ

ឯង ។ នៅលើពោនដីរ ឯកវណ៌ត្រង់កណ្ដាលក្បាល ឈ្មោះថា សុទស្សនៈ មានមណ្ឌបកម្ពស់ ១២ យោជន៍ , ទទឹង ៥០ យោជន៍ ក្នុងមណ្ឌបនោះ មានបល្ល័ង្កកែវមណី ទទឹង ១ យោជន៍ ជាទីគង់ប្រថាប់នៃព្រះឥន្ទ្រាធិរាជ នៅជុំវិញមណ្ឌប ។ មានទង់ជោតជិតៗ គ្នា ទង់មួយប្រវែង ១ យោជន៍ មានកណ្ដឹង ស្ទឹកពោធិ៍ ចងព្យួរគ្រប់ចុងទង់ទាំងអស់ ពេលត្រូវខ្យល់បក់មក ឮសូរពីរោះដូចពិណ ។

ព្រះឥន្ទ្រ មានអគ្គមហេសី ៤ ព្រះអង្គ គឺនាងសុជាតា ១ , នាងសុធម្មា ១ , នាងសុនន្ទា ១ , នាងសុចិត្រា ១ ។ មានស្នំ ២ កោដិ កន្លះ ។

## សាលាសុធម្មា

សាលាសុធម្មានេះ ប្រដាប់ដោយរតនៈ ៧ ប្រការ កម្ពស់ ៥០០ យោជន៍ ទទឹង ៣០០ យោជន៍ វាស់ជុំវិញ ១,២០០ យោជន៍ , ផ្ទៃសាលាជាវិការៈនៃកែវផលិក , សសរជាមាស , មេដំបូល ផ្ដោង ផ្ទាន បង្កង់ ដៃរណែង និងដំបូលពិតានជាដើម សុទ្ធតែរតនៈ ទាំង ៧ ប្រការ ,

ដំបូលប្រក់ដោយកែវឥន្ទនិល ,  ពិតាន  និងសសរ  វិចិត្រ រចនាទៅដោយផ្កាភ្ញីផ្សេងៗ  រំលេចដោយកែវប្រពាឡ  , ជហ្វាជង្គា  រំលេចដោយប្រាក់  ,  ក្នុងសាលាចំកណ្ដាល តាំងធម្មាសនៈ  សម្រាប់សម្ដែងធម៌  កម្ពស់  ១  យោជន៍ រំលេចដោយកែវ  ៧  ប្រការ  ប៉ាំងស្វេតច្ឆត្រ  កម្ពស់  ៣ យោជន៍ ,  ស្ថិតនៅក្បែរធម្មាសនៈ  ជាទីគង់ប្រថាប់នៃស្ដេច ព្រះឥន្ទកោសិយទេវរាជ  បន្ទាប់មកជាទីប្រថាប់របស់ទេវតា ៣២  អង្គ  ដែលមានសក្ដានុភាពធំ  តមកទៀត  សម្ដេច បជាបតិ  ស្ដេចវរុណៈ  ស្ដេចព្សាន្ត  តាមលំដាប់  រហូតដល់ ទីនាំងរបស់ទេវតា  មានបណ្ដាសក្ដិ  និងទេវតាជាបរិស័ទ ។ ល ។

សាលាសុធម្មានេះ  តាំងនៅក្បែរដើមបារិច្ឆត្តព្រឹក្ស  , ដើមបារិច្ឆត្តព្រឹក្សនេះ  មួយឆ្នាំចេញផ្កាម្ដង  ,  មុនពេលចេញ ផ្កា  ស្លឹកមានពណ៌ស៊ីទួន  ,  ទេវតាទាំងឡាយ  បានឃើញ ស្លឹកហើយ  ក៏ត្រេកអរដោយគិតថា  នឹងបានហិតផ្កាក្នុង ពេលឆាប់ៗ  នាំគ្នាមកសម្លឹងមើលជានិរន្តរ៍ ,  លុះពេលចេញ

ផ្កា ស្លឹកនោះក៏រង្គោះ ជ្រុះអស់រលីង ចេញសុទ្ធតែផ្កាពណ៌ក្រហមស្អេកស្កះ ជះពន្លឺជុំវិញដើម , បរិមណ្ឌលទទឹង ៥០០ យោជន៍ , ក្លិនក្រអូបតាមខ្យល់ ១០០ យោជន៍ , មិនចាំបាច់ឡើងបេះ ឬថ្តក់ទម្លាក់ទេ មានខ្យល់ឈ្មោះកន្តនៈ បក់ផាត់ញ៉ាំងផ្កាឲ្យរុះធ្លាក់ចុះមកឯង , ពេលផ្ការុះ មានខ្យល់ឈ្មោះ**សម្បដិច្ឆន្នៈ** ទទួលផ្កាមិនឲ្យធ្លាក់ដល់ដី បន្ទាប់មកខ្យល់ឈ្មោះ**បវេសនៈ** បក់ផាត់ផ្កា ឲ្យចូលទៅក្នុង**សាលាសុធម្មា** ទើបមានខ្យល់ ឈ្មោះ**សមដ្ឋនៈ** បក់ផាត់ផ្កានោះចេញ ក្រោយមក ទើបមានខ្យល់ឈ្មោះ**សន្ថរៈ** មាននាទីរៀបចំវិចិត្រផ្កានោះ ឲ្យមានរបៀបរៀបរយ មិនឲ្យគរលើគ្នា ។

លុះដល់ពេលវេលាស្តាប់ធម៌ ឬសន្ទនាធម៌ សម្តេចឥន្ទ្រាធិរាជ ទ្រង់ផ្លុំវិជ្ជយុត្តស័ង្ខ ដែលមានបណ្តោយ ១២០ ហត្ថ ញ៉ាំងសំឡេងឲ្យលាន់ឮកងរំពងទូទៅ ទាំងខាងក្នុងនិងខាងក្រៅនគរ**សុទស្សនៈ** ពេលផ្លុំម្តង សំឡេងនោះ អាចតាំងនៅយូរដល់ ៤ ខែ របស់មនុស្ស ។ ទេវបុត្រ និង

ទេពធីតាទាំងឡាយ ជាន់តាវត្តិង្ស កាលព្រួសសំឡេងនោះ ហើយ ក៏នាំគ្នាមកកាន់**សាលាសុធម្មា** ស្មើចេញពីរាងកាយ និងពីគ្រឿងអាភរណៈ ឬអលង្ការដែលប្រដាប់កាយ ក៏ភ្លឺច្រះទូទាំងសាលា ។

កាលព្រះឥន្ទកោសិយ ទ្រង់ផ្ញុំស័ង្ខប្រកាសដល់ទេវតាទាំងឡាយហើយ ព្រះអង្គ និងអគ្គមហេសី ទាំង ៤ ក៏យាងចេញពី**ប្រាសាទវេជយន្តៈ** ឡើងគង់លើ**ដំរីឯរាវ័ណ** ដោយមានទេវតាហែហមប្រមាណ ៣ កោដិ ៦ លានអង្គ យាងទៅកាន់**សាលាសុធម្មា** ឯអ្នកសម្ដែងធម៌នៅទីនោះ គឺព្រហ្មព្រះនាមសនង្កុមារៈ បានស្ដេចយាងចុះមកសម្ដែងជាប់ជានិច្ច តែពេលខ្លះសម្ដេចព្រះឥន្ទ្រាធិរាជ ទ្រង់សម្ដែងដោយផ្ទាល់ ពុំនោះសោត ទេវបុត្រអង្គណាមួយ ដែលមានប្រតិពល ខាងធម្មវិន័យច្បាស់លាស់ សម្ដែង ។

**សាលាសុធម្មា**នេះ មិនមែនមានតែ**ឋានតាវត្តិង្ស** ទេ សូម្បី នៅទេវលោកខាងលើ ៤ ជាន់ទៀតក៏មានដែរ ។

# ឥដ្ឋារម្មណ៍ក្នុងឋានតាវត្តិង្ស

ទេវតាទាំងឡាយ ដែលបានមកកើតក្នុងឋានតាវត្តិង្ស នេះ សុទ្ធតែសោយទិព្វសម្បត្តិ ដែលជាផលនៃកុសលកម្ម ពីអតីតជាតិ ទេវបុត្រ ទេពធីតា មានរូបរាង លក្ខណៈ សណ្ឋាន ទ្រង់ទ្រាយ ឋិតនៅជាកំលោះ ក្រមុំ ជារៀងរហូត មិនមានចាស់ជរា សក់ស្កូវ ធ្មេញបាក់ ភ្នែកងងឹត ត្រចៀកថ្លង់ សាច់ស្បែកជ្រីវជ្រួញឡើយ មានតែការស្អាតបាតជានិច្ច ។ អាហារដ៏ល្អិត ជាសុទ្ធាភោជន ទើបពួកទេវតាមិនមានឧច្ចារៈ បស្សាវៈ មិនមានរដូវប្រចាំខែ និងមិនមានគភ៌ ។ តែមានទេវតាស្រីពួកខ្លះ ក៏មានរដូវ និងមានគភ៌ ដូចមនុស្សដែរ ។ បុត្រធីតា កើតលើភ្លៅនៃទេវតាទាំងឡាយ ។ ទេវតាអង្គខ្លះ មានទេពអប្សរជាបាទបរិចារិកា ៥០០ , ៧០០ , ១,០០០ អង្គ ។ ទេវតាច្រើនណាស់ ដែលគ្មានវិមានផ្ទាល់ខ្លួនអាស្រ័យនៅ ។ ក្នុងទេវលោកនេះ មាន-ការប្រព្រឹត្តទៅដោយការវិវាទគ្នា មានក្រុមប្រឹក្សាកាត់ក្តី និងសាកសួរសុខទុក្ខគ្នា ដូចស្រុកមនុស្សដែរ ។ ទេពធីតាអង្គខ្លះ

មានវិមាននៅផ្ទាល់ខ្លួន តែគ្មានគូគ្រង មានសេចក្តី នឿយ-ណាយ មិនសប្បាយរីករាយ ដូចជាទេពកញ្ញាដែល មានគូ-គ្រងឡើយ ព្រោះទេពធីតាដែលមានគូគ្រង គេតែងនាំគ្នារួមទាំងបរិវារ ទៅលេងកម្សាន្តតាមឧទ្យាននានា ។ល។

រស្មីចេញពីកាយ អាភរណៈ ភូសា គ្រឿងអលង្ការ និងវិមានរបស់ទេវបុត្រ ទេពធីតាអង្គខ្លះ មាន ១២ យោជន៍ , ខ្លះ ១០០ យោជន៍ ។ ទេវតាជាន់លើ អាចមើលទេវតាជាន់ក្រោមឃើញ ឯទេវតាជាន់ទាប មិនអាចឃើញទេវតាជាន់ខ្ពស់ឡើយ ។

**ឋានតាវត្តិង្ស** មានសុទ្ធតែឥដ្ឋារម្មណ៍ទាំងអស់ ទេវបុត្រទេពធីតា សោយទិព្វសម្បត្តិ ឥតមានវត្ថុស្មោកគ្រោកបដិកូល ដែលហូរចេញពីទ្វារទាំង ៩ សូម្បីតិចតួចឡើយ ។ ទេវតាទាំងឡាយ កាលបើជុំភ្លឹនមនុស្សប្រមាយ ១០០ យោជន៍ សូម្បីស្តេចចក្រពត្តិស្រង់ទឹក ១ ថ្ងៃ ២ ដង ផ្លាស់ប្តូរព្រះភូសា ៣ ដង ស្អិតស្អាងរាងកាយដោយគ្រឿង

ក្រអូបយ៉ាងណា ក៏ទេវតាជុំក្លិនស្អុយ ដូចខ្មោចសុនខដែលជាប់ទឹងក ។

មួយទៀត បណ្តាសួនឧទ្យានក្នុង**ឋានតាវត្តិង្ស**ទាំងអស់ **ឧទ្យាននន្ទវ័ន** ប្រកបដោយឥដ្ឋារម្មណ៍លើសគេ គឺថា ប្រសិនបើទេវបុត្រ ទេពធីតា អង្គណាមានទុក្ខ សោកៈ បរិទេវៈ ខ្លាចសេចក្តីស្លាប់ កាលបើបានចូលទៅក្នុង**ឧទ្យាននន្ទវ័ន** សេចក្តីទុក្ខ សោកៈ បរិទេវៈ ក៏រសាត់បាត់អស់ ។

ឯ**នន្ទវនុទ្យាន**នេះ មិនមែនមានតែក្នុង**ឋានតាវត្តិង្ស** ប៉ុណ្ណោះទេ ស្ថានសួគ៌ផ្សេងៗ ទៀតក៏មានដែរ ។ ព្រោះជាទីសប្បាយរីករាយ ក្តីតក្តីនយ៉ាងខ្លាំង ។ ក្នុងឧទ្យានមួយៗ មានដើមឈើទិព្វ ១០០០ ដើម ។ នៅក្នុង**សួនសុចិត្រា** មានដើមឈើ មានពូជអំបូរឈ្មោះ**អាសាវតី** ១,០០០ ឆ្នាំ **ឋានតាវត្តិង្ស** ទើបមានផ្កាផ្លែម្តង នៅក្នុងផ្លែមានទឹកទិព្វៗ ក្នុងផ្លែនោះឯង ជាសុរានៃទេវតា**ឋានតាវត្តិង្ស** ទេវតាអង្គខ្លះ

ពេលផឹកទឹកសុរានោះ ស្រវឹងក៏ដេកលក់អស់ ៤ ខែ ទើបស្វាង ។

# សេវនកិច្ចក្នុងឋានសួគ៌ ២៦ ជាន់

ស្ថានសួគ៌ ២៦ ជាន់ ដែលបានពោលខាងលើ ចែកជា ៣ ពួកគឺ **កាមាវចរ** ១ , **រូបាវចរ** ១ , **អរូបាវចរ** ១ ។ ប្រាំមួយជាន់ខាងដើម ជា**កាមាវចរ** នៅមានចិត្តជាប់ជំពាក់នឹងកាមារម្មណ៍ មានសេវនកិច្ចគ្រោតគ្រាត និងល្អិតជាងគ្នាជាលំដាប់ៗ គឺ **ចាតុម្មហារាជិកា តាវត្តិង្ស** សម្រេចកាមសេវនកិច្ច ដោយរួមប្រវេណី ដូចមនុស្ស ។ ជាន់**យាមា** សម្រេចកាមសេវនកិច្ច ដោយការស្ទាបអង្អែល ។ ជាន់**តុសិត** សម្រេចកាមសេវនកិច្ច ដោយការចាប់ដៃ ។ ជាន់**និម្មានរតី** សម្រេចកាមសេវនកិច្ច ដោយញញឹមទទួលគ្នា ។ ជាន់**បរនិម្មិតវសវត្តី** សម្រេចកាមសេវនកិច្ច ដោយការសម្លឹងមើលគ្នាប៉ុណ្ណោះ តែមិនមានសុក្កសម្ភវៈទេ ។

## គ~យាមា

យាមាទេវតា = ទេវតាអ្នកទៅ គឺគេចចៀសទៅពីទុក្ខ ដល់នូវទិព្វសុខ ។

ទេវតាជាន់ទី ៣ នេះ មានស្តេចព្រះនាម**សុយាមៈ** ជាអ្នកគ្រប់គ្រង មានអាយុ ២,០០០ ឆ្នាំទិព្វ **គិតជាឆ្នាំមនុស្សគឺ**

- ១ ថ្ងៃ ( យាមា ) ស្មើនឹង ២០០ ឆ្នាំមនុស្ស
- ១ ខែ ( យាមា ) ស្មើនឹង ៦,០០០ ឆ្នាំមនុស្ស
- ១ ឆ្នាំ ( យាមា ) ស្មើនឹង ៧២,០០០ ឆ្នាំមនុស្ស
- ២,០០០( យាមា ) ស្មើនឹង ១៤៤ លានឆ្នាំមនុស្ស ។

## ឃ~តុសិតា

**តុសិតាទេវតា** = ទេវតាអ្នកត្រេកអររីករាយ ទេវតាជាន់ទី ៤ នេះ មានអាយុ ៤,០០០ ឆ្នាំទិព្វ **គិតជាឆ្នាំមនុស្សគឺ**

- ១ ថ្ងៃ ( តុសិតា ) ស្មើនឹង ៤០០ ឆ្នាំមនុស្ស
- ១ ខែ ( តុសិតា ) ស្មើនឹង ១២,០០០ ឆ្នាំមនុស្ស
- ១ ឆ្នាំ ( តុសិតា ) ស្មើនឹង ១៤៤,០០០ ឆ្នាំមនុស្ស

- ៤,០០០ ឆ្នាំ ( តុសិតា ) ស្មើនឹង ៥៧៦ លានឆ្នាំមនុស្ស ។

## ខ~និម្មានរតី

**និម្មានរតីទេវតា** = ទេវតាដែលអាចនិម្មិត កាមភោគៈតាមបំណង ហើយត្រេកអរលើអារម្មណ៍ ដែលបុណ្យបានតាក់តែង ។ ទេវតាជាន់ទី ៥ នេះ មានអាយុ ១៦,០០០ ឆ្នាំទិព្វ **គិតជាឆ្នាំមនុស្សគឺ**

- ១ ថ្ងៃ ( និម្មានរតី ) ស្មើនឹង ៨,០០០ ឆ្នាំមនុស្ស
- ១ ខែ ( និម្មានរតី ) ស្មើនឹង ២៤,០០០ ឆ្នាំមនុស្ស
- ១ ឆ្នាំ ( និម្មានរតី ) ស្មើនឹង ២៨៨,០០០ ឆ្នាំមនុស្ស
- ៨,០០០ ឆ្នាំ ( និម្មានរតី ) ស្មើនឹង ២,៣០៤ លានឆ្នាំមនុស្ស ។

## ច~បរនិម្មិតវសវត្តី

**បរនិម្មិតវសវត្តី** = ទេវតាដែលមានអំណាចក្នុង កាម-ភោគៈ ដែលទេវតាពួកដទៃ ដឹងវារចិត្តហើយនិម្មិតឲ្យ ។

*ទេវតាជាន់ទី ៦ នេះ មានអាយុ ១៦,០០០ ឆ្នាំទិព្វ* **គិតជាឆ្នាំមនុស្សគឺ**

*- ១ ថ្ងៃ ( បរនិម្មិតវសវត្តី ) ស្មើនឹង ១,៦០០ ឆ្នាំមនុស្ស*

*- ១ ខែ ( បរនិម្មិតវសវត្តី ) ស្មើនឹង ៤៨,០០០ មនុស្ស*

*- ១ ឆ្នាំ ( បរនិម្មិតវសវត្តី ) ស្មើនឹង ៥៧៦,០០០ ឆ្នាំមនុស្ស*

*- ១,៦០០ ឆ្នាំទិព្វ ( បរនិម្មិតវសវត្តី ) ស្មើនឹង ៩,២១៦ ឆ្នាំមនុស្ស ។*

**ចប់ ឆកាមាវចរសួគ៌ ។**

# រូបព្រហ្ម ១៦ ជាន់

**ក-ព្រហ្មបរិសជ្ជា** *= ព្រហ្មបរិស័ទ គឺជាអ្នកបម្រើមហាព្រហ្ម មានអាយុមួយភាគបី នៃវិវដ្ដដ្ឋាយីអសង្ខេយ្យកប្ប ។*

**ខ-ព្រហ្មបុរោហិតា** *= ព្រហ្មពួកនេះ ជាបុរោហិតនៃមហាព្រហ្ម មានអាយុពាក់កណ្ដាលវិវដ្ដដ្ឋាយីអសង្ខេយ្យកប្ប ។*

**គ~មហាព្រហ្មា** = ព្រហ្មពួកនេះ ជាព្រហ្មធំជាងព្រហ្ម-បរិសជ្ជាជាដើម ដោយវណ្ណៈ អាយុយឺនយូរ មួយវិវដ្ដដ្ឋាយី-អសង្ខេយ្យកប្ប ។

**ឃ~បរិត្តាភា** = ព្រហ្មពួកនេះ មានរស្មីតិចជាងព្រហ្មទាំងឡាយ ខាងលើ អាយុ ២ មហាកប្ប ។

**ង~អប្បមាណាភា** = ព្រហ្មពួកនេះ មានពន្លឺរស្មីប្រមាណពុំបាន មានអាយុ ៤ មហាកប្ប ។

**ច~អាភស្សរា** = ព្រហ្មពួកនេះ មានពន្លឺរស្មីផ្សាយទៅដូចផ្លេកបន្ទោរ ជះពន្លឺចេញពីពពក មានអាយុ ៨ មហាកប្ប ។

**ឆ~បរិត្តសុភា** = ព្រហ្មពួកនេះ មានរស្មីល្អជាងព្រហ្មខាងលើ មានអាយុ ១៦ មហាកប្ប ។

**ជ~អប្បមាណសុភា** = ព្រហ្មពួកនេះ មានរស្មីល្អប្រមាណពុំបាន មានអាយុ ៣២ មហាកប្ប ។

**ឈ~សុទស្សិណ្ហា** = ព្រហ្មពួកនេះ មានពន្លឺរស្មីដ៏ល្អ ព្រោងព្រាតច្បាស់ថ្លៃង ជះផ្សាយទូទៅ មានអាយុ ៦៤ មហាកប្ប ។

**ញ~វេហប្ផលា** = ព្រហ្មពួកនេះ មានផលដ៏បរិបូណ៌ វិសេសវិសាល មានអាយុ ៥០០ មហាកប្ប ។

**ដ~អសញ្ញីព្រហ្ម** = ព្រហ្មជាន់នេះ ពុំមានសញ្ញាសោះឡើយ ។ បុញ្ញកម្ម កាលមានអត្តភាពជាមនុស្ស បានបួសក្នុងសាសនាណាមួយ ពិចារណាឃើញទោសនៃរាគៈ ទោសៈ មោហៈ ថា សុទ្ធតែកើតអំពីចិត្ត ទើបតាំងចិត្តកំណត់ចិត្ត ជាប់និរន្តរ៍ថា ចិត្តមិនមាន ដរាបដល់ឯកគ្គតាចិត្ត ហើយបានសម្រេចឈាន ។ លុះក្ស័យជីវិត ទៅកើតជាអសញ្ញីព្រហ្ម មានតែរូប ឥតមានវេទនា សញ្ញា សង្ខារ វិញ្ញាណ កាលដែលស្លាប់ក្នុងឥរិយាបថណា ក៏ទៅកើតជាព្រហ្មក្នុងឥរិយាបថនោះ រហូតដល់ច្យុត ពេលច្យុត មានសញ្ញាកើតមុន ទើបច្យុត ។ ព្រហ្មពួកនេះ មានអាយុ ៥០០ មហាកប្ប ។

**ច-អវិហា** = *ព្រហ្មមិនសាបសូន្យចាកសម្បត្តិ របស់ខ្លួន មានអាយុ ១,០០០ មហាកប្ប ។*

**ឆ-អតប្បា** = *ព្រហ្មមិនធ្វើឲ្យអ្នកដទៃក្ដៅក្រហាយ មានអាយុ ២,០០០ មហាកប្ប ។*

**ជ-សុទស្សា** = *ព្រហ្មដែលមានរូបល្អឆើត គួរទស្សនា មានអាយុ ៤,០០០ មហាកប្ប ។*

**ឈ-សុទស្សី** = *ព្រហ្មដែលមានសេចក្ដីយល់ឃើញដ៏ល្អប្រពៃ មានអាយុ ៨,០០០ មហាកប្ប ។*

**ញ-អកនិដ្ឋ** = *ព្រហ្មពួកនេះ ជាអ្នកមានសម្បត្តិដ៏ឧក្រិដ្ឋគ្រប់បែបយ៉ាង មានអាយុ ១,៦០០ មហាកប្ប ។*

## អរូបព្រហ្ម ៤ ជាន់

**ក-អាកាសានញ្ចាយតនៈ** = *អាយតនៈ គឺអាកាសមិនមានទីបំផុត ។*

***បានសេចក្ដីថា*** *កាលលោកនៅមានអត្តភាពជាមនុស្ស ចម្រើនអរូបជ្ឈាន សម្លឹងមើលអាកាស ពង្រីកកសិណថា*

អាកាសមិនមានទីបំផុតៗ ។ ព្រហ្មពួកនេះ មានអាយុ ២ ម៉ឺនមហាកប្ប ។

**ខ~វិញ្ញាណញ្ចាយតនៈ** = អាយតនៈ គឺវិញ្ញាណមិនមានទីបំផុត ។ កាលលោកចម្រើនអរូបជ្ឈាន សម្លឹងឃើញចិត្តវិញ្ញាណថា មិនមានទីបំផុត ។ ព្រហ្មពួកនេះ មានអាយុ ៤ ម៉ឺនមហាកប្ប ។

**គ~អាកិញ្ចញ្ញាយតនៈ** = អាយតនៈ គឺអ្វីតិចតួចមិនមាន ។ កាលលោកចម្រើនអរូបជ្ឈាន សម្លឹងអាកាស និងវិញ្ញាណថា មិនមានអ្វីជាតួខ្លួន ហើយប្រកាន់ថា មិនមានអ្វីជាអារម្មណ៍ ។ ព្រហ្មពួកនេះ មានអាយុ ៦ ម៉ឺន មហា-កប្ប ។

**ឃ~នេវសញ្ញានាសញ្ញាយតនៈ** = អាយតនៈ គឺមានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែន ការចម្រើនអរូបជ្ឈាននេះ មានវិថីចិត្តល្អិតជាទីបំផុត ។ ព្រហ្មពួកនេះមានអាយុ ៨ ម៉ឺន ៤ ពាន់មហាកប្ប ។

## ការសម្តែងអំពីភូមិឋាន ៣១ ជាន់

## ចប់ ដោយសង្ខេប ។

# នាទីកំណាព្យព្រះធម៌
# ធម្មនិយាម ៣០
# របស់ព្រះពុទ្ធគ្រប់ព្រះអង្គ

សូមក្រាបបង្គំប្រណម្យវន្ទា ឆ្ពោះព្រះភគវាពុទ្ធាបានត្រាស់
ធម្មនិយាមទំនៀមល្អល្អះ សាមសិបមុខច្បាស់ខ្ញុំសូមពណ៌នា ។
មួយរញ្ជួយភពជាតិគ្រប់ចុងក្រោយ បារមីនាំឱ្យដឹងពេលវេលា
ទ្រង់យាងកាន់ផ្ទៃស្មារតីល្អជា ដឹងខ្លួនគ្រប់គ្រាក្នុងគភ៌មាតា ។
ពីរគឺព្រះភក្ត្រវរលក្ខណ៍ក្នុងគភ៌ ស្ថិងស្មាធិ៍ក្នុងធម៌បវរកាយា
ព្រះភក្ត្របែរផ្ទុយពីខ្នងមាតា ឆ្ពោះផ្ទៃភ្លឺថ្លាមាតារំពៃ ។
បីឥរិយាបថនៃព្រះមាតា ពេលគ្រប់មាសាសាស្តាចាកផ្ទៃ
មាតាទ្រង់ឈរខុសស្រីដទៃ ប្រសូតបុត្រថ្ងៃហបូទ័យជ្រះថ្លា ។
បួនសួនឧទ្យានទីឋានប្រសូត ក្នុងព្រៃរហូតឈើស្រូតចេញផ្កា
ទេវតានិងមនុស្សថ្វាយសាធុការ ចក្រវាលបព្វតាខ្ទ័រខ្ទារអ៊ូអរ ។
ប្រាំព្រះប្រសូតចុះស្រូតយាងឈាន ប្រាំពីរជំហានឆ្ពោះទិសឧត្តរ
ត្រួតគ្រប់ទិសឋានក្លាហានបវរ ទើបបានបន្លឺសីហនាទ ។

ប្រាំមួយប្រមើលទតមើលនិមិត្ត　　ទេវទូតបួនពិតចិត្តគិតលះញាតិ
បុត្រកើតថ្ងៃណាថ្ងៃនោះទ្រង់ឃ្លាត　　ចិត្តឥតរវាតយាត្រាសាងផ្នួស ។
ប្រាំពីរធីអាផ្តាច់ប្តូរព្យាយាម　　ឥតមានទាក់ទាមក្នុងនាមអ្នកបួស
កំណត់វេលាមិនអាចតិចហួស　　ប្រាំពីរថ្ងៃនោះនឹងបានត្រាស់ដឹង ។
ប្រាំបីមឃសីគង់សោយបាយាស　　ក្នុងថ្ងៃបានត្រាស់ទ្រង់ច្បាស់ទីពឹង
បាយាសថាសមាសថ្វាយព្រះថ្ងៃឡើង　　ហៅបាយត្រាស់ដឹងបានបុណ្យមហិមា ។
ប្រាំបួនជួនភព្វ័ទ្រង់ទ្រាប់ស្បូវភ្លាំង　　ក្លាយជាបល្ល័ង្កគង់តាំងភាវនា
នៅគល់ពោធិព្រឹក្សនាទិសបូព៌ា　　បល្ល័ង្កភគវាផុសត្រាសាយ័ណ្ហ ។
ដប់គាប់ឃប្ចូទ័យអានាបាណៈ　　បរិកម្មប្រចក្សសតិដឹងទាន់
ខ្យល់ចេញខ្យល់ចូលចិត្តមូលមិនភាន់　　ដំណើរជវន័ជាន់ឆ្លងកាមា ។
ដប់មួយជំនួយពីព្រះបារមី　　ផ្ចាញ់មារអប្រីយ៍ព្រមទាំងសេនា
ពុទ្ធប្បវត្តិត្រង់នេះអស្ចារ្យ　　បរិស័ទជ្រះថ្លាបាចផ្កាអភិសេក ។
ដប់ពីរមុនីអង្គទ្រង់សម្រេចញាណ　　ត្រៃវិជ្ជាមានទ្រង់ញាណអនេក
ពិសាខបុណ្ណមីកើតញាណប្លែកៗ　　ពោធិញ្ញាណខ្ពស់ឯកកព្រើកធរណី ។
ដប់បីក្សត្រថ្លៃគង់ក្នុងមហាឋាន　　វិមុត្តិក្សេមក្សាន្តអស់ឋានប្រាំពីរ
សប្តាហ៍ឋានមួយលើកស្ទួយស្ថានទី　　ចេតិយព្រះមុនីប្រាំពីរកន្លែង ។

ដប់បួនជូនព្រហ្មជុំអារាធនា    សូមព្រះភគវាយាងត្រាស់សម្ដែង
ព្រះធម៌ប្រពៃវិស័យសូរ្យសែង    ទ្រង់ព្រមសម្ដែងដោយព្រហ្មវិហារ ។
ដប់ប្រាំចាំច្បាស់ទ្រង់ត្រាស់ធម្មចក្ក    ឥសិបតនៈព្រៃមិគទាយា
ឋានត្រៃរតនៈអាសាឡ្ហបូជា    ថ្ងៃព្រះភគវាស្ថាបនាព្រះសង្ឃ ។
ដប់ប្រាំមួយទ្រង់គង់ត្រាស់ឱវាទ    បាតិមោក្ខស្អាងស្អាតឱវាទផ្ទូរផង់
បេះដូងព្រះធម៌ពន្លឺចតុរង្គ    ថ្ងៃនោះត្រូវត្រង់មាឃបុណ្ណមី ។
ដប់ប្រាំពីរទ្រង់គង់វត្តជេតពន    ប្រោសដល់មហាជននិរន្តរ៍ប្រក្រតី
ទ្រង់យកអរុណជេតពនសួស្ដី    ជេតពនជិនស្រីអាស្រ័យជានិច្ច ។
ដប់ប្រាំបីទ្រង់សម្ដែងបាដិហារ្យ    យមកៈអស្ចារ្យនិគ្រន្ថរត់គេច
នៅក្រុងសាវត្ថីប្រុសស្រីមិនតិច    នេះគឺពុទ្ធកិច្ចសង្គ្រោះលោកា ។
ដប់ប្រាំបួនទ្រង់គង់ឋានត្រៃត្រិង្ស    ត្រិះរិះរំពឹងថ្លឹងគុណមាតា
សម្ដែងអភិធម្មស័ក្តិសមអស្ចារ្យ    ថ្វាយព្រះមាតាសុខាអមតៈ ។
ម្ភៃគឺព្រះអង្គទ្រង់ចាកទេវលោក    ស្ដេចយាងចុះមកដែនសង្កស្សៈ
មហាជនច្រើនពិតយកចិត្តទុកដាក់    បូជាគារវៈអចលចេតិយ ។
ម្ភៃមួយគឺទ្រង់គង់ក្នុងសមាបត្តិ    ព្រះញាណស្ងប់ស្ងាត់លះកាត់លោកិយ៍
អរហត្តផលតម្កល់ប្រក្រតី    ឆាប់ក្ដីយូរក្ដីវិស័យពុទ្ធញ្ញាណ ។

ថ្ងៃពីរប្រមើលមើលគ្រប់វេនេយ្យ   ឧបនិស្ស័យសព្វសត្វដែលមាន
ដោយព្រះករុណាសមាបត្តិញ្ញាណ   ត្រួតសត្វកោដិលានមានពីរវារៈ ។
ថ្ងៃបីទ្រង់លៃវិន័យអាជ្ញា   បញ្ញត្តសិក្ខាតាមការជ្រាបជាក់
មានរឿងកើតមុនខូចគុណសាវ័ក   មានហេតុជាក់លាក់ទើបដាក់វិន័យ ។
ថ្ងៃបួនអង្រួនហឫទ័យករុណា   ជាតកទេសនាសាស្ដាលកលៃ
ដើមរឿងជាហេតុបង្កើតអត្ថន័យ   ជាតកប្រពៃលៃតាមហេតុការណ៍ ។
ថ្ងៃប្រាំទ្រង់ប្រោសដល់ពួកព្រះញាតិ   អង្គព្រះលោកនាថសម្ដែងបាដិហារ្យ
កម្ចាត់មានះព្រះញាតិវង្សា   ទើបត្រាស់ទេសនាគម្ពីរពុទ្ធវង្ស ។
ថ្ងៃប្រាំមួយទ្រង់គង់ធ្ងន់ក្នុងធម៌   បរិស័ទណាល្អមានធម៌ទ្រទ្រង់
ស្ដេចយាងទទួលស្រុះស្រួលដោយអង្គ   គារវៈធ្ងរផង់ឈ្មោះត្រង់ព្រះធម៌ ។
ថ្ងៃប្រាំពីរទ្រង់គង់ចាំព្រះវស្សា   បើមាននរណានិមន្តដោយល្អ
ពេលចេញវស្សាមុនយាងចេញចរ   ទ្រង់ចម្រើនពរត្រាស់លាអ្នកនោះ ។
ថ្ងៃប្រាំបីទ្រង់គង់យ៉ាងឃ្លត់ចត់   មុនភត្តក្រោយភត្តគ្មានភ្លាត់ភ្លេចសោះ
បំពេញពុទ្ធកិច្ចគ្រប់យាមទាំងអស់   ពុទ្ធកិច្ចសង្គ្រោះមនុស្សនិងទេវតា ។
ថ្ងៃប្រាំបួនទ្រង់គង់សោយមំសៈ   ក្នុងថ្ងៃទ្រង់ដាក់អនុដ្ឋានកាយា
បិណ្ឌបាតចុងក្រោយជាទានថ្លៃថ្លា   សោយរសមំសាហឫទ័យបរិសុទ្ធ ។

សាមសិបអវសានទ្រង់បានចូលឈាន　　មុននឹងនិព្វានឈានច្រើនបំផុត
ម្ភៃបួនសែនកោដិសមាបត្តិបរិសុទ្ធ　　រួចហើយទ្រង់ផុតរលត់សង្ខារ ។
អហាំរីខ្ញុំបង្គំវន្ទា　　ឆ្ពោះព្រះភគវាព្រះធម៌ថ្លៃថ្លា
ព្រមទាំងព្រះសង្ឃផ្ទូរផង់សីលា　　ចិន្តាលំអុតព្រះពុទ្ធនិយាម ។
សូមឱ្យសព្វសត្វបដិបត្តិតាមធម៌　　សាសនាបវរល្អដូចព្រះនាម
អរហំសម្មាគ្មានការទាក់ទាម　　កិលេសរវាមរវាតសូន្យបង់ ។
សូមឱ្យសាសនាសម្មាសម្ពុទ្ធ　　បរិស័ទមោះមុតរួមចិត្តទ្រទ្រង់
ឋិតថេរចីរកាលអភិបាលដោយសង្ឃ ព្រមព្រៀងស្មោះត្រង់ផ្ចិតផ្ចង់សិក្ខា ។
សូមមនុស្សទេវតាមានការគោរព　　ទាំងថ្ងៃទាំងយប់ក្នុងព្រះសាសនា
សូមបានសម្រេចដូចក្តីប្រាថ្នា　　អស់នូវតណ្ហាទុក្ខាចប់ឈោង ។

រៀបរៀងដោយលោកគ្រូអគ្គបណ្ឌិត ប៊ុត-សាវង្ស

( ស្រង់ចាក សៀវភៅជំនួយសតិ ភាគទី ១៤ ទំព័រ ៣១៣ )

# ១~បុរាណភាសិត

សក្តិពុំស្មើយស  នាអ្នកខ្ពង់ខ្ពស់  ពុំស្មើចិត្តជា

## បទភាគគតិ

ភាសិតទាស់ថា  នរូអ្នកណា  មានសក្តិខ្ពង់ខ្ពស់
មានត្រឹមតែសក្តិ  ប៉ុន្តែឥតយស  ច្រើនតែរលស់
កេរ្តិ៍ឈ្មោះទៅឯង ។ រីអ្នកមានជាតិ  ត្រកូលអាមាត្យ
មន្ត្រីជាក់ស្តែង  មានចិត្តអាក្រក់  តក់ម៉ក់ស្ងក់ស្ងែង
មានគេខ្លាចក្រែង ប៉ុន្តែគេស្អប់ ។  នរូអ្នកណា
ឥតមានសក្តា  ប៉ុន្តែមានទ្រព្យ  មានគេរាប់អាន
ជុំវិញគ្រប់សព្វ  ជប់នាក់ទាំងជប់  សឹងមូលចូលមក ។
ព្រោះគេមានចិត្ត  មេត្តាអាណិត  ប្រណីហៅរក
ស៊ីចុះមិនគិត  ដេរទៅហៅមក  អ្នកផងចូលជ្រក
បំពេញយសឲ្យ ។

# ២~ព្រះពុទ្ធោវាទ

## សម្ដែងអំពីជនគួរសេពគប់ និងមិនគួរសេពគប់

### បទពាក្យ ៧

*បុគ្គលមិនគួរសេពគប់មិត្ត ចិត្តបាបទុច្ចរិតអាក្រក់ក្រៃ*
*បុរសអធម[1]ឥតតម្លៃ លាមកចង្រៃកុំសេពគប់ ។*
*គួរសេពគប់តែមិត្តកល្យាណ មានចិត្តក្សេមក្សាន្តគ្មានឧបទ្រព*
*បុរសឧត្ដមសមទាំងគ្រប់ គួរតែសេពគប់កុំបោះបង់ ។*
*គប់ពាលពាលនាំទៅរកខុស គប់ប្រាជ្ញជាប្រុសកាន់ពេញអង្គ*
*ឬស្រីដែលមានចិត្តផិតផង់ ស្លូតត្រង់នាំត្រង់មករកត្រូវ ។*
*រីការសេពគប់នោះតែងច្នង ទោះឥតបំណងឲ្យខុសផ្លូវ*
*ក៏តែងជិតដោយតាមគ្នាទៅ ពុំនៅតាមធម្មតាឡើយ ។*
*មនុស្សខ្ចកឃ្វាលសេះឥតខ្ចកសោះ សេះបោះជំហានតាមរឿយៗ*
*ដោយវាហាត់តាមពុំកន្តើយ ពុំយូរលង់ឡើយសេះខ្ចកដែរ ។*

---

*១. អានថា អៈធំ ( ដូចនិយម, មធ្យម ) ។*

ព្រោះវាហាក់ធ្វើតាមគង្វាល ជាលរាលឲ្យចិត្តវាផាកបែរ
វាដើរប៉ាក់ពើកប៉ាក់ពើកដែរ ព្រោះតែយល់ថាគេបង្ហាត់ ។
ទោះបីជាតិឈើជាតិលតា វាសេពគប់គ្នាត្រាតែកាត់
ចងតាមគ្នាវាមិនបាច់ហាត់ តែងបាត់ភាពដើមខ្លះពុំខាន ។
ជាតិល្វីងលាយគ្នានឹងជាតិផ្អែម ធ្វើជាបង្អែមប្រើការបាន
ព្រោះការសេពគប់អាចរុញច្រាន ភាពដើមប៉ុន្មានឲ្យប្រែក្លាយ ។

*( កំណាព្យទាំង ២ ខាងលើនេះ ជាស្នាព្រះហស្តចុងក្រោយបង្អស់ របស់សម្តេចព្រះមហាសុមេធាធិបតី* **ជួន-ណាត ជោតញ្ញាណោ** *ព្រះសង្ឃរាជថ្នាក់ទី ១ គណៈមហានិកាយ )*

## ១~ផ្លែល្វា និងផ្លែខ្នុរណាំង[១]

ឧទុម្ពរទុំ សំបកក្រៅរុំ ក្រហមរលង់
ខាងក្នុងសឹងនៅ ដង្កូវមមង់ ដូចមនុស្សទ្រទង់
ចិត្តជួបូស្សា ។

ផ្លែខ្នុរណាំងទុំ សំបកក្រៅរុំ ច្រូងប្រាលបន្លា
ខាងក្នុងសឹងក្លែប ក្រអែបពីសា ដូចអ្នកសទ្ធា
ចិត្តជាសប្បុរស ។

## ២~កន្លង់ និងរុយ

កន្លង់ប៉ងផ្កា ជនល្អប្រាថ្នា ការគុណប្រយោជន៍ រុយប៉ងសម្អុយ បង្អួយអសោច ជនជួជាតិហោច ប្រាថ្នា ។

## ៣~សុភាសិត

វត្ថុមួយសង្ឃរាជពីរមិនស្អាត លោកធាតុមួយព្រះអាទិត្យបី

១. ច្បាប់ដើម មាន ២ គាថា តែខ្ញុំបាទដាក់បញ្ចូលតែ ១ គាថា ។

នគរមួយស្តេចច្រើនអធិបតី     អ្នកប្រាជ្ញគប្បីដឹងដោយឧបមា។

## ៤~គតិលោក

ពស់មួយក្បាលច្រើនចម្រើនទាស់   ចូលមិនអស់ចេញអបសម្របគ្នា
ពស់មួយកន្ទុយច្រើនទោះបែករា   អាចសម្របស្របគ្នាចេញចូលបាន។

## ៥~ពិសដ៏ពន្លឹក

អាចារ្យមិនពោលពិសដទៃ     ថាជាពិសលើសនៃពិសទ្រព្យសង្ឃ
ពិសឯទៀតអាចសម្លាប់តែអង្គៗ ពិសទ្រព្យសង្ឃអាចសម្លាប់ជនទូទៅ។

( ទាំង ៥ នេះ ចម្លងចេញ លោកនិតិប្បករណ៍ ព្រះ **អ៊ុក~ជា** រៀបរៀង តាមរយៈលោកអ្នកឧកញ៉ា **សុត្តន្តប្រីជាឥន្ទ** ) ។

## ១~ទឹកចិត្តឪម៉ែ

សន្តានហឫទ័យនៃព្រះអរហន្ត     មកលើពួកជនហ្មត់ចត់យ៉ាងណា
ទឹកចិត្តម៉ែឪលើបុត្រធីតា     ហ្មត់ចត់អស្ចារ្យក៏យ៉ាងនោះដែរ ។
ចូរកូនទាំងឡាយកុំវាយតម្លៃ     ទឹកចិត្តប្រពៃនៃពុកនិងម៉ែ

ឲ្យស្មើនឹងទ្រព្យឬនឹងប្រាក់រៀវ ព្រោះថាឪម៉ែជាព្រះអរហន្ត ។
នៅក្នុងលោកនេះពុំមាននរណា ចិត្តគិតប្រាថ្នាមេត្តាពេកពន់
លើកូនប្រុសស្រីមានន័យគុណធ្ងន់ ឲ្យដូចអរហន្តមាតាបិតា ។
បើកូនស្វែងរកអង្គព្រះអរហន្ត ដើម្បីបន្ទន់ឱនក្រាបសិរសា
កូនត្រូវនឹកដល់មាតាបិតា ព្រះអរហន្តាឋិតនៅក្នុងផ្ទះ ។
មាតាបិតាចិន្តាបរិសុទ្ធ ស្ម័គ្រស្មោះលើបុត្រសុទ្ធចិត្តត្រង់លះ
កម្លាំងកាយចិត្តជីវិតប្រាក់មាស ចិត្តល្អដូចជាវេស្សន្តរ៍ក្សត្រា ។

# ២-ភ្នំព្រហ្ម

ភ្នំសុមេរុគឺជាមេភ្នំ ធំក្រៃលែងធំទ្រៃត្រិង្សឋាន
តែគង់នៅតូចជាងម៉ែកល្យាណ ព្រោះម៉ែទ្រឋានព្រះព្រហ្មមុខ ៤។

# ៣- ពាក្យម៉ែឪទូន្មាន

ប្រាប់កូនឲ្យធ្វើល្អ ស្មៀកពាក់សគឺចិត្តស្មោះ
ប្រដៅឥតមានខ្ចោះ ដូចគេប្រោះយកទឹកថ្លា ។
អប់រំក្រើនរំលឹក ទោះល្ងាចព្រឹកឪទេសនា

ប្រាប់កូនឲ្យឧស្សាហ៍ ធ្វើកិច្ចការជាកល្យាណ ។
សុចរិតថ្លៃជាងពេជ្រ កុំបំភ្លេចចោលខ្លួនប្រាណ
មនុស្សថ្លៃពន់ប្រមាណ កុំចោលប្រាណដូរយកប្រាក់ ។
ចោលប្រាណស្មើលក់ខ្លួន ម៉ែពោលផ្ដូនឲ្យប្រចក្ស
មនុស្សយើងថ្លៃជាងប្រាក់ ត្រូវទុកដាក់ខ្លួនឲ្យល្អ ។

## ៤~ថ្នាំរក្សាចិត្ត

រូបសល្អរៀងគួរស្រឡាញ់ តែចាញ់ល្អចិត្តគំនិតជា
មិនយូរប៉ុន្មានរូបជរា ឯចិត្តល្អជាមិនចាស់ឡើយ ។
ចូរកូនប្រុសស្រីកុំបំភ្លេច ធម៌ថ្លៃជាងពេជ្រនាំដល់ត្រើយ
មានរូបមានរោគឥតស្រាកស្បើយ កូនអើយព្រះធម៌មិនចេះឈឺ។
បើកូនរៀនធម៌អប់រំចិត្ត ប្រព្រឹត្តសុចរិតចិត្តកូនភ្លឺ
ជីវិតត្រូវស្លាប់រូបត្រូវឈឺ ប៉ុន្តែចិត្តភ្លឺមិនស្លាប់ទេ ។

## ៥~ការអាង

ឫស្សីមានបន្ទាការពារខ្លួន ប្រាជ្ញអាងច្បាប់ក្បួនការពារខុស
ឫស្សីបែកគុម្ពទំពាំងផុះ សាមគ្គីគ្នារស់បែកគ្នាស្លាប់ ។

## ៦~ចិត្តអប់រំបានល្អ

ធ្ងន់ណែនទីងធីងដូចផែនដី មិនមានជាប់អ្វីដូចអាកាស
ស្ងប់ស្ងៀមត្រជាក់សែនស្រឡះ គឺសុខពិតណាស់ចិត្តអប់រំ ។

## ៧~ការមិននិន្ទាក្នុងលោកមិនមាន

### បទពាក្យ ៨

ព្រះចន្ទនិងថ្ងៃឥតមានជីងអ្វី តែត្រូវប្រុសស្រីនិន្ទាសរសើរ
ពពករសាត់ដូចមានស្លាបហើរ ភ្លៀងខ្យល់ដេកដើរគេថាទាំងអស់ ។
បួសជាព្រះសង្ឃនៅគេរិះគន់ ធ្វើចោរលួចប្លន់គេទាន់ជាក់ខ្លោះ
ត្រាស់ជាព្រះពុទ្ធនៅគេមិនស្មោះ ធម៌ល្អឥតខ្ចោះគង់មានគេស្អប់ ។

សរសើរនិទ្ទាមានពីបុរាណ កាន់យកមិនបានតាមពាក្យទាស់គាប់
បើកូនមានប្រាជ្ញកូននឹងមានកត្តញ្ញូ ត្រូវមួយខុសជប់កុំរាប់ខាងច្រើន ។
( ចាកសៀវភៅ **ម៉ែ** !!! លោកគ្រូអគ្គបណ្ឌិត **ប៊ុត-សាវង្ស** )

## ៨-ចិត្តយើងចិត្តគេ

ចិត្តយើងចិត្តគេ កូនត្រូវរិះរេ គ្នាន់គ្នេរឲ្យច្បាស់
កុំពោលតាមពាល តាមព្រះតម្រាស់ ព្រះធម៌ល្អណាស់
កូនត្រូវប្រតិបត្តិ ។
ចិត្តគេចិត្តយើង បើមានះឡើង កូនត្រូវកម្ចាត់
បើចង់សុខចិត្ត កូនត្រូវហ្វឹកហាត់ រស់ដោយប្រយ័ត្ន
ទើបផុតអន្តរាយ ។

## ៩~កុំចង់កែសភាពពិត

ទានៅតែជាទា មិនក្លាយជាសត្វដទៃ
ចង់ខុសកើតទុក្ខភ័យ ល្អប្រពៃនៅត្រង់ពិត
បំណង់ឲ្យសមហេតុ ច្បាស់ក្រឡែតរឿងជីវិត
កុំចង់កែការពិត អប់រំចិត្តពិតបានសុខ ។

## ១០~មេត្តាភាវនា

ក្ដីសុខគឺជាបំណងធំក្រៃ សត្វក្នុងភពត្រៃភ័យខ្លាចទុក្ខា
អ្នកមានចិត្តខ្ពស់រស់ដោយមេត្តា ខ្ពនជាឧបមាប្រាថ្នាសុខសាន្ត ។
ចម្រើនមេត្តានិងការតាំងចិត្ត សូមឲ្យជីវិតឆ្ងាយជិតសព្វឋាន
រស់នៅបានសុខគ្មានអ្វីរំខាន សីលធម៌កល្យាណបានជាសម្បត្តិ ។
ស្មារតីមិនភ្លេចជាកិច្ចរាល់ថ្ងៃ តាំងចិត្តថ្លាថ្លៃវៀនក្ដីវិបត្តិ
រៀបកាយវាចាសិក្សាហ្វឹកហាត់ មេត្តាសម្បត្តិកម្ចាត់ហិង្សា ។

## ១១~រឹងក្នុង ទន់ក្រៅទិសដៅសាសនា

បង្គាក្តាមខ្យងបង្កងជលសា តួបតាមធម្មជាតិព្រោះថារឹងក្រៅ
ខាងក្នុងទន់សោះតួបតកូនចៅ ដូចមនុស្សល្ងង់ខ្លៅឫកគ្រាន់បើ ។
គោសេះក្របីដីរល្អគន់ រឹងក្នុងក្រៅទន់ជាសត្វបម្រើ
ដូចមនុស្សស្រុកាពរាបសាប្រសើរ ចំណោះគ្រាន់បើដំណើរអ្នកប្រាជ្ញ។
ធម្មជាតិរឹងក្រៅរីកទៅមិនធំ ឫស្សីព្រៃភ្នំបន្ទាគួរខ្លាច
ទោះស្វាត្នោតដូងក៏គង់មិនអាច ធំដូចដើមត្រាចបេងធ្នង់ផ្ចឹករាំង ។
មនុស្សត្រូវចេះគិតគំនិតសិក្សា ធម្មជាតយ៉ាងណាកុំឲ្យភាន់ភាំង
ទន់ក្នុងរឹងក្រៅដូចជាប់ឃុំឃាំង ត្រូវចេះរវាំងប្រយ័ត្នក្នុងក្រៅ ។
រឹងក្នុងទន់ក្រៅសំដៅចរិយា ទន់ភ្លន់រាបសាប្រហារធមិខ្មៅ
គុណធមិចម្រើនផុតការសោកសៅ នេះជាទិសដៅព្រះពុទ្ធសាសនា។

## ១២~ត្រូវមានធម៌វិន័យក្នុងខ្លួន

បព្វជិតមិនសង្រួម នឹងទ្រោមចុះនូវសទ្ធា
គ្រហស្ថតតការងារ ប្រាកដជានឹងធ្លាក់ចុះ ។

រស់នៅឥតវិន័យ　　ដូចក្របីឥតកន្ទុះ
បើឥតធម៌វិញនោះ　　ដូចលីងគ្រួសជះដាក់គេ ។

## ១៣~អានិសង្សសេចក្ដីព្យាយាម

មើលសត្វកណ្ដៀរកពូនដី　　មើលសត្វបក្សីក្រេងសម្បុក
មើលឃ្មុំជាដើមសាងក្ដីសុខ　　ព្យាយាមសម្រុកបានសម្រេច។
ទឹកស្រក់តក់ៗទម្លុះថ្ម　　រលកតៗថ្មសិកដាច់
កាន់ការងារអ្វីត្រូវប្ដូរផ្ដាច់　　ផលល្អសម្រេចព្រោះព្យាយាម។

## ១៤~ពាក្យបុរាណ

ស្លៀកសសាងព្រតចិត្តនៅខ្មៅ　　ចោលប្រាជ្ញនាំខ្លៅចង់ចៀសបាប
យកវែកឲ្យដឹងរសប្រៃសាប　　យកខ្សាច់មកគាបបានប្រេងឬ?
ឫស្សីធ្មើក្លាក់ដាក់គ្មានថ្នាំង　　គងស្គរគាំងវាយមិនឮ
សុរិយាមិនយកជាពន្លឺ　　ជឿធឹងអំពិលអំពែកសត្វ ។

## ១៥~សុចរិតធម៌

យល់ការងារច្បាស់   ប្រឹងប្រែងឲ្យណាស់   សីលធម៌អាជីព
ការងារសុចរិត   ដើរកាន់ប្រទីប   សង្គ្រោះអាជីព
ជាពរពលៈ ។

## ១៦~បណ្ឌិត និងពាលផ្សេងគ្នា

បណ្ឌិតនឹងពាលប្រាជ្ញនិងខ្លៅ   ដូចសនឹងខ្មៅស្រមណ៍នឹងអាប
ពិសេសដូចជាបុណ្យនឹងបាប   បើបុណ្យបាក់ស្វាបបាបក្រញី ។
ខ្ញុំបានរៀបរាប់ភ្ជាប់អត្ថអាថ៌   ចងក្រងខ្ញឹមសារសង្ខេបខ្វី
លើកជូនលោកអ្នកចាស់ក្មេងក្តី មិត្តភក្តិប្រុសស្រីប្រណីផង ។
ខ្ញុំយល់យ៉ាងណាថាយ៉ាងហ្នឹង   បេះតិចខំប្រឹងចាប់ដោតក្រង
អត្ថាធិប្បាយស្រាយចំណង   យកបុណ្យចម្លងប៉ងលើកជូន ។

( ចាប់ពី **ទឹកចិត្តម៉ែ** ដល់**បណ្ឌិត និងពាលផ្សេងគ្នា** ទាំង ១៦ នេះ

រៀបរៀងដោយ លោកគ្រូអគ្គបណ្ឌិត **ប៊ុត~សាវង្ស** )

# ព្រះធម៌កម្ចាត់អវិជ្ជា

*ដួងសុរិយាបំភ្លឺនៅពេលថ្ងៃ ចន្ទពេញបូណ៌មីបំភ្លឺពេលយប់*
*ព្រះធម៌ល្អណាស់ភ្លឺខ្លាំងលើសលប់ ទាំងថ្ងៃទាំងយប់កម្ចាត់មោហា ។*

# សន្សំបុណ្យលះបាប

*បុណ្យបូកនឹងបុណ្យកុំបីបាត់ បាបនោះគួរបិទកុំបីបើក*
*រឿងបានរឿងបង់គង់កម្រើក រៀមច្បងគួរលើកបទបូជា ។*

*( លោកអាចារ្យ* **នឹង~ការ** *)*

# ១~សុជីវធម៌

*សុជីវធម៌តែងលំអមនុស្ស គ្រប់ជនប្រុសស្រីដែលកាន់រក្សា*
*ទោះមានឬក្រជំតូចយ៉ាងណា បានកាន់រក្សាថ្លៃថ្លាឧត្តម ។*
*អំពើគ្រាំគ្រងកន្ទងមិនបាន សុជីវធម៌ជាអ្នករៀបចំ*
*ដកចោលអំពើណាដែលពុំសម រើសស្រង់សន្សំទុកអំពើល្អ ។*

ចេះខ្មាសខ្លួនឯងក្រែងអ្នកដទៃ ចេះលៃចេះលកវិន័យឬធម៌
រស់សមជាមនុស្សខ្ពង់ខ្ពស់បវរ បើមនុស្សគ្មានធម៌ស្មើនឹងតិរច្ឆាន ។

## ២~សល់តែថ្ងៃចាស់

មិនទាន់បានធ្វើអ្វីល្អផង ម្ដែផ្ទាំកន្ទងផុតស្រឡះ
វ័យក្មេងអស់ទៅយ៉ាងរហ័ស សល់តែថ្ងៃចាស់ថ្ងៃជរា ។
បណ្ដាថ្ងៃចាស់ជរាខ្លួន ថ្ងៃមួយចំនួនមានរោគា
នឹងមានថ្ងៃមួយគ្រប់ៗគ្នា គឺពេលវេលាត្រូវមរណា ។
ឯម្យ៉ាងដែលគួរឲ្យស្ដុតណាស់ គឺស្លាប់មុនចាស់មុនយាយតា
ដូច្នេះគួរតែសិក្សា អប់រំចិត្តាផ្លូវធម៌ផង ។

## ៣~សួនមច្ចុរាជ

មច្ចុរាជជាផ្កាវីកបង្អួតខ្លួន រស់នៅក្នុងសួនមច្ចុរាជរក្សា
ជានុយជាផ្កាក់អន្ទាក់តណ្ហា ឥតមានខ្លឹមសារទាក់ដោយសម្រស់ ។
កាមគុណជាគ្រឿងបោកបញ្ឆោតសត្វ បិទបាំងវិបត្តិបង្អួតលាភយស
សត្វលោកលិចលង់ព្រោះជាប់នឹងរស ស្វែងរកលាភយសព្រោះតែកាមគុណ ។

## ៤~មនុស្ស និងសត្វ

កើតជាសត្វឆ្កែតែមានបុណ្យចាស់ នាំឲ្យឆ្កែនោះមានម្ចាស់ស្រឡាញ់
កន្ទែងនៅស្អាតចំណីឆ្ងាញ់ៗ សម្បូរសាច់ខ្លាញ់សុខជាងមនុស្សៗ
កើតមកជាមនុស្សបុណ្យស្មើរតែគ្មាន ក្រខ្សត់អត់ឃ្លានលំបាកក្រៃណាស់
វេទនាជាងសត្វដែលមានបុណ្យខ្លះ កើតមកជួបម្ចាស់អ្នកមានចិត្តធម៌ៗ
តែទោះយ៉ាងណាជាតិមនុស្សឧត្តម ព្រោះអាចសន្សំបុណ្យទានបន្ត
តិរច្ឆានពុំអាចសាងអំពើល្អ បើមនុស្សគ្មានធម៌អន់ជាងសត្វហើយ ។

## ៥~យល់ចិត្តអ្នកក្រ

បើចៅហ្វាយនាយស្គាល់ចិត្តអ្នកក្រ ប្រើខ្ញុំកំដរសុខចម្រើនពិត
ព្រោះចិត្តអ្នកក្រហ៊ានប្តូរជីវិត ដឹងគំនិតចៅហ្វាយចិត្តធម៌ ។

## ៦~ព្រះធម៌ជាស្ពាន

កើតជាមនុស្សហើយ ចូរកុំកន្តើយ រកត្រើយនិព្វាន
សទ្ធាជាពូជ ដូចព្រះទូន្មាន ព្រះធម៌ជាស្ពាន

ធ្ងន់វដ្តសង្សារ ។

បើជា**តិរច្ឆាន** ធ្វើទានម្តេចបាន ទុក្ខលុះមរណា

ឥតស្គាល់សីលទាន ពុំមានធម៌អាថ៌ ខ្វះទាំងអាហារ

ខ្វោចផ្សាលុះក្ស័យ ។

កើតជាមនុស្សនេះ ជាបុណ្យពិសេស ជាលាភធំក្រៃ

កុំភ្លេចសីលទាន ស្ពានឆ្លងភពត្រៃ សុំជាប់និស្ស័យ

ព្រះពុទ្ធសាសនា ។

សទ្ធានៅរាក់ បើខ្វះវីរិយៈ ជំពាក់តណ្ហា

បើខ្វះខន្តិ បាត់ក្តីមេត្តា បើខ្វះបញ្ញា

ជាប់បំណុលកម្ម ។

( ចាប់ពី**សុជីវធម៌** ដល់**ព្រះធម៌ជាស្ពាន** ទាំង ៦ នោះ

រៀបរៀងដោយឧបាសក **គុយ-សុធន** )

# ពាក្យអារាធនា ធម្មកថិកសម្ដែងព្រះធម៌

**អហំខ្ញុំ**ព្រះករុណា[១] ជួសឧបាសិកាឧបាសក
ទាយិកានិងទាយក មានចិត្តជក់ក្នុងធម្មា ។
ខំលះមច្ឆរិយៈ ដែលព័ទ្ធធ្លាក់ក្នុងគ្រឹហា
ចំណាយពេលវេលា ទោះមមាញឹកយ៉ាងណា ។
មកកាន់ទីប្រជុំ ប្រមូលផ្ដុំសាកច្ឆា
ឬស្ដាប់ព្រះធម្មា ពោលវេលាដ៏គួរសម ។
លះកាត់ក្ដីប្រមាទ យល់ថាជាតិមេទុក្ខធំ
ជរាព្យាធិនាំ ទៅកាន់មច្ចុរាជា ។
ព្រោះហេតុដូច្នោះហើយ ព្រះគុណអើយ[២]សូមមេត្តា
សម្ដែងធម៌ទេសនា ជាធម្មាព្រះជិនស្រី ។
ជាធម៌នាំសព្វសត្វ ឲ្យឆ្លងកាត់ផុតភពត្រៃ
កិលេសតណ្ហាក្ស័យ និរភ័យដ៏ក្សេមក្សាន្ត ។
ជាទីបរមសុខ ស្ងប់ចាកទុក្ខពីសន្ដាន

---

១.ធម្មកថិកជាគ្រហស្ថ ត្រូវថា អហំរីខ្ញុំ ។ ២. បើគ្រហស្ថថា ធម្មាចារ្យអើយ ។

ពោលគឺព្រះនិព្វាន មិនមានកើតចាស់ឈឺស្លាប់ ។
ហៃសាធុជនា ទាំងអស់គ្នាសូមត្រងត្រាប់
ព្រះធម៌បវរគាប់ ស្តាប់ហើយស្តាប់បដិបត្តិ ។
ឲ្យត្រង់តាមពុទ្ធដីកា ដោយសទ្ធាប្រសើរក្តាត់
បន្ទោបង់ប្រមាទ ឲ្យខ្វាត់ឃ្វាតពីចិន្តា ។
គួរខន្តីអត់ធន់ ត្រូវគិតគន់ពិចារណា
ផ្ចង់កាយផ្ចង់វាចា ផ្ចង់សោតាផ្ចង់ស្មារតី ។
ត្រូវធ្វើស្មាធិពិត ឯកគ្គតាចិត្តឲ្យប្រពៃ
គោរពព្រះធម៌ថ្លៃ ជាបច្ច័យនៃបញ្ញា ។
ជាហេតុបានចាក់ធ្លុះ ច្បាស់ចំពោះចតុរា-
រិយសច្ច ៤ ប្រការ នាអនាគតនោះហោង ។

# ផ្សាយមេត្តាចិត្តសង្ខេប  ករណីយមេត្តសូត្រ

## បទភាគគតិ

**បាណភូតា** សូម្បីមួយណា ឥតមានសេសសល់
ដែលមានតណ្ហា តក់ស្លុតកង្វល់ ឬមាំមួនដល់
អស់តណ្ហាក្តី ។
ពួកសត្វមានកាយ វែងធំទាំងឡាយ កណ្តាលឬខ្លី
ស្គមធាត់ដែលឃើញ ឬមិនឃើញក្តី ឋិតនៅនាព្ឋ
ទីឋានឆ្ងាយជិត ។
បានកើតរួចហើយ ឬក៏នៅឡើយ កំពុងពិនិត្យ
ស្វែងរកទីកើត កំណើតថ្មីពិត សូមមានជីវិត
ជាសុខក្សេមក្សាន្ត ។
ឯសត្វដទៃ ផ្សេងទៀតនោះនៃ គប្បីកុំមាន
ចងចិត្តអាឃាត ព្យាបាទបៀតបៀន កំហែងរុករាន
ដល់គ្នានឹងគ្នា ។

មិនគួរមើលងាយ ដល់សត្វទាំងឡាយ ទោះតិចក្តីណា
និងកុំតាំងចិត្ត គិតប៉ងប្រាថ្នា ឲ្យទុក្ខដល់គ្នា
ដោយការក្រោធខឹង ។

និងបដិឃសញ្ញា ថ្នាំងថ្នាក់ចង្អៀតតានតឹង គួរប្រញាប់លះ
មានះរឹងត្អឹង ហើយគួរខំប្រឹង ចម្រើនមេត្តា ។

ថាសត្វសាកល សូមមានខ្លួនដល់ សុខក្សេមគ្រប់គ្នា
កុំឲ្យមានទុក្ខ រោគសោកវេរា ប្រៀបដូចមាតា
រក្សាបុត្តថ្លៃ ។

ហ៊ានប្តូរជីវិត ស្លាប់រស់មិនគិត ព្រោះបុត្តពិសី
ជាកូនតែមួយ ប្រសូតពីផ្ទៃ ថ្នាក់ថ្នមបមបី
ភក្តីស្ងួនភ្ងា ។

សាធុទាំងឡាយ គប្បីផ្សព្វផ្សាយ មេត្តាព្រហ្មវិហារ
ដល់ពពួកសត្វ កម្ចាត់វេរា សព្វពេលវេលា
គ្រប់ឥរិយាបថ ។

បណ្ឌិតពោលថា កិរិយាន៎ុះណា ជាសាសន៍ប្រាកដ
អ្នកបានចម្រើន កើនចិត្តបរិសុទ្ធ នឹងបានឆ្ងងផុត

បាកកពទាំងបី ។

មាតាបិតា ឧបជ្ឈាយាចារ្យ បុព្វការី

មួយអន្ទើដោយ ប្រេតជាញាតិ ជាដើមនោះនៃ

សុំលោកត្រេកអរ ។

អនុមោទនា បុញ្ញភាគា ដោយចិត្តស្មោះស

ហើយសូមសុខសាន្ត ក្នុងឋានបវរ លុះសម្រេចធម៌

មគ្គផលនិព្វាន ។

សូមពុទ្ធសាសនា នៃព្រះមហាគោតម ទ្រង់ញាណ

រុងរឿងបិតថេរ ចីរកាលថ្កើងថ្កាន បរិបូរបាន

ប្រាំពាន់ឆ្នាំហោង ។

( រៀបរៀងដោយ ឧបាសក **ជាំ-គុយ** )

# ស្រីមិនខ្វះប្រុសមិនក្រ

កិច្ចសិក្សា ត្រូវទុកថា ជាទីមួយ ខំបោះពួយ គឺប្រឹងប្រែង

យ៉ាងហានក្លា កុំជ្រមុល ពុលជ្រមុជ ជុចស្នេហា ត្រូវសិក្សា

ឲ្យចប់សិន សឹមណេះណោះ ស្រីមិនខ្វះ ប្រុសមិនក្រ

ល្អគគោក នៅងងោក ក្បាលងងុល មិនក្រសោះ ។

*ចាំទទួល អ្នកបេះដឹង ប្រឹងរៀនទោះ ដោយស្មគ្រស្មោះ*
*អស់ពីពោះ ពិតមិនខាន បើរវល់ តែពីរឿង ស្នេហាវិញ*
*មិនបំពេញ ខាងចំណេះ ផេះចង្ក្រាន ក្រវិជ្ជា ដូចជាក្រ*
*អ្វីគ្រប់ឋាន ចូរប្រុងប្រាណ គឺប្រឹងប្រែង សិក្សាអឺយ ។*

*( និពន្ធដោយលោកសាស្ត្រាចារ្យ ភាសាខ្មែរ* **ឱម~ណាគ្រី**
*ទសវត្ស ទី ៦០ )*

**២៩៥-ស្រវឹងនឹងជីវិត... ភ្លេចងាប់**
**ស្រវឹងនឹងទ្រព្យ... ភ្លេចខ្លួន**
**ស្រវឹងនឹងភាពមាំមួន... ភ្លេចអនិច្ចំ**
**ស្រវឹងនឹងកម្លាំង... ភ្លេចរោគ**
**ស្រវឹងនឹងលោក... ភ្លេចលាញ**
**ស្រវឹងនឹងជំនាញ... ភ្លេចប្រយ័ត្ន**
**ស្រវឹងនឹងសម្បត្តិ... ភ្លេចសីលទាន**
**ស្រវឹងនឹងមាន... ភ្លេចក្រ**
**ស្រវឹងនឹងត្រាច់ចរ... ភ្លេចផ្ទះសម្បែង**
**ស្រវឹងនឹងក្មេង... ភ្លេចចាស់**

ស្រីងអ្វីទៀតច្រើនណាស់...ភ្លេចកោតក្រែង

ស្រីងនឹងប្តីប្រពន្ធគ្នាឯង... ភ្លេចម៉ែភ្លេចឪ ។

(ស្រង់ចាកសៀវភៅបទពិចារណា ដែលរៀបរៀងដោយ

លោកគ្រូអគ្គបណ្ឌិត ប៊ុត~សាវង្ស)